ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី

## ចក្ខុវិស័យឆ្នាំ២០៤០


**រៀបចំដោយ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

បោះពុម្ពផ្សាយលើកទី១

ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧, ខែមិថុនា ឆ្នាំ២០២៣


ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី ចក្ខុវិស័យឆ្នាំ២០៤០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១១៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២២/១២៣៦ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីអស្សាមិករណ៍

-បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសំណង់

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្ដីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្ដីពីការកែសម្រួលមាត្រា២និងមាត្រា៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្ដីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញអនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្ដីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលមាត្រា ៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

**សម្រេច**

**មាត្រា ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី ដែលមានចក្ខុវិស័យដល់ឆ្នាំ ២០៤០ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យនេះ។

**មាត្រា ២.-**

ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីអាចធ្វើការកែសម្រួលក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្ដង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការកែសម្រួលផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីមុនពេលកំណត់ អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈឬផលប្រយោជន៍ជាតិ។

ការកែសម្រួលផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីត្រូវអនុវត្តតាមនីតិវិធីនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃចន្ទ ២រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដើម្បីចុះហត្ថលេខា**

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**ជា សុផារ៉ា**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
**លេខ : ៥៤៨ សជណ.ដប**

ថ្ងៃចន្ទ ២ រោច ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**

- **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**
- **ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី**

**កម្មវត្ថុ ៖** ករណីគោរពស្នើសុំសម្រេចដ៏ខ្ពង់ខ្ពស់ដាក់ឱ្យប្រើប្រាស់ "ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីចក្ខុវិស័យឆ្នាំ២០៤០" ដោយអនុក្រឹត្យស្ដីពីការដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី។

**យោង ៖** - លិខិតលេខ១១១៦ ដនស/គ.ដ.ន.ជ ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៣ របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្ដីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលយល់ព្រមដាក់ឱ្យប្រើប្រាស់ "ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីចក្ខុវិស័យឆ្នាំ២០៤០" មានភ្ជាប់មកជាមួយដូចខាងក្រោម៖

១-អនុក្រឹត្យស្ដីពីការដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី។

២-ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី ចក្ខុវិស័យឆ្នាំ២០៤០។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមឯកឧត្តមជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ឈួន សុធី**

**ចម្លងជូន៖**
- ក្រសួងមហាផ្ទៃ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងបរិស្ថាន
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...១១៧...អនក្រ.បក ចុះថ្ងៃ...ចន្ទ ២ រោច ខែ...ជេស្ឋ...ឆ្នាំ...ថោះ... បញ្ចស័ក ព.ស.២៥៦៧
ត្រូវនឹងថ្ងៃទី...៥.... ខែ...មិថុនា... ឆ្នាំ២០២៣
ស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី

# ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី

## ចក្ខុវិស័យឆ្នាំ២០៤០

# មាតិកា

ទំព័រ


**១- សេចក្តីផ្តើម** ---------- ១

**២- ក្របខ័ណ្ឌសង្គម-សេដ្ឋកិច្ច និងបរិស្ថាន** ---------- ២

**២.១- កត្តាភូមិសាស្ត្រនិងប្រជាសាស្ត្រ** ---------- ២

**២.២- កត្តាបរិស្ថានរូបសាស្ត្រ** ---------- ៣

២.២.១- សណ្ឋានដីនិងអាកាសធាតុ ---------- ៣

២.២.២- ប្រព័ន្ធផ្លូវទឹកនិងតំបន់ជម្រាលទឹកភ្លៀង ---------- ៣

២.២.៣- ប្រភេទដីនិងភាពសមស្របសម្រាប់កសិកម្ម ---------- ៤

**២.៣- ការប្រើប្រាស់ដីនិងការគ្រប់គ្រងការប្រើប្រាស់ដី** ---------- ៤

២.៣.១- ការប្រែប្រួលគម្របដី ---------- ៤

២.៣.២- ការប្រើប្រាស់ដីបច្ចុប្បន្ន ---------- ៥

២.៣.៣- ព្រៃឈើ ---------- ៦

២.៣.៤- កសិកម្ម ---------- ៨

២.៣.៥- ការយករ៉ែ ---------- ៩

២.៣.៦- កសិករខ្នាតតូចនិងសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ---------- ៩

**២.៤- សេវាកម្មប្រព័ន្ធអេកូឡូស៊ី** ---------- ១០

**២.៥- ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត** ---------- ១១

២.៥.១- បណ្តាញផ្លូវ ---------- ១១

២.៥.២- អគ្គិសនី ---------- ១២

**២.៦- ប្រជាសាស្ត្រ** ---------- ១២

**២.៧- ការផ្តល់សេវាសង្គម** ---------- ១៣

**២.៨- ការងារ** ---------- ១៤

**២.៩- សមាសធាតុសំខាន់ៗនៃទម្រង់ការរៀបចំដែនដី** ---------- ១៤

២.៩.១- បណ្តាញទំនាក់ទំនងក្នុងតំបន់និងបណ្តាញផ្លូវថ្នល់ ---------- ១៤

២.៩.២- ប្រព័ន្ធប្រើប្រាស់ដី ---------- ១៦

២.៩.៣- រចនាសម្ព័ន្ធពហុមជ្ឈមណ្ឌលទីប្រជុំជន ---------- ១៧

២.៩.៤- ប៉ូលអភិវឌ្ឍសេដ្ឋកិច្ច ---------- ១៨

**៣- ចក្ខុវិស័យ** ---------- ១៩

**៤- គោលបំណងអភិវឌ្ឍរយៈពេលវែងនិងគោលដៅ** ---------- ២២

**៥- យុទ្ធសាស្ត្រអភិវឌ្ឍដែនដី** ---------- ២៤

**៥.១- យុទ្ធសាស្ត្រជំរុញការអភិរក្សប្រកបដោយនិរន្តរភាពក្នុងដែនជម្រកសត្វព្រៃនិងរបៀងអភិរក្សជីវៈចម្រុះ**------------------------------------------------------------------------------------------------- ២៥
៥.១.១- យុទ្ធសាស្ត្ររង : ជំរុញកិច្ចខិតខំប្រឹងប្រែងអភិរក្សនៅក្នុងតំបន់ស្នូលនិងតំបន់អភិរក្សក្នុងដែនជម្រកសត្វព្រៃ------------------------------------------------------------------------------------- ២៥
៥.១.២- យុទ្ធសាស្ត្ររង : លើកកម្ពស់ការគ្រប់គ្រងព្រៃឈើដោយសហគមន៍មូលដ្ឋាននិងពង្រឹងកសិកម្មបែបធម្មជាតិនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនិងតំបន់សហគមន៍ក្នុងដែនជម្រកសត្វព្រៃ( ការប្រើប្រាស់ដីសហគ្រប់គ្រង) ------------------------------------------------------------ ២៦
៥.១.៣- យុទ្ធសាស្ត្ររង : ធានាឱ្យបាននូវការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាពនិងការពារព្រៃឈើនៅក្នុងរបៀងអភិរក្សជីវៈចម្រុះ ------------------------------------------------------------ ២៧
៥.១.៤- យុទ្ធសាស្ត្ររង : ការពារតំបន់ទេសភាពដែលជាផ្នែកមួយនៃអត្តសញ្ញាណបរិស្ថាន សង្គម និងវប្បធម៌របស់ខេត្តមណ្ឌលគិរី ------------------------------------------------------------ ២៨
**៥.២- យុទ្ធសាស្ត្រកម្រិតផលប៉ះពាល់អវិជ្ជមានលើសេដ្ឋកិច្ច បរិស្ថាន និងសង្គមនៃគម្រោងអភិវឌ្ឍខ្នាតធំ**------------------------------------------------------------------------------------------------- ២៩
៥.២.១- យុទ្ធសាស្ត្ររង : កម្រិតផលប៉ះពាល់អវិជ្ជមាននៃប្រតិបត្តិការទាញយករ៉ែ---------------- ២៩
៥.២.២- យុទ្ធសាស្ត្ររង : កម្រិតផលប៉ះពាល់អវិជ្ជមាននៃគម្រោងអភិវឌ្ឍទំនប់វារីអគ្គិសនី------- ៣០
**៥.៣- យុទ្ធសាស្ត្រគាំទ្រការបង្កើតមជ្ឈមណ្ឌលអប់រំអំពីការអភិរក្សធនធានធម្មជាតិនិងលើកកម្ពស់ការសិក្សាស្រាវជ្រាវអំពីជីវៈចម្រុះនិងការអភិរក្សប្រកបដោយនិរន្តរភាព**------------------------------- ៣០
៥.៣.១- យុទ្ធសាស្ត្ររង : លើកកម្ពស់ការសិក្សានៅទីវាលជាក់ស្តែងអំពីជីវៈចម្រុះ---------------- ៣០
**៥.៤- យុទ្ធសាស្ត្រពង្រីកការអភិវឌ្ឍអេកូទេសចរណ៍ដោយផ្សារភ្ជាប់នឹងការគ្រប់គ្រងធនធានធម្មជាតិនិងការអភិរក្សវប្បធម៌ប្រកបដោយនិរន្តរភាព**------------------------------------------------------------ ៣១
៥.៤.១- យុទ្ធសាស្ត្ររង : លើកកម្ពស់ការអភិវឌ្ឍវិស័យអេកូទេសចរណ៍ -------------------------- ៣១
៥.៤.២- យុទ្ធសាស្ត្ររង : លើកកម្ពស់ការអភិវឌ្ឍវិស័យទេសចរណ៍វប្បធម៌ជនជាតិដើមភាគតិច --៣២
៥.៤.៣- យុទ្ធសាស្ត្ររង : លើកកម្ពស់ការអភិវឌ្ឍវិស័យសេវាកម្មនិងផលិតផលទេសចរណ៍------- ៣២
**៥.៥- យុទ្ធសាស្ត្រគាំទ្រការអភិវឌ្ឍមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដែលលើកកម្ពស់ដល់សេវាកម្មនិងផលិតផលទេសចរណ៍ផ្អែកលើធនធានមូលដ្ឋាន** ------------------------------------------ ៣២
៥.៥.១- យុទ្ធសាស្ត្ររង : កំណត់គម្រោង រៀបចំគម្រោង និងអនុវត្តការបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីអភិវឌ្ឍជំនាញចាំបាច់ដល់ការគ្រប់គ្រងទេសចរណ៍សហគមន៍មូលដ្ឋាន ---------- ៣៣
៥.៥.២- យុទ្ធសាស្ត្ររង : កំណត់គម្រោង រៀបចំគម្រោង និងអនុវត្តការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីលើកកម្ពស់ផលិតផលរបស់ខេត្តមណ្ឌលគិរី------------------------------------------ ៣៣
**៥.៦- យុទ្ធសាស្ត្រជំរុញការអភិវឌ្ឍកសិកម្មខ្នាតតូចប្រកបដោយនិរន្តរភាពសម្រាប់កសិករ**------- ៣៣
៥.៦.១- យុទ្ធសាស្ត្ររង : ធានាឱ្យបាននូវការអភិវឌ្ឍកសិកម្មលក្ខណៈគ្រួសារប្រកបដោយភាពរស់រវើក (មានប្រសិទ្ធភាពនៃសេដ្ឋកិច្ច យុត្តិធម៌សង្គម និងបរិស្ថានល្អ)------------------- ៣៣
៥.៦.២- យុទ្ធសាស្ត្ររង : ការពារកសិកម្មវិលជុំដែលមានស្រាប់និងគាំទ្រការផ្លាស់ប្តូរពីប្រព័ន្ធកសិកម្មចម្ការវិលជុំទៅជាកសិកម្មអចិន្ត្រៃយ៍------------------------------------------ ៣៤

**៥.៧- យុទ្ធសាស្ត្រលើកកម្ពស់ការអភិវឌ្ឍកសិឧស្សាហកម្មខ្នាតធំប្រកបដោយការទទួលខុសត្រូវ ដើម្បីផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមកជាមួយកសិកម្មខ្នាតតូច** ---------- ៣៥

៥.៧.១- យុទ្ធសាស្ត្ររង : ជំរុញការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ចដែលស្វែងរកផលប្រយោជន៍រួមគ្នាជាមួយកសិកម្មខ្នាតតូច ---------- ៣៥

**៥.៨- យុទ្ធសាស្ត្រពង្រឹងការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍នៅក្រៅប្រព័ន្ធតំបន់ការពារធម្មជាតិ** ---------- ៣៦

៥.៨.១- យុទ្ធសាស្ត្ររង : ពង្រឹងការគ្រប់គ្រងសហគមន៍ព្រៃឈើដែលមានស្រាប់ ---------- ៣៦

៥.៨.២- យុទ្ធសាស្ត្ររង : ពង្រឹងគម្រោងសហគ្រប់គ្រងសហគមន៍នេសាទដែលមានស្រាប់ ---------- ៣៦

**៥.៩- យុទ្ធសាស្ត្រលើកកម្ពស់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន និងការធ្វើដំណើរ ដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានសេវាសាធារណៈសម្រាប់ប្រជាជននិងគាំទ្រការអភិវឌ្ឍតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម** ---------- ៣៦

៥.៩.១- យុទ្ធសាស្ត្ររង : អភិវឌ្ឍមជ្ឈមណ្ឌលដឹកជញ្ជូនកម្រិតតំបន់ដែលលើកកម្ពស់បរិស្ថានផ្សារភ្ជាប់ទៅនឹងអាកាសយានដ្ឋានថ្មីនិងក្រុងសែនមនោរម្យ ---------- ៣៧

៥.៩.២- យុទ្ធសាស្ត្ររង : ធ្វើឱ្យប្រសើរឡើងនូវចល័តភាពក្នុងខេត្តមណ្ឌលគីរីនិងលទ្ធភាពទទួលបានសេវាសាធារណៈ ---------- ៣៧

**៥.១០- យុទ្ធសាស្ត្រលើកកម្ពស់កំណើនអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនិងការអភិវឌ្ឍតាមតំបន់ព្រំដែនតាមផែនការច្បាស់លាស់ជាមជ្ឈមណ្ឌលអភិវឌ្ឍន៍ថ្មី ដើម្បីសម្រួលដល់ការផ្លាស់ប្តូរពាណិជ្ជកម្មជាមួយប្រទេសជិតខាង** ---------- ៣៨

៥.១០.១- យុទ្ធសាស្ត្ររង : គាំទ្រការអភិវឌ្ឍ បរិក្ខារ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មតាមព្រំដែន និងកាត់បន្ថយផលប៉ះពាល់បរិស្ថានពីការអភិវឌ្ឍ ---------- ៣៩

៥.១០.២- យុទ្ធសាស្ត្ររង : ពង្រឹងកិច្ចសហប្រតិបត្តិការតាមព្រំដែននិងគ្រប់គ្រងការអភិវឌ្ឍតំបន់ព្រំដែន ---------- ៤០

**៥.១១- យុទ្ធសាស្ត្រលើកកម្ពស់កំណើនអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនិងការអភិវឌ្ឍកសិឧស្សាហកម្មនិងប្រភេទឧស្សាហកម្មផ្សេងទៀតក្នុងតំបន់មានសក្តានុពល ហើយតភ្ជាប់បណ្តាញដឹកជញ្ជូននិងតំបន់ផែស្ងួតទៅនឹងទីផ្សារក្នុងស្រុកនិងទីផ្សារក្រៅស្រុក** ---------- ៤០

៥.១១.១- យុទ្ធសាស្ត្ររង : ពង្រឹងសមត្ថភាពនៃការគ្រប់គ្រងរបស់ខេត្ត ដើម្បីបង្កើនតម្លៃផលិតផលកសិកម្មរបស់ខ្លួនតាមរយៈការគ្រប់គ្រង ការស្តុកទុក និងកែច្នៃឱ្យបានល្អ ---------- ៤០

៥.១១.២- យុទ្ធសាស្ត្ររង : ជំរុញការអភិវឌ្ឍឧស្សាហកម្មផ្អែកលើចំណេះដឹង បច្ចេកវិទ្យា និងនវានុវត្តន៍ដោយមិនប៉ះពាល់ដល់បរិស្ថាន ---------- ៤១

**៥.១២- យុទ្ធសាស្ត្រលើកកម្ពស់ការអភិវឌ្ឍទីក្រុង ទីប្រជុំជនដោយមានផែនការច្បាស់លាស់និងប្រកបដោយនិរន្តរភាព ដើម្បីឆ្លើយតបនឹងកំណើនតម្រូវការសេវាកម្មសាធារណៈ និងឯកជននិងកំណត់ផលប៉ះពាល់នៃកំណើននគរូបនីយកម្មលើបរិស្ថាន** ---------- ៤១

៥.១២.១- យុទ្ធសាស្ត្ររង : គ្រប់គ្រងការអភិវឌ្ឍនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាពនិងចីរភាព ៤១

៥.១២.២- យុទ្ធសាស្ត្ររង : ធានានូវការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មទីក្រុងចាំបាច់ឱ្យកាន់តែប្រសើរឡើង ---- ៤៣

**៥.១៣- យុទ្ធសាស្ត្រលើកកម្ពស់ទេសភាពទីក្រុង ទីប្រជុំជនតាមរយៈការលើកកម្ពស់និងអភិរក្សប្រព័ន្ធបៃតងធម្មជាតិនិងកសិកម្មក្នុងក្រុង ទីប្រជុំជន និងតំបន់ជុំវិញ** ---- ៤៣

៥.១៣.១- យុទ្ធសាស្ត្ររង : រៀបចំ កសាង និងអនុវត្តផែនការប្រព័ន្ធទេសភាពបៃតងលម្អិតនិងបទប្បញ្ញត្តិចាំបាច់ ---- ៤៣

៥.១៣.២- យុទ្ធសាស្ត្ររង : រៀបចំ កសាង និងអនុវត្តតំបន់ទេសភាពកសិកម្មនៅក្នុងមជ្ឈមណ្ឌលទីក្រុង ទីប្រជុំជនសំខាន់ៗ ---- ៤៤

**៥.១៤- យុទ្ធសាស្ត្រគ្រប់គ្រងនិងផ្តល់សេវាកម្មបរិស្ថានទីក្រុងប្រកបដោយប្រសិទ្ធភាពនិងមានគុណភាពខ្ពស់ ឆ្លើយតបនឹងកំណើនទីក្រុងនិងការអភិវឌ្ឍសេដ្ឋកិច្ច** ---- ៤៤

៥.១៤.១- យុទ្ធសាស្ត្ររង : លើកកម្ពស់ការផ្តល់សេវាកម្មនិងបរិក្ខារគាំទ្រការផ្គត់ផ្គង់ទឹកស្អាតមានសុវត្ថិភាពនិងគ្រប់គ្រាន់ក្នុងតំបន់ទីក្រុងនិងតំបន់ជុំវិញ ---- ៤៤

៥.១៤.២- យុទ្ធសាស្ត្ររង : ធានាការគ្រប់គ្រងសំណល់រាវមានប្រព័ន្ធបង្ហូរទឹកកខ្វក់និងប្រព័ន្ធបង្ហូរទឹកភ្លៀងក្នុងទីក្រុង ទីប្រជុំជនប្រកបដោយប្រសិទ្ធភាព ---- ៤៥

៥.១៤.៣- យុទ្ធសាស្ត្ររង : ធានាការគ្រប់គ្រងសំណល់រឹងក្នុងទីក្រុង ទីប្រជុំជនប្រកបដោយប្រសិទ្ធភាព ---- ៤៦

**៥.១៥- យុទ្ធសាស្ត្រប្រើប្រាស់ដី** ---- ៤៦

៥.១៥.១- ការកំណត់តំបន់គោលប្រើប្រាស់ដីក្នុងខេត្តមណ្ឌលគិរី ---- ៤៦

៥.១៥.២- ការកំណត់បទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម ---- ៤៨

**៦- ផែនការសកម្មភាព** ---- ៥០

**៧- ធនធានហិរញ្ញវត្ថុ** ---- ៥០

**៨- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ** ---- ៥១

**៨.១- យន្តការ** ---- ៥១

៨.១.១- យន្តការថ្នាក់ជាតិ ---- ៥១

៨.១.២- យន្តការថ្នាក់ក្រោមជាតិ ---- ៥១

៨.១.៣- នីតិវិធីសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ---- ៥២

**៨.២- គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត** ---- ៥៣

**៨.៣- ការអភិវឌ្ឍស្ថាប័ន** ---- ៥៣

**៩- សេចក្តីសន្និដ្ឋាន** ---- ៥៣

**សន្ទានុក្រម** ---- ៥៥

**ឯកសារឧបសម្ព័ន្ធ** ---- ៦០

## ១- សេចក្តីផ្តើម

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញនិងច្បាប់ រាជរដ្ឋាភិបាលកម្ពុជាបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែកនិងគ្រប់វិស័យ ក្នុងគោលដៅបង្កើននិងកែលម្អការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព ដោយដាក់ចេញនូវគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗជាច្រើនពាក់ព័ន្ធនឹងការរៀបចំដែនដីនិងនគរូបនីយកម្មនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មានជាអាទិ៍គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់សំណង់ ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។

គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជាគឺជាត្រីវិស័យតម្រង់ទិសមួយដ៏សំខាន់សំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជាត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍតាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដីនិងការធ្វើឱ្យរលូននូវវិធាននិងឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។

ផ្អែកលើមូលដ្ឋានគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗទាំងនេះ និងដោយមើលឃើញពីភាពលេចធ្លោនៃធនធានធម្មជាតិនៅក្នុងខេត្តមណ្ឌលគិរី គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តមណ្ឌលគិរី ដោយមានការគាំទ្រថវិកាពីសហភាពអឺរ៉ុប(EU) និងពីភ្នាក់ងារសហរដ្ឋអាម៉េរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ(USAID)តាមរយៈអង្គការមូលនិធិសកលសម្រាប់ធម្មជាតិ(WWF)កម្ពុជា និងដោយមានការគាំទ្របច្ចេកទេសពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានកសាងផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីប្រកបដោយការទទួលខុសត្រូវនិងមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល វិស័យឯកជន និងសហគមន៍មូលដ្ឋានជាដើម។ ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីបានផ្តល់នូវគោលការណ៍អភិវឌ្ឍន៍និងឧបករណ៍គតិយុត្តសម្រាប់គាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្តនិងដំណើរការនៃការអភិវឌ្ឍដែនដីដ៏មានប្រសិទ្ធភាព ដើម្បីលើកកម្ពស់ការអភិវឌ្ឍដែនដីនិងភាពជាម្ចាស់រួមគ្នាប្រកបដោយតុល្យភាពរវាងការគ្រប់គ្រងធនធានធម្មជាតិ ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព បរិយាបន្ន និងការទទួលបាននូវសេវាសាធារណៈប្រកបដោយសមធម៌។

ជារួម ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីគឺជាក្របខ័ណ្ឌអភិវឌ្ឍដែនដីគ្រប់ជ្រុងជ្រោយផ្អែកលើចក្ខុវិស័យនិងផ្តល់នូវទិសដៅជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍខេត្តមណ្ឌលគិរីក្នុងរយៈពេល២០ឆ្នាំ។ ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីមានគោលបំណងចង្អុលបង្ហាញនូវគោលនយោបាយ ផែនការ កម្មវិធី និងយុទ្ធសាស្ត្រពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលកម្ពុជា និងតម្រង់ទិសការធ្វើសមាហរណកម្មផែនការគ្រប់វិស័យនិងគ្រប់កម្រិត។ ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីកំណត់នូវរចនាសម្ព័ន្ធដែនដីរបស់ខេត្តមណ្ឌលគិរីនិងមុខងារជាក់លាក់ទៅតាមតំបន់ផ្សេងៗគ្នាក្នុងដែនដីរបស់ខេត្តមណ្ឌលគិរីសម្រាប់ចក្ខុវិស័យឆ្នាំ២០៤០ ដោយផ្អែកលើសមាសធាតុសំខាន់ៗចំនួន៤ គឺប្រព័ន្ធប្រើប្រាស់ដី ការដឹកជញ្ជូននិងបណ្តាញតភ្ជាប់ រចនាសម្ព័ន្ធពហុមជ្ឈមណ្ឌលទីប្រជុំជន និងប៉ូលអភិវឌ្ឍសេដ្ឋកិច្ច។

## ២- ក្របខ័ណ្ឌសង្គម-សេដ្ឋកិច្ច និងបរិស្ថាន

### ២.១- កត្តាភូមិសាស្ត្រនិងប្រជាសាស្ត្រ

ខេត្តមណ្ឌលគិរីត្រូវបានបង្កើតឡើងដោយព្រះរាជក្រមលេខ៦៤ប.រ. ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៦១ ដោយកាត់ចេញពីស្រុកឆ្លូងលើ ខេត្តក្រចេះ ហើយចែកចេញជា៣ស្រុក គឺស្រុកកោះញែក ស្រុកច្បារ និងស្រុកអូររាំង។ ខេត្តមណ្ឌលគិរីស្ថិតនៅភាគឦសាននៃព្រះរាជាណាចក្រកម្ពុជា មានព្រំប្រទល់បច្ចុប្បន្នខាងលិចជាប់នឹងខេត្តក្រចេះ ខាងជើងជាប់នឹងខេត្តស្ទឹងត្រែងនិងខេត្តរតនគិរី និងខាងកើតនិងខាងត្បូងជាប់នឹងខេត្តដាក់ឡាក់ ខេត្តដាក់ណុង និងខេត្តបិញភឿក នៃប្រទេសវៀតណាម។ ខេត្តមណ្ឌលគិរីមានចម្ងាយប្រមាណ៣៥៨គីឡូម៉ែត្រពីរាជធានីភ្នំពេញ ដោយធ្វើដំណើរតាមផ្លូវជាតិលេខ៨ លេខ៧ និងលេខ៧៦ ឆ្លងកាត់តាមខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ និងមានផ្ទៃដីសរុប១៤ ២៨៨គីឡូម៉ែត្រក្រឡា ស្មើនឹង១ ៤២៨ ៨០០ហិកតា ដែលត្រូវបានទទួលស្គាល់ដោយក្រសួងមហាផ្ទៃ ដោយឡែកទិន្នន័យភូមិសាស្ត្រដែលប្រើប្រាស់សម្រាប់ការងារកសាងផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី មានភាពខុសគ្នាបន្តិចបន្តួច មានផ្ទៃដីសរុប១៣ ៧១៥គីឡូម៉ែត្រក្រឡា។

បច្ចុប្បន្ន រដ្ឋបាលខេត្តមណ្ឌលគិរីចែកចេញជាក្រុងចំនួន១ គឺក្រុងសែនមនោរម្យ និងស្រុកចំនួន៤ មានស្រុកកែវសីមា ស្រុកកោះញែក ស្រុកអូររាំង និងស្រុកពេជ្រាដា ហើយបែងចែកជា៤សង្កាត់ និង១៧ឃុំ ស្មើនឹង៩២ភូមិ ក្នុងនោះចំនួន១៤ភូមិ ស្ថិតនៅក្នុងក្រុងសែនមនោរម្យ និងចំនួន៧៨ភូមិទៀត ស្ថិតនៅតាមបណ្តាស្រុកទាំង៤។ យោងតាមរបាយការណ៍របស់មន្ទីរផែនការ ក្នុងឆ្នាំ២០២០ ខេត្តមណ្ឌលគិរីមានប្រជាជនសរុបចំនួន៩០ ៩៤៩នាក់ ក្នុងនោះមានជនជាតិដើមភាគតិចរស់នៅប្រមាណ៤៧ភាគរយ។ ខេត្តមណ្ឌលគិរីជាខេត្តមានដង់ស៊ីតេទាបជាងគេក្នុងចំណោមខេត្តទាំងអស់នៃព្រះរាជាណាចក្រកម្ពុជាគឺត្រឹម៦,០៣នាក់/គីឡូម៉ែត្រក្រឡាប៉ុណ្ណោះ។

ខេត្តមណ្ឌលគិរីអាចចាត់ទុកជាខេត្តយុទ្ធសាស្ត្រមួយនៅភាគឦសានរបស់ព្រះរាជាណាចក្រកម្ពុជាដែលស្ថិតនៅក្នុងក្របខ័ណ្ឌតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា- ឡាវ- វៀតណាម(CLV)និងមានសក្តានុពលតភ្ជាប់ទំនាក់ទំនងជាមួយបណ្តាញគមនាគមន៍និងសេដ្ឋកិច្ចនៃមហាអនុតំបន់ទន្លេមេគង្គ(GMS) ដែលផ្តល់នូវកាលានុវត្តន៍យ៉ាងពិសេសសម្រាប់សមាហរណកម្មសេដ្ឋកិច្ចទៅក្នុងតំបន់និងពិភពលោក។ ម្យ៉ាងទៀត ខេត្តមណ្ឌលគិរីក៏មានសក្តានុពលធនធានធម្មជាតិនិងវប្បធម៌ដ៏សម្បូរបែបដែលផ្តល់នូវកាលានុវត្តន៍យ៉ាងខ្លាំងសម្រាប់ការអភិវឌ្ឍអេកូទេសចរណ៍។

## ២.២- គន្លាបរិស្ថានរូបសាស្ត្រ

### ២.២.១- សណ្ឋានដីនិងអាកាសធាតុ

ខេត្តមណ្ឌលគិរីជាខេត្តតំបន់ខ្ពង់រាប មានរយៈកម្ពស់ប្រែប្រួលអប្បបរមាពី៤០ម៉ែត្រដល់អតិបរមា១ ០៣០ម៉ែត្រធៀបនឹងនីវ៉ូទឹកសមុទ្រ។ រយៈកម្ពស់ខ្ពស់បំផុត ស្ថិតនៅប៉ែកអាគ្នេយ៍នៃខេត្តមណ្ឌលគិរីគឺនៅស្រុកពេជ្រាដាក្បែរព្រំដែនជាមួយប្រទេសវៀតណាម។ រយៈកម្ពស់នេះមានស្ថានភាពជម្រាលធ្លាក់ចុះទៅប្រព័ន្ធទន្លេមេគង្គផ្នែកខាងលិចនិងស្រុកកោះញែក និងទៅផ្នែកខាងជើងខេត្តរតនគិរី។ តំបន់មួយចំនួននៃខេត្តមណ្ឌលគិរី ត្រូវបានរកឃើញនូវវត្ថុមានប្រភេទរ៉ែលោហៈមានតម្លៃ ដូចជារ៉ែមាស រ៉ែបុកស៊ីតជាដើម។ វត្ថុមានរ៉ែមាសត្រូវបានរកឃើញនៅក្នុងល្បាយលាយឡំជាមួយប្រភេទសិលាមេថ្មខ្សាច់ក្រហមទ្រីយ៉ាស៊ិកដែលស្ថិតនៅក្នុងស្រុកពេជ្រាដានិងស្រុកកោះញែក ខណៈដែលវត្ថុមានរ៉ែបុកស៊ីតដែលមានល្បាយលោហៈអាលុយមីញ៉ូមពី២៥ទៅ៣៥ភាគរយត្រូវបានរកឃើញនៅក្នុងស្រុកអូររាំង។ រីឯប្រភេទត្បូងថ្មពណ៌បៃតងស្រាលដែលមានផ្ទុកសារធាតុម៉ាញ៉េស្យូមច្រើន ហៅថា "**ថ្មសំអាងមានតម្លៃ**" ត្រូវបានរកឃើញនៅតាមជ្រលងភ្នំនានា។

ខេត្តមណ្ឌលគិរីមានសីតុណ្ហភាពទាបជាងបណ្តាខេត្តនានានៃប្រទេសកម្ពុជា ហើយគម្លាតនៃការប្រែប្រួលក្នុងឆ្នាំក៏តូចជាងនៅតំបន់ទំនាបកណ្តាលដែរ។ ទិន្នន័យចន្លោះឆ្នាំ២០១៥ទៅឆ្នាំ២០១៨ បង្ហាញថា កម្រិតសីតុណ្ហភាពជាមធ្យមប្រចាំឆ្នាំគឺត្រឹម២៧,២អង្សាសេ(សីតុណ្ហភាពអប្បបរមាជាមធ្យមធ្លាក់ដល់១៦,២អង្សាសេ នៅខែមករានិងសីតុណ្ហភាពអតិបរមាជាមធ្យមឡើងដល់៣៧,០អង្សាសេនៅខែមេសា)។ ការប្រែប្រួលសីតុណ្ហភាពមានទំនាក់ទំនងទៅនឹងរយៈកម្ពស់ភូមិសាស្ត្រ ដោយតំបន់ដែលមានរយៈកម្ពស់ខ្ពស់មានសីតុណ្ហភាពទាប។ សីតុណ្ហភាពអតិបរមាជាមធ្យមប្រែប្រួលពី២៥,២៤អង្សាសេនៅតំបន់ប៉ែកអាគ្នេយ៍ទៅដល់៣០,៩៥អង្សាសេនៅតំបន់ប៉ែកពាយ័ព្យ។ រីឯសីតុណ្ហភាពអប្បបរមាជាមធ្យមប្រែប្រួលពី១៧,១៨អង្សាសេនៅតំបន់ប៉ែកអាគ្នេយ៍ទៅដល់២៣,៩៦អង្សាសេនៅតំបន់ប៉ែកពាយ័ព្យដែលជាតំបន់មានរយៈកម្ពស់ខ្ពស់និងទទួលបានបរិមាណកម្ពស់ទឹកភ្លៀងខ្ពស់ជាងតំបន់ដទៃទៀត។ បរិមាណទឹកភ្លៀងនៅចន្លោះឆ្នាំ២០១៥ទៅឆ្នាំ២០១៨ ជាមធ្យមប្រចាំឆ្នាំមានប្រមាណ២ ០០១មីលីម៉ែត្រ ក្នុងនោះបរិមាណកម្ពស់ទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំធ្លាក់ទាបត្រឹម១ ៦៤៨មីលីម៉ែត្រនៅឆ្នាំ២០១៥ និងបរិមាណកម្ពស់ទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំឡើងខ្ពស់ដល់២ ២៦៦មីលីម៉ែត្រនៅឆ្នាំ២០១៧។

### ២.២.២- ប្រព័ន្ធផ្លូវទឹកនិងតំបន់ជម្រាលទឹកភ្លៀង

ទន្លេសំខាន់ៗដែលហូរឆ្លងកាត់ខេត្តមណ្ឌលគិរីគឺជាដៃទន្លេដែលហូរចាក់ចូលទៅទន្លេមេគង្គ ដោយមានផ្ទៃជម្រាលហូរចាក់ពីទិសខាងកើតទៅទិសខាងលិច និងបន្តហូរទៅខេត្តក្រចេះនិងខេត្តស្ទឹងត្រែង។ ផ្ទៃទឹកធំជាងគេនៃខេត្តមណ្ឌលគិរី គឺទន្លេស្រែពកដែលជាផ្នែកមួយនៃប្រព័ន្ធជលធារវិទ្យា ស៣(ទន្លេស្រែពក ទន្លេសេសាន និងទន្លេសេកុង)។ ទន្លេស្រែពកមានប្រភពចេញពីប្រទេសវៀតណាម ដោយហូរឆ្លងកាត់ខេត្តមណ្ឌលគិរីតាមស្រុកកោះញែក។ ទន្លេស្រែពកមានទឹកជាប្រចាំគ្រប់រដូវ ប៉ុន្តែកម្ពស់ទឹកមានការប្រែប្រួលខ្លាំងរវាងរដូវប្រាំងនិងរដូវវស្សា។ ដោយឡែក ផ្ទៃទឹកដទៃទៀតនៅខេត្តមណ្ឌលគិរីពុំមានទឹកជាប្រចាំគ្រប់រដូវនោះ ដោយរីងស្ងួតនៅរដូវប្រាំង។ ភស្តុតាងមួយចំនួនបានបង្ហាញថា ការសាងសង់ទំនប់វារីអគ្គិសនីនៅខ្សែទឹកខាងលើនៃទន្លេមេគង្គនិងនៅតាមដៃទន្លេនេះគឺជាមូលហេតុដែលបង្កឱ្យមានការប្រែប្រួលកម្ពស់ទឹកនេះ។

ដៃទន្លេសំខាន់មួយរបស់ទន្លេស្រែពកគឺអូរច្បារដែលហូរកាត់ភូមិសាស្ត្រស្រុកកោះញែកពីទិសខាងត្បូងទៅទិសខាងជើង។ អូរច្បារមានសារៈសំខាន់ណាស់សម្រាប់ទ្រទ្រង់វិស័យកសិកម្មនៅតំបន់ភាគខាងជើងនៃខេត្តមណ្ឌលគិរី ដោយសារនៅរដូវវស្សា អូរច្បារបានហូរនាំទឹកទៅចាក់បំពេញបឹងសំខាន់ៗដែលអាចពង្រីកវិសាលភាពសម្រាប់ស្រោចស្រពនៅរដូវវស្សានិងនៅរដូវប្រាំងបានមួយកម្រិតបន្ថែមទៀត។ ទន្លេ ប្រភពទឹកផ្សេងទៀត និងតំបន់ជម្រាលទឹកភ្លៀងរបស់វាដែលជួយស្រោចស្រពក្នុងខេត្តមណ្ឌលគិរី ចាប់ពីភាគខាងត្បូងទៅភាគខាងជើងមានជាអាទិ៍ព្រែកឆ្លូង ព្រែកទេរ(អូរទេរ) ព្រែកគ្រៀង(អូរគ្រៀង) និងព្រែកព្រះ(អូរព្រះ)។

### ២.២.៣- ប្រភេទដីនិងភាពសមស្របសម្រាប់កសិកម្ម

លក្ខណៈនៃដីនិងភាពសមស្របរបស់ដីសម្រាប់កសិកម្មគឺអាស្រ័យលើលក្ខណវិនិច្ឆ័យ ដូចជាភូគព្ភសាស្ត្រ សណ្ឋានដី អាកាសធាតុ និងប្រភពទឹក។ ប្រភេទដីដែលកើតចេញពីសិលាមេនៅតំបន់ខ្ពង់រាបភាគឦសានជាប្រភេទដី Ferralsol ស្មើនឹង៩ភាគរយនៃផ្ទៃដីសរុបខេត្តមណ្ឌលគិរី។ ដីប្រភេទនេះមានពណ៌ក្រហមនិងលឿងដែលពណ៌នេះកើតមកពីការប្រមូលផ្តុំនៃដែកអុកស៊ីដ ពិសេសដែកនិងអាលុយមីញ៉ូម។ ប្រភេទដី Ferralsol មិនមែនជាប្រភេទដីដែលសម្បូរទៅដោយសារធាតុគីមីទេ ប៉ុន្តែជាប្រភេទដីដែលមានស្រទាប់ជ្រៅល្អ សក្តិសមសម្រាប់ដំណាំកសិកម្ម ដូចជាដំណាំប្រចាំឆ្នាំនិងដំណាំរយៈពេលវែងដែលមានឫសចាក់ចូលក្នុងដីជ្រៅ។

ផ្សារភ្ជាប់ជាមួយស្ថានភាពឡើងចុះនៃសណ្ឋានដី យើងអាចសង្កេតឃើញថា ប្រភេទដីដែលមានស្រទាប់រាក់និងជាប្រភេទដី Leptosols ស្មើនឹង១១ភាគរយនៃផ្ទៃដីសរុបខេត្តមណ្ឌលគិរីដែលជាប្រភេទដីថ្មគ្រួសមិនសមស្របសម្រាប់ដំណាំកសិកម្មទេ។ ក្នុងលក្ខខណ្ឌអ៊ីដ្រូសែនបន្ថែមទៀត(ឧទាហរណ៍ ផ្នែកនិរតីនៃខេត្តមណ្ឌលគិរី) យើងមើលឃើញថា ជាប្រភេទដី Gleysols ស្មើនឹង៦ភាគរយនៃផ្ទៃដីសរុបខេត្តមណ្ឌលគិរីដែលជាដីសើម។ ប្រសិនបើច្រោះទឹកបានល្អ ប្រភេទដីនេះអាចសមស្របសម្រាប់ដំណាំកសិកម្មកម្រិតមធ្យម។ ដីមួយប្រភេទទៀតគឺប្រភេទដី Acrisols ស្មើនឹង៦៤ភាគរយនៃផ្ទៃដីសរុបខេត្តមណ្ឌលគិរី។ ប្រភេទដី Acrisols សម្បូរទៅដោយដីឥដ្ឋដែលជាប់ទាក់ទងជាមួយសំណើមអាកាសធាតុត្រូពិក ហើយជារឿយៗ ប្រភេទដី Acrisols ជួយទ្រទ្រង់តំបន់ព្រៃឈើ។ ប្រភេទដី Acrisols កើតឡើងពីការពុកផុយនៃប្រភេទសិលាមេថ្មខ្សាច់(Sand-stone) ហើយជាដីមានកម្តៅខ្ពស់។ ប្រភេទដី Acrisols ពុំសូវល្អឬសមស្របសម្រាប់ដំណាំកសិកម្មទេ ប៉ុន្តែនៅពេលប្រភេទដីនេះជួបនឹងលក្ខខណ្ឌជក់ទឹកនិងស្ថិតនៅតំបន់ដែលមានរយៈកម្ពស់ទាបវិញ ជាប្រភេទដីដែលសមស្របសម្រាប់កសិកម្មខ្លាំងទៅវិញ។

## ២.៣- ការប្រើប្រាស់ដីនិងការគ្រប់គ្រងការប្រើប្រាស់ដី

### ២.៣.១- ការប្រែប្រួលគម្របដី

ចន្លោះឆ្នាំ១៩៩៩ ដល់ឆ្នាំ២០១៩ ប្រភេទគម្របដីនៅតំបន់សំខាន់ៗក្នុងខេត្តមណ្ឌលគិរីមានការប្រែប្រួលយ៉ាងខ្លាំងលើផ្ទៃដីប្រមាណ៣០៣ ៤៦៤ហិកតាស្មើនឹង២១ភាគរយនៃផ្ទៃដីសរុបខេត្តមណ្ឌលគិរី។ ការប្រែប្រួលគម្របដីបានកំណត់ជា៣ប្រភេទសំខាន់ៗដូចខាងក្រោម៖

- **ការបាត់បង់ព្រៃឈើទៅជាដីកសិកម្ម** ការប្រែប្រួលនេះរាប់ទាំងការប្រែប្រួលនៃប្រភេទព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃល្បោះឬព្រៃរបោះ ការសឹករេចរឹលនៃព្រៃឈើឬប្រភេទព្រៃផ្សេងទៀត ទៅជាដំណាំស្រូវ ដំណាំចម្ការ និងចម្ការលាយឡំជាមួយព្រៃ។ ការផ្លាស់ប្តូរផ្ទៃដីព្រៃឈើសរុបប្រមាណ **១៨៧ ៧៧៣**ហិកតាស្មើនឹង៦២ភាគរយនៃការប្រែប្រួលគម្របដីសរុបឬស្មើនឹង១៣,១ភាគរយនៃផ្ទៃដីសរុបខេត្តមណ្ឌលគិរី។ ការពង្រីកផ្ទៃដីកសិកម្មគឺជាកត្តាចម្បងដែលនាំឱ្យមានការបាត់បង់ព្រៃឈើនៅខេត្តមណ្ឌលគិរីតាមរយៈការអនុវត្តដំណើរការកសិឧស្សាហកម្មខ្នាតធំ ការផ្តល់ដីសម្បទានសេដ្ឋកិច្ចសម្រាប់ដំណាំកៅស៊ូឬតាមរយៈកសិកម្មខ្នាតតូចរបស់កសិករសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ ឬតាមរយៈកសិកម្មលក្ខណៈសហគ្រាសដែលបានអនុវត្តលើផ្ទៃដីខ្នាតមធ្យមចន្លោះពី២០ទៅ៥០ហិកតា
- **ការសឹករេចរឹលព្រៃឈើ** ការប្រែក្លាយពីព្រៃល្បោះ ព្រៃពាក់កណ្តាលស្រោង និងព្រៃស្រោង ទៅជាព្រៃរេចរឹល។ ការផ្លាស់ប្តូរនេះមានផ្ទៃដី៤១ ៦៣៨ហិកតាស្មើនឹង៣,៤ភាគរយនៃផ្ទៃដីសរុបគម្របព្រៃល្បោះ ព្រៃពាក់កណ្តាលស្រោង និងព្រៃស្រោង។ ការផ្លាស់ប្តូរទៅជាប្រភេទព្រៃរេចរឹលនេះ កើតឡើងក្នុងទ្រង់ទ្រាយធំនិងមើលមិនសូវឃើញច្បាស់លើរូបភាពផ្កាយរណប ដូចការបាត់បង់ព្រៃឈើសម្រាប់កសិកម្មនោះទេ។ ព្រៃរេចរឹលគឺជាទម្រង់នៃការផ្លាស់ប្តូរគម្របដី ហើយអាចនឹងផ្លាស់ប្តូរទៅជាតំបន់កសិកម្មនាពេលអនាគត
- **ការកើនឡើងដង់ស៊ីតេព្រៃឈើឬការដុះឡើងវិញនៃព្រៃឈើ** ការផ្លាស់ប្តូរពីប្រភេទព្រៃរេចរឹលនិងព្រៃផ្សេងៗទៅជាប្រភេទព្រៃល្បោះ ព្រៃពាក់កណ្តាលស្រោង និងព្រៃស្រោង។ ព្រៃដុះឡើងវិញមានផ្ទៃដី៥១ ៤១៣ហិកតាស្មើនឹង១៧ភាគរយនៃការប្រែប្រួលគម្របដីសរុបឬស្មើនឹង៣,៥ភាគរយនៃផ្ទៃដីសរុបខេត្តមណ្ឌលគិរី។ ព្រៃដុះឡើងវិញនេះ កើតឡើងនៅតំបន់កណ្តាលនៃខេត្តមណ្ឌលគិរី ពិសេសនៅតំបន់ដែលបានកំណត់ជាតំបន់ការពារធម្មជាតិ។ ទន្ទឹមនឹងនេះ ក៏មានតំបន់ដែលមានការកើនឡើងដង់ស៊ីតេព្រៃឈើផងដែរដែលជាសក្ខីភាពមួយបញ្ជាក់អំពីភាពជោគជ័យនៃការខិតខំប្រឹងប្រែងក្នុងកិច្ចការពារព្រៃឈើក្នុងតំបន់មួយចំនួនក្នុងខេត្តមណ្ឌលគិរី។

### ២.៣.២- ការប្រើប្រាស់ដីបច្ចុប្បន្ន

ការកំណត់ប្រភេទប្រើប្រាស់ដីលម្អិតឆ្នាំ២០១៩ ផ្អែកលើរូបភាពផ្កាយរណបតាមរយៈប្រព័ន្ធចាប់យកព័ត៌មានពីលម្ហអាកាសដែលថតនៅខែកុម្ភៈ ឆ្នាំ២០១៩ ខណៈមានពពកបាំងតិចបំផុត។ ការបកប្រែរូបភាពផ្កាយរណបគឺផ្អែកលើមូលដ្ឋាននៃការផ្ទៀងផ្ទាត់ថ្នាក់លើកទី១សម្រាប់អង្គការ WWF ដោយក្រុមអ្នកជំនាញខាងប្រព័ន្ធចាប់យកព័ត៌មានពីលម្ហអាកាសដែលបានប្រើប្រាស់សំណុំចៃដន្យនៃចំណុចផ្ទៀងផ្ទាត់លើដីជាក់ស្តែង ដើម្បីពិនិត្យភាពជាក់លាក់នៃការបកប្រែរូបភាពផ្កាយរណបនិងសុក្រឹត្យភាពនៃប្រភេទប្រើប្រាស់ដីឆ្នាំ២០១៩។ នៅដំណាក់កាលចាំបាច់ រូបភាពផ្កាយរណបរបស់ Google Earth ដែលមានកម្រិតនៃភាពច្បាស់លាស់ខ្ពស់ត្រូវបានប្រើប្រាស់ ដើម្បីជួយដល់ការផ្ទៀងផ្ទាត់ការបកប្រែរូបភាពផ្កាយរណប។ ប្រភេទប្រើប្រាស់ដីដែលពាក់ព័ន្ធនឹងកសិកម្មមានផ្ទៃដីស្មើនឹង៩,៨ភាគរយនៃផ្ទៃដីសរុបខេត្តមណ្ឌលគិរី ក្នុងនោះមានចម្ការម្រេចនិងប្រភេទចម្ការផ្សេងៗដែលមិនអាចកំណត់ប្រភេទដំណាំបាន ដូចជាដំណាំប្រចាំឆ្នាំនិងដំណាំរយៈពេលវែង ព្រមទាំងវាលស្រែដែលធ្វើការដាំ

ដុះនៅផ្នែកខាងជើងនៃស្រុកកោះញែក។ ចម្ការដំណាំលាយឡំជាមួយព្រៃមានផ្ទៃដីស្មើនឹង២,២ភាគរយនៃផ្ទៃដីសរុបខេត្តមណ្ឌលគិរី ហើយមិនអាចកំណត់ប្រភេទដំណាំជាក់លាក់ក្នុងប្រភេទនេះទេ ប៉ុន្តែដីកសិកម្មពនេចរទាំងទីតាំងកំពុងដាំដុះនិងទីតាំងធ្លាប់ដាំដុះពីមុនក៏ត្រូវបានរាប់បញ្ចូលទៅក្នុងប្រភេទចម្ការលាយឡំជាមួយព្រៃដែរ។

នៅពេលដែលដំណាំកៅស៊ូត្រូវបានរាប់បញ្ចូលជាប្រភេទព្រៃឈើ គម្របព្រៃក្នុងឆ្នាំ២០១៩ មានផ្ទៃដីស្មើនឹង៨៩,៨ភាគរយនៃផ្ទៃដីសរុបខេត្តមណ្ឌលគិរី។ ព្រៃល្បោះ ព្រៃពាក់កណ្ដាលស្រោង និងព្រៃស្រោងជាផ្នែកដ៏ធំមួយនៃគម្របព្រៃឈើដែលមានផ្ទៃដីស្មើនឹងប្រមាណ៧៨,៨ភាគរយនៃផ្ទៃដីសរុបខេត្តមណ្ឌលគិរី។ ចម្ការកៅស៊ូបានរួមចំណែកលើផ្ទៃដីស្មើនឹងប្រមាណ៥ភាគរយ ខណៈព្រៃរេចរឹលរួមជាមួយវាលស្មៅមានផ្ទៃដីស្មើនឹង៥,៥ភាគរយនៃផ្ទៃដីសរុបខេត្តមណ្ឌលគិរី។ ការបំប្លែងពីព្រៃឈើទៅជាដីកសិកម្មនាំឱ្យមានការប្រែប្រួលគម្របដីពីមុនដែលធ្វើឱ្យតំបន់ទាំងនេះក្លាយជាព្រៃរេចរឹលនិងវាលស្មៅ។ ប៉ុន្តែធនធានដីក្នុងតំបន់នេះនឹងផ្ដល់សក្ដានុពលយ៉ាងសំខាន់ដែលអាចប្រើប្រាស់សម្រាប់ការអភិវឌ្ឍវិស័យកសិកម្មនាពេលអនាគត។

### ២.៣.៣- ព្រៃឈើ

#### ក- ការគ្រប់គ្រងតំបន់ការពារ

ខេត្តមណ្ឌលគិរីតាមរយៈព្រះរាជក្រឹត្យស្ដីពីតំបន់ការពារធនធានធម្មជាតិដែលបានអនុម័តនៅឆ្នាំ១៩៩៣ បានកំណត់ឱ្យមានដែនជម្រកសត្វព្រៃចំនួន៣ គឺដែនជម្រកសត្វព្រៃភ្នំព្រេច ដែនជម្រកសត្វព្រៃភ្នំណាមលៀរ និងដែនជម្រកសត្វព្រៃលំផាត់។ ដែនជម្រកសត្វព្រៃគឺជាតំបន់បម្រុងធម្មជាតិដោយផ្អែកលើលក្ខខណ្ឌធម្មជាតិដើម្បីការពារសត្វព្រៃ រុក្ខជាតិ និងរក្សាតុល្យភាពអេកូឡូស៊ី។ ទោះជាយ៉ាងនេះក្ដី ដែនជម្រកសត្វព្រៃមិនដើរតួនាទីសំខាន់ក្នុងការផ្ដល់សេវាកម្មទេសចរណ៍សម្រាប់សាធារណជនទូទៅដូចឧទ្យានជាតិនោះទេ។ លើសពីនេះ ខេត្តមណ្ឌលគិរីមានតំបន់ការពារព្រៃឈើចំនួន២កន្លែងដែលបានកំណត់នៅឆ្នាំ២០០២ គឺស្រែពកនិងកែវសីមា។ គិតត្រឹមឆ្នាំ២០២០ ខេត្តមណ្ឌលគិរីមានតំបន់ការពារចំនួន៥កន្លែងដែលគ្រប់គ្រងដោយក្រសួងបរិស្ថាននិងគ្របដណ្ដប់លើផ្ទៃដីសរុប៩២៥ ៨៣៥ហិកតាស្មើនឹង៦៤,៨ភាគរយនៃផ្ទៃដីសរុបខេត្តមណ្ឌលគិរី។ នៅឆ្នាំ២០១៧ របៀងអភិរក្សជីវៈចម្រុះថ្មីត្រូវបានបង្កើតឡើង ហើយបានបញ្ចូលទៅក្នុងប្រព័ន្ធនៃតំបន់ការពារធម្មជាតិ។ របៀងអភិរក្សជីវៈចម្រុះព្រៃសានត្រូវបានបែងចែកជា៣ផ្នែក គ្របដណ្ដប់លើខេត្តមណ្ឌលគិរីមានផ្ទៃដី**១៧៧ ៨៥៦**ហិកតាដែលធ្វើឱ្យផ្ទៃដីសរុបស្ថិតក្រោមការគ្រប់គ្រងតំបន់ការពារធម្មជាតិកើនឡើងផ្ទៃដីដល់**១ ១០៣ ៦៩១**ហិកតាស្មើនឹង**៧៧** ភាគរយនៃផ្ទៃដីសរុបខេត្តមណ្ឌលគិរី។

ការវិភាគនិងការពិនិត្យលម្អិតលើធនធានធម្មជាតិនិងវិសាលភាពនៃគម្របដីក្នុងតំបន់ការពារធម្មជាតិចន្លោះឆ្នាំ**១៩៩៩**ដល់ឆ្នាំ២០១៩ជាមូលដ្ឋានសម្រាប់ជំរុញប្រសិទ្ធភាពកិច្ចខិតខំប្រឹងប្រែងការពារធនធានធម្មជាតិ។ ក្នុងចំណោមដែនជម្រកសត្វព្រៃទាំង៥ ក្នុងខេត្តមណ្ឌលគិរី ដែនជម្រកសត្វព្រៃភ្នំណាមលៀរនិងដែនជម្រកសត្វព្រៃកែវសីមាត្រូវបានទទួលរងការកាប់ទន្ទ្រានព្រៃឈើខ្លាំងបំផុតនៅក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ ហើយបន្តរាលដាលចូលទៅក្នុងដែនជម្រកសត្វព្រៃស្រែពក។ ដែនជម្រកសត្វព្រៃស្រែពកមានការការពារព្រៃឈើបានល្អ។ ម្យ៉ាងវិញទៀត ការសឹករេចរឹលនៃព្រៃឈើ រួមជាមួយនឹងការកាប់ឈើហុបបានកើតឡើងនៅប៉ែកខាងជើងដែលអាចបញ្ជាក់បានថា ការបាត់បង់ព្រៃឈើនៅតែបន្តមានការគំរាមកំហែងក្នុងខេត្តមណ្ឌលគិរី ពោលគឺនៅក្នុងដែនជម្រកសត្វព្រៃភ្នំព្រេច។ រីឯដែនជម្រកសត្វព្រៃលំផាត់ជាតំបន់ដែលទទួលបានការអភិរក្សល្អជាងគេក្នុងចំណោមដែនជម្រកសត្វព្រៃទាំងអស់ ពិសេសផ្នែកដែលស្ថិតនៅក្នុងភូមិសាស្ត្រខេត្តមណ្ឌលគិរី។

ច្បាប់ស្តីពីតំបន់ការពារធម្មជាតិដែលបានអនុម័តនៅឆ្នាំ២០០៨ បានបញ្ជាក់យ៉ាងច្បាស់អំពីការគ្រប់គ្រងតំបន់ការពារធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ច្បាប់នេះបានកំណត់តំបន់ការពារធម្មជាតិចំនួន៤តំបន់ រួមមានតំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ក្នុងគោលបំណងធានានូវការគ្រប់គ្រង ការអភិរក្សជីវៈចម្រុះ និងការធានាការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិប្រកបដោយនិរន្តរភាព។

គិតមកត្រឹមឆ្នាំ២០២០ ដែនជម្រកសត្វព្រៃភ្នំណាមលៀរមិនទាន់មានការកំណត់បែងចែកតំបន់នៅឡើយ។ តំបន់ស្នូលនិងតំបន់អភិរក្សរួមបញ្ចូលគ្នាមានផ្ទៃដីស្មើនឹងប្រមាណ៦៦ភាគរយនៃផ្ទៃដីសរុបតំបន់ការពារធម្មជាតិ។ ដោយឡែកតំបន់សហគមន៍គ្របដណ្តប់លើផ្ទៃដីស្មើនឹងត្រឹម៩,២ភាគរយប៉ុណ្ណោះ ហើយមានប្រជាជនស្មើនឹង១៦ភាគរយនៃចំនួនប្រជាជនសរុបខេត្តមណ្ឌលគិរីកំពុងរស់នៅក្នុងតំបន់ការពារធម្មជាតិ។ ចំនួនប្រជាជននេះអាចនឹងបន្តកើនឡើងនាថ្ងៃអនាគត។

### ខ- សហគ្រប់គ្រងលើធនធានព្រៃឈើ

សហគមន៍តំបន់ការពារធម្មជាតិគឺជាគម្រោងនៃការគ្រប់គ្រងរួមគ្នាដែលត្រូវបានបង្កើតឡើងក្នុងតំបន់ព្រៃឈើច្បាស់លាស់ស្ថិតនៅតំបន់ប្រើប្រាស់ដោយចីរភាពនៃតំបន់ការពារធម្មជាតិ។ ខេត្តមណ្ឌលគិរីមានសហគមន៍តំបន់ការពារធម្មជាតិចំនួន២១សហគមន៍ដែលគ្របដណ្តប់លើផ្ទៃដី៦២ ២៣៥ហិកតាស្មើនឹង៦,៧ភាគរយនៃផ្ទៃដីសរុបតំបន់ការពារធម្មជាតិ។ ដីព្រៃឈើដែលស្ថិតនៅខាងក្រៅតំបន់ការពារធម្មជាតិគឺស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលការគ្រប់គ្រងមានទម្រង់ប្រហាក់ប្រហែលនឹងគោលការណ៍គ្រប់គ្រងរួមដែរ ហើយត្រូវបានហៅថា សហគមន៍ព្រៃឈើ។ ខេត្តមណ្ឌលគិរីមានសហគមន៍ព្រៃឈើចំនួន៨សហគមន៍ មានផ្ទៃដី៩ ៧៩៩ហិកតា និងមានប្រជាជនរស់នៅចំនួន៧២៤គ្រួសារ។

នៅក្នុងឆ្នាំ២០១១ មានសហគមន៍នេសាទចំនួន២សហគមន៍ត្រូវបានបង្កើតឡើងនៅភាគខាងជើងនៃស្រុកកោះញែកដែលមានទម្រង់ជាសហគ្រប់គ្រងប្រហាក់ប្រហែលនឹងសហគមន៍ព្រៃឈើដែរ។ សហគមន៍នេសាទទាំង២ មានផ្ទៃសរុប១ ៥២៩ហិកតាដែលមានគោលបំណងចម្បងការពារនិងគ្រប់គ្រងធនធានទឹកដែលជាប្រភពយ៉ាងសំខាន់សម្រាប់មច្ឆជាតិនិងផ្គត់ផ្គង់ជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់។ ផ្ទៃដីសហគមន៍នេសាទមិនរាប់ត្រឹមតែផ្ទៃទឹកនោះទេគឺរួមទាំងតំបន់ដែលគ្របដណ្តប់ដោយព្រៃឈើជុំវិញដែរ។

### គ- ការគ្រប់គ្រងព្រៃឈើដោយជនជាតិដើមភាគតិចក្រោមរូបភាពកម្មសិទ្ធិសមូហភាព

ច្បាប់ភូមិបាលដែលបានអនុម័តនៅឆ្នាំ២០០១ បានផ្តល់លទ្ធភាពក្នុងការចេញប្រភេទប័ណ្ណកម្មសិទ្ធិដីធ្លីសមូហភាពជូនជនជាតិដើមភាគតិច។ មាត្រា២៥ នៃច្បាប់នេះបានចែងថា សហគមន៍ជនជាតិដើមភាគតិចអាចទទួលបានកម្មសិទ្ធិសមូហភាពនៅលើដីដែលពួកគាត់បានបង្កើតភូមិឋាននិងដីដែលពួកគាត់បានប្រកបរបរកសិកម្មតាមប្រពៃណី។ អនុក្រឹត្យលេខ៨៣អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៩ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ជាមូលដ្ឋានសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច។ យោងតាមអនុក្រឹត្យនេះ ដីដែលជាកម្មវត្ថុនៃការផ្តល់ជូនដោយរាជរដ្ឋាភិបាលក្រោមរូបភាពកម្មសិទ្ធិសមូហភាពត្រូវបានបែងចែកជា៥ប្រភេទ រួមមានដីផលិតកម្មកសិកម្ម ដីលំនៅឋានដែលផ្ទេរចេញពីដីឯកជនរបស់រដ្ឋ ដីបម្រុងទុកសម្រាប់ធ្វើកសិកម្ម ដីព្រៃកប់ខ្មោច និងដីព្រៃអារក្សដែលផ្ទេរចេញពីដីសាធារណៈរបស់រដ្ឋ។

ខេត្តមណ្ឌលគិរី ប័ណ្ណកម្មសិទ្ធិសមូហភាពចំនួន៧ ត្រូវបានផ្តល់ជូនសហគមន៍ជនជាតិដើមភាគតិចតាមនីតិវិធីជាផ្លូវការ ហើយសហគមន៍ចំនួន៧ផ្សេងទៀត កំពុងស្ថិតនៅដំណាក់កាលស្នើសុំការទទួលស្គាល់។ ប្រភេទដីព្រៃកប់ខ្មោចនិងព្រៃអារក្សមានផ្ទៃដីសរុប៤៧០ហិកតាដែលគ្រប់គ្រងដោយជនជាតិដើមភាគតិចត្រូវបានកំណត់ទីតាំងរួចសម្រាប់ផ្តល់ប័ណ្ណកម្មសិទ្ធិសមូហភាពនិងសម្រាប់បង្ហាញដល់សហគមន៍ដទៃទៀត។

**ឃ- ការកាត់បន្ថយការសាយភាយកាបូនពីការបាត់បង់ព្រៃឈើនិងការសឹករេចរឹលនៃព្រៃឈើ(REDD+)**

ការសិក្សាបង្ហាញថា ការបាត់បង់និងការសឹករេចរឹលព្រៃឈើនៅតែជាប្រភពដ៏សំខាន់នៃការសាយភាយកាបូនទៅក្នុងបរិយាកាស ទោះបីជាមានការអនុម័តនូវគោលនយោបាយលើកទឹកចិត្តជាច្រើន ដើម្បីកាត់បន្ថយការសាយភាយកាបូនពីការកាប់ទន្ទ្រានព្រៃនិងការសឹករេចរឹលព្រៃឈើក៏ដោយ។ គម្រោងលើកទឹកចិត្តមួយគឺគម្រោង "**ការកាត់បន្ថយការសាយភាយកាបូនពីការបាត់បង់ព្រៃឈើនិងការសឹករេចរឹលនៃព្រៃឈើ**" (រេដបូក, REDD+)។

ខេត្តមណ្ឌលគិរីមានគម្រោងរេដបូកមួយដែលបានអនុវត្តនៅតំបន់ដែនជម្រកសត្វព្រៃកែវសីមា ដោយមានជំនួយបច្ចេកទេសពីអង្គការសមាគមអភិរក្សសត្វព្រៃ(WCS)ក្រោមជំនួយថវិកាពីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាម៉េរិក(USAID)។ គម្រោងនេះ បានចាប់ផ្តើមតាំងពីខែមករា ឆ្នាំ២០១០ ជាមួយនឹងកម្មវិធីរយៈពេល៦០ឆ្នាំដែលគ្របដណ្តប់លើផ្ទៃដីប្រមាណ១៦៧ ០០០ហិកតានៃផ្ទៃដីព្រៃល្បោះនិងតំបន់ទ្រនាប់លើផ្ទៃដី២៩៧ ០០០ហិកតា។ គម្រោងនេះនឹងបន្តដំណើរការរហូតដល់ឆ្នាំ២០៦៩។ គម្រោងរេដបូកមានអត្ថប្រយោជន៍ចម្បងចំនួន៣ គឺអត្ថប្រយោជន៍សម្រាប់អាកាសធាតុសម្រាប់សហគមន៍និងសម្រាប់ជីវៈចម្រុះ។ ទោះជាយ៉ាងនេះក្តី តាមរយៈការវិភាគលើការប្រែប្រួលគម្របដីខាងលើបានបង្ហាញថា តំបន់គម្រោងនេះមានការគំរាមកំហែងដោយការកាប់ទន្ទ្រានព្រៃឈើ ដើម្បីពង្រីកផ្ទៃដីកសិកម្ម។

### ២.៣.៤- កសិកម្ម

**ក- ដំណាំសំខាន់ៗនិងទីផ្សារចែកចាយកសិផល**

ផ្ទៃដីកសិកម្មនៅក្នុងខេត្តមណ្ឌលគិរីមានការកើនឡើងខ្លាំងគួរឱ្យកត់សម្គាល់ក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ។ ដំណាំប្រចាំឆ្នាំមានដូចជាដំណាំស្រូវនិងដំឡូងមីដែលជាប្រភេទដំណាំមានសារៈសំខាន់ជាងគេគឺស្មើនឹង៥២ភាគរយនិងស្មើនឹង២៩ភាគរយនៃផ្ទៃដីបង្កបង្កើនផលសរុប។ ដោយឡែក ចំពោះដំណាំរយៈពេលវែងដំណាំកៅស៊ូមានបរិមាណច្រើនជាងគេគឺស្មើនឹងប្រមាណ៧៨ភាគរយនៃផ្ទៃដីដាំដុះដំណាំរយៈពេលវែងសរុបបន្ទាប់មកគឺដំណាំស្វាយចន្ទីស្មើនឹង១៤ភាគរយ និងដំណាំម្រេចស្មើនឹង២ភាគរយ។ គួរកត់សម្គាល់ផងដែរ ក្រៅពីដំណាំស្រូវ បន្លែ ដំណាំប្រចាំឆ្នាំ និងដំណាំរយៈពេលវែងដែលបានដាំដុះនៅក្នុងខេត្តមណ្ឌលគិរី ជាប្រភេទដំណាំដែលទទួលបានទីផ្សារក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ។ កត្តានេះបញ្ជាក់ថា ទីផ្សារពិភពលោកនិងខ្សែច្រវាក់តម្លៃនៃផលិតផលកសិកម្មទាំងនេះគឺជាកត្តាកំណត់ប្រព័ន្ធដាំដុះដំណាំក្នុងខេត្តមណ្ឌលគិរីកន្លងមក។

**ខ- សម្បទានដីសេដ្ឋកិច្ច**

ផលិតកម្មកសិកម្មនៅក្នុងខេត្តមណ្ឌលគិរីបង្កើតឡើងក្រោមទម្រង់សំខាន់ចំនួន២ គឺផលិតកម្មកសិកម្មខ្នាតតូចដោយកសិករដែលប្រជាជនធ្វើលើដីរបស់ពួកគាត់និងផលិតកម្មកសិកម្មខ្នាតធំដែលយើងស្គាល់ថាសម្បទានដីសេដ្ឋកិច្ច។ នៅក្នុងខេត្តមណ្ឌលគិរី ទិន្នន័យបានបង្ហាញថា សម្បទានដីសេដ្ឋកិច្ចមានចំនួន២៥ទីតាំងដែលគ្របដណ្តប់លើផ្ទៃដីសរុប១៦២ ៣០៣ហិកតា ក្នុងនោះទីតាំងសម្បទានដីសេដ្ឋកិច្ចចំនួន៧ មានទីតាំងនៅ

តំបន់ការពារធម្មជាតិ គ្របដណ្តប់លើផ្ទៃដី៤៣ ៩៧០ហិកតាស្មើនឹង៤,៧ភាគរយនៃផ្ទៃដីសរុបតំបន់ការពារធម្មជាតិ។ ក្នុងចំណោមសម្បទានដីសេដ្ឋកិច្ចទាំង២៥ ក្នុងខេត្តមណ្ឌលគិរី មានតែទីតាំងសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនចំនួន១៤ដែលបានចុះបញ្ជីជាដីឯកជនរបស់រដ្ឋមានផ្ទៃដី១១០ ៤៣៧ហិកតាស្មើនឹង៦៨ភាគរយនៃផ្ទៃដីសម្បទានដីសេដ្ឋកិច្ចសរុប។ សម្បទានដីសេដ្ឋកិច្ចមានផ្ទៃដីធំនិងមានប្រភេទខុសៗគ្នាផ្អែកលើប្រភេទដំណាំដែលក្រុមហ៊ុនមានបំណងចង់ដាំដុះ។

ចាប់តាំងពីឆ្នាំ២០១២ រាជរដ្ឋាភិបាលបានបញ្ឈប់ការផ្តល់សម្បទានដីសេដ្ឋកិច្ចបន្តទៀត បូករួមជាមួយវិធីសាស្ត្រដែលប្រើប្រាស់នាពេលបច្ចុប្បន្ន ដើម្បីជំរុញការវិនិយោគក្នុងវិស័យកសិកម្ម ដោយផ្តោតលើការអនុវត្តគំរូផលិតកម្មកសិកម្មតាមកិច្ចសន្យាតាមរយៈការផ្សារភ្ជាប់ក្រុមហ៊ុនជាមួយប្រជាកសិករក្នុងទម្រង់ជាច្រើននៃកិច្ចសន្យា។ ការប្រើប្រាស់គំរូកសិកម្មទាំងនេះមានគោលបំណងផ្សារភ្ជាប់ក្រុមហ៊ុននិងកសិករខ្នាតតូច ដើម្បីរួមគ្នាបង្កើតនូវដំណោះស្រាយឈ្នះ ឈ្នះ ដោយក្រុមហ៊ុនអាចផ្តល់បច្ចេកទេសនិងទីផ្សារដល់កសិករ ហើយកសិករផ្តល់មកវិញនូវដីធ្លីរបស់ពួកគេ កម្លាំងពលកម្ម និងចំណេះដឹងក្នុងភាពជាដៃគូ។ ទោះជាយ៉ាងណាក្តី ភាពជាដៃគូដែលផ្តល់អត្ថប្រយោជន៍ឱ្យគ្នាទៅវិញទៅមកនេះក៏នៅពុំទាន់ពេញលេញនិងត្រូវការកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត។

### ២.៣.៥- ការយករ៉ែ

អាជ្ញាបណ្ណមួយចំនួនត្រូវបានរាជរដ្ឋាភិបាលផ្តល់ជូនក្រុមហ៊ុនក្នុងស្រុកនិងក្រុមហ៊ុនអន្តរជាតិ ដើម្បីស្វែងរុករកនិងធ្វើអាជីវកម្មប្រភេទរ៉ែមាសនិងរ៉ែបុកស៊ីត។ ដីដែលបានផ្តល់ក្នុងអាជ្ញាបណ្ណកន្លងមកមានផ្ទៃដីសរុប ២១៣ ៥៣១ហិកតា។ ផ្ទៃដីស្មើនឹងប្រមាណ១៨,២ភាគរយនៃផ្ទៃដីសរុបក្នុងអាជ្ញាបណ្ណគឺសម្រាប់ធ្វើអាជីវកម្ម ប៉ុន្តែប្រសិនបើផ្ទៃដីដែលបានអនុញ្ញាតឱ្យនេះបានធ្វើអាជីវកម្មទាំងអស់វិញនោះនឹងផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងដល់ដីកសិកម្ម គុណភាពទឹកទាំងលើដីនិងក្រោមដី ការកសាងហេដ្ឋារចនាសម្ព័ន្ធ កម្មសិទ្ធិដីធ្លីរបស់កសិករខ្នាតតូច និងព្រៃឈើជាដើមដែលទាំងនេះគួរត្រូវបានពិចារណាច្បាស់លាស់ឡើងវិញសម្រាប់ពេលអនាគត។

### ២.៣.៦- កសិករខ្នាតតូចនិងសុវត្ថិភាពនៃការកាន់កាប់ដីធ្លី

បន្ថែមលើផែនការនៃសហគ្រប់គ្រងនិងកម្មសិទ្ធិសមូហភាពដែលបានរៀបរាប់ខាងលើ ការផ្តល់ប័ណ្ណកម្មសិទ្ធិបានធ្វើឱ្យកសិករខ្នាតតូចទទួលបានសុវត្ថិភាពកាន់កាប់ដីធ្លីលើដីឯកជនរបស់ខ្លួន។ យុទ្ធនាការចុះបញ្ជីដីធ្លីតាមបទបញ្ជាលេខ០១ បានផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជាច្រើនក្នុងចន្លោះឆ្នាំ២០១២ ដល់ឆ្នាំ២០១៣ ហើយដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅបន្តអនុវត្តជាធម្មតា។ មកដល់ឆ្នាំ២០២២ ដីដែលបានចុះបញ្ជីរួចរាល់មានផ្ទៃដីសរុប៣៦៥ ២២៣ហិកតា ក្នុងនោះគិតរួមទាំងផ្ទៃដី៣៦ ០៨៩ហិកតាស្មើនឹង៩,៨៨ភាគរយបានធ្វើឡើងក្នុងយុទ្ធនាការចុះបញ្ជីដីធ្លីតាមបទបញ្ជា០១, ផ្ទៃដីប្រមាណ៥ ៩១៦ហិកតាស្មើនឹង១,៦២ភាគរយបានធ្វើការចុះបញ្ជីតាមកម្មវិធីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ, ផ្ទៃដីប្រមាណ៥ ៥០៦ហិកតាស្មើនឹង១,៥១ភាគរយបានធ្វើការចុះបញ្ជីដាច់ដោយដុំ, ផ្ទៃដីប្រមាណ៨ ៥៧៣ហិកតាស្មើនឹង២,៣៥ភាគរយបានធ្វើការចុះបញ្ជីជាដីសហគមន៍និងស្របពេលផ្ទៃដីប្រមាណ៣០៩ ១៣៩ហិកតាស្មើនឹង៨៤,៦៤ភាគរយបានធ្វើការចុះបញ្ជីជាដីរដ្ឋ។ ទោះជាយ៉ាងនេះក្តី នៅសល់ផ្ទៃដីមួយផ្នែកទៀតដែលមិនទាន់បានចុះបញ្ជី ហើយសិទ្ធិប្រើប្រាស់និងអាស្រ័យផលដីគឺស្ថិតនៅត្រឹមការទទួលស្គាល់របស់អាជ្ញាធរភូមិ ឃុំប៉ុណ្ណោះ។ បទពិសោធន៍កន្លងមកបានបង្ហាញថា សិទ្ធិប្រើប្រាស់របស់កសិករខ្នាតតូចត្រឹមកម្រិតភូមិ ឃុំនេះមានហានិភ័យខ្ពស់ ពិសេសតំបន់គ្របគ្រងដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចនិងតំបន់ដែលបានផ្តល់អាជ្ញាបណ្ណរ៉ែ។

នៅតំបន់ផ្សេងៗទៀតនៃប្រទេសកម្ពុជា បញ្ហាខ្វះដីកសិកម្មនិងមានដីកសិកម្មតិចជាង១ហិកតាគឺមានការដោះស្រាយតាមរយៈគម្រោងសម្បទានដីសង្គមកិច្ច។ សម្បទានដីសង្គមកិច្ចទាក់ទងនឹងយន្តការផ្លូវច្បាប់ដែលផ្ទេរដីកម្មសិទ្ធិឯកជនរបស់រដ្ឋក្នុងគោលដៅសង្គមកិច្ចទៅឱ្យប្រជាពលរដ្ឋក្រីក្រដែលគ្មានដីឬខ្វះខាតដីសម្រាប់ការតាំងលំនៅនិង/ឬសម្រាប់គោលដៅធ្វើកសិកម្មលក្ខណៈគ្រួសារ។ ក្រោមគម្រោងកម្មវិធីសម្បទានដីសង្គមកិច្ចសិទ្ធិភោគៈត្រូវបានផ្តល់ឱ្យអ្នកទទួលយកដីពីគម្រោងរយៈពេលយ៉ាងតិច៥ឆ្នាំ ហើយក្នុងករណីសម្បទានិកបន្តរស់នៅឬធ្វើកសិកម្មលើដីដែលខ្លួនបានទទួលនិងបានអនុវត្តតាមកាតព្វកិច្ចផ្លូវច្បាប់ក្នុងរយៈពេលកាន់កាប់៥ឆ្នាំពួកគាត់អាចដាក់ពាក្យស្នើសុំប្តូរពីសិទ្ធិភោគៈទៅជាម្ចាស់កម្មសិទ្ធិ។ គិតមកដល់ឆ្នាំ២០២០ ខេត្តមណ្ឌលគិរីទទួលបានគម្រោងសម្បទានដីសង្គមកិច្ចចំនួន៥គម្រោងដែលមានផ្ទៃដីសរុប៤ ៨៤៤ហិកតា។ បើប្រៀបធៀបនឹងផ្ទៃដីដែលបានផ្តល់ក្នុងគោលដៅសម្បទានដីសេដ្ឋកិច្ច ផ្ទៃដីនេះស្មើនឹង២ភាគរយនៃផ្ទៃដីសម្បទានដីសេដ្ឋកិច្ចប៉ុណ្ណោះ។

### ២.៤- សេវាកម្មប្រព័ន្ធអេកូឡូស៊ី

ប្រព័ន្ធអេកូឡូស៊ីផ្តល់អត្ថប្រយោជន៍ដ៏មានតម្លៃដល់សង្គមនិងសេដ្ឋកិច្ចនៅថ្នាក់មូលដ្ឋាន។ សេវាកម្មនៃប្រព័ន្ធអេកូឡូស៊ីត្រូវបានចែកជា៤ប្រភេទធំៗ៖

- **សេវាកម្មផ្គត់ផ្គង់** គឺជាផលិតផលដែលទទួលបានពីប្រព័ន្ធអេកូឡូស៊ី រួមមានអាហារ ឱសថ ទឹកសាបជាដើម
- **សេវាកម្មរក្សាលំនឹង** គឺជាអត្ថប្រយោជន៍ដែលទទួលបានពីការកំណត់នៃដំណើរការប្រព័ន្ធអេកូឡូស៊ី រួមមានបទបញ្ជាអាកាសធាតុ ការការពារទឹកជំនន់ ការគ្រប់គ្រងការហូរច្រោះជាដើម
- **សេវាកម្មវប្បធម៌** គឺជាអត្ថប្រយោជន៍មិនមែនជាសម្ភារៈដែលទទួលបានពីប្រព័ន្ធអេកូឡូស៊ី រួមមានអារម្មណ៍ ទីកន្លែង ការផ្តល់ភាពធូរស្បើយខាងវិញ្ញាណ ការកាត់បន្ថយភាពតានតឹង ផលប្រយោជន៍ផ្នែកលម្ហែកម្សាន្តនិងស្មារតីជាដើម
- **សេវាកម្មទ្រទ្រង់** គឺជាសេវាកម្មដែលចាំបាច់សម្រាប់ការផលិតសេវាកម្មប្រព័ន្ធអេកូឡូស៊ីផ្សេងៗទៀត រួមមានជីវៈចម្រុះ ការកែច្នៃសារធាតុចិញ្ចឹមឡើងវិញ ការធ្វើរស្មីសំយោគ ការបង្កើតដីជាដើម។

ធនធានធម្មជាតិដ៏សម្បូរបែបរបស់ខេត្តមណ្ឌលគិរីបានផ្តល់នូវសេវាកម្មប្រព័ន្ធអេកូឡូស៊ីដ៏មានតម្លៃ។ ប៉ុន្តែអត្ថប្រយោជន៍ទាំងនេះទទួលការគំរាមកំហែង ដោយសារការអនុវត្តការប្រើប្រាស់ដីធ្លីមិនមាននិរន្តរភាព ពោលគឺមានការកាប់ទន្ទ្រានព្រៃឈើ ការបំប្លែងដីធ្លី ការធ្វើប្រព័ន្ធកសិកម្មនានាជាដើម។ ការវាយតម្លៃលើសេវាកម្មទាំងនេះនិងកម្រិតដែលធនធានធម្មជាតិទាំងនេះទទួលការគំរាមកំហែងគឺជាកត្តាសំខាន់នៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងផែនការរៀបចំដែនដី។ សំណុំនៃឧបករណ៍អ៊ិនវ៉េស(InVEST) ត្រូវបានប្រើ ដើម្បីកសាងផែនទីបណ្តុំសេវាកម្មប្រព័ន្ធអេកូឡូស៊ីនិងកំណត់តម្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីផ្សេងៗគ្នាដែលស្ថិតក្នុងតំបន់នានានៃខេត្តមណ្ឌលគិរី។ លក្ខណៈរូបវន្តជារួមរបស់ផែនទីនេះបានបញ្ជាក់អំពីកត្តាគុណតម្លៃនិងរបាយសេវាកម្មផ្សេងៗគ្នានៅទូទាំងខេត្តមណ្ឌលគិរី ពោលគឺការផ្ទុកកាបូននិងផលិតផលអនុផលព្រៃឈើ។

ដើម្បីស្វែងយល់អំពីកត្តាជំរុញនិងកត្តាចម្បងដែលគំរាមកំហែងដល់ការផ្តល់សេវាកម្មប្រព័ន្ធអេកូឡូស៊ីចាំបាច់ត្រូវធ្វើការប្រៀបធៀបដោយដាក់ឱ្យត្រួតស៊ីគ្នារវាងផែនទីសេវាកម្មប្រព័ន្ធអេកូឡូស៊ីនិងផែនទីបង្ហាញពីការផ្លាស់ប្តូរគម្របដីចន្លោះឆ្នាំ១៩៩៩ ដល់ឆ្នាំ២០១៩ និងប្រព័ន្ធកាន់កាប់ដីធ្លីសំខាន់ៗ។ ទីតាំងសំខាន់ៗនៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីចំនួន៤កន្លែងត្រូវបានកត់សម្គាល់៖

១- ទីតាំងនេះមានការផ្តល់សេវាកម្មប្រព័ន្ធអេកូឡូស៊ីខ្ពស់ ប៉ុន្តែមានការគំរាមកំហែងដោយសម្បទានដីសេដ្ឋកិច្ច ការឈូសឆាយដីសម្រាប់កសិកម្មក្នុងទ្រង់ទ្រាយធំ និងការប្រឈមនឹងការរេចរឹលព្រៃឈើដែលបង្កដោយសកម្មភាពស្វែងរករ៉ែបុកស៊ីត។ កិច្ចខិតខំប្រឹងប្រែងការពារព្រៃឈើក្នុងដែនជម្រកសត្វព្រៃភ្នំណាមលៀរគឺជាមធ្យោបាយដ៏សំខាន់មួយក្នុងការធានាការការពារព្រៃឈើនិងការផ្តល់សេវាកម្មប្រព័ន្ធអេកូឡូស៊ីប្រកបដោយនិរន្តរភាពបន្ថែមទៀត។

២- ទីតាំងដែលមានការកាប់ទន្ទ្រានព្រៃឈើយ៉ាងច្រើនផងដែរគឺស្ថិតនៅភាគនិរតីនៃស្រុកកែវសីមា ហើយការផ្លាស់ប្តូរការប្រើប្រាស់ដីភាគច្រើនបណ្តាលមកពីកសិករខ្នាតតូចនិងសម្បទានដីសេដ្ឋកិច្ច។ ដូចគ្នានឹងករណីមុនដែរ កិច្ចខិតខំប្រឹងប្រែងការពារព្រៃឈើនៅក្នុងដែនជម្រកសត្វព្រៃកែវសីមាមានសារៈសំខាន់ណាស់ ដើម្បីថែរក្សាសេវាកម្មប្រព័ន្ធអេកូឡូស៊ីក្នុងរយៈពេលវែង។

៣- នៅភាគឦសាននៃខេត្តមណ្ឌលគិរី កន្លែងផ្តល់សេវាកម្មប្រព័ន្ធអេកូឡូស៊ីមួយផ្សេងទៀតរងការគំរាមកំហែង ដោយសារការឈូសឆាយដីពង្រីកផលិតកម្មកៅស៊ូលើសម្បទានដីសេដ្ឋកិច្ច។ម្យ៉ាងទៀត តំបន់ព្រៃឈើដែលមានទីតាំងស្ថិតនៅក្នុងដែនជម្រកសត្វព្រៃលំផាត់បានផ្តល់សេវាកម្មប្រព័ន្ធអេកូឡូស៊ីតម្លៃខ្ពស់។ ការអភិរក្សព្រៃឈើបានល្អពីមុនមកមានន័យថា សេវាកម្មប្រព័ន្ធអេកូឡូស៊ីនៅតំបន់នោះក៏បានការពារយ៉ាងល្អដែរ។

៤- តំបន់សំខាន់នៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីមានការគំរាមកំហែងដោយសារការកាប់ទន្ទ្រានព្រៃឈើដើម្បីពង្រីកដីកសិកម្មនិងស្វែងរុករករ៉ែនានា។

## ២.៥- ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

### ២.៥.១- បណ្តាញផ្លូវ

បណ្តាញផ្លូវថ្នល់គឺជាសមាសធាតុសំខាន់ក្នុងផែនការរៀបចំដែនដី។ ខេត្តមណ្ឌលគិរីជាខេត្តសំខាន់មួយនៃតំបន់អភិវឌ្ឍន៍ត្រីកោណកម្ពុជា- ឡាវ- វៀតណាម ហើយអាចចាត់ទុកថា ទីតាំងយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍក្នុងតំបន់។ បណ្តាញផ្លូវថ្នល់ក្នុងខេត្តមណ្ឌលគិរីត្រូវបានកសាងនិងពង្រីកបន្ថែមគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ជារួមដង់ស៊ីតេបណ្តាញផ្លូវថ្នល់មានកម្រិតខ្ពស់ជាងមុន។ ផែនការមេអភិវឌ្ឍន៍បណ្តាញផ្លូវថ្នល់ ឆ្នាំ២០០៦ គឺជាឯកសារគោលនយោបាយជាយុទ្ធសាស្ត្រដ៏សំខាន់ ដើម្បីតម្រង់ទិសអភិវឌ្ឍន៍បណ្តាញផ្លូវថ្នល់ក្នុងប្រទេសកម្ពុជា។

ទន្ទឹមនឹងនេះ នៅឆ្នាំ២០១៤ រាជរដ្ឋាភិបាលបានដាក់ចេញនូវច្បាប់ស្តីពីផ្លូវថ្នល់ដែលសំដៅធ្វើការគ្រប់គ្រងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងការធានាបាននូវសុវត្ថិភាពចរាចរណ៍ក្នុងប្រទេស។ ច្បាប់នេះក៏ផ្តោតលើការពង្រឹងកិច្ចសហប្រតិបត្តិការនិងការធ្វើសមាហរណកម្មថ្នាក់ជាតិ តាមតំបន់ ថ្នាក់ក្រោមជាតិ និងកិច្ចសហប្រតិបត្តិការថ្នាក់អន្តរជាតិនៅក្នុងវិស័យអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផងដែរ។ បណ្តាញហេដ្ឋារចនាសម្ព័ន្ធមានសារៈសំខាន់ណាស់ ព្រោះវាដើរតួជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងចរាចរណ៍ពាណិជ្ជកម្ម ព្រមទាំងដើរតួជាមធ្យោបាយចាំបាច់សម្រាប់មនុស្សធ្វើដំណើរទៅកាន់គោលដៅផ្សេងៗ។ ច្បាប់នេះក៏បានកំណត់យ៉ាងច្បាស់លាស់នូវគម្លាតជាក់លាក់ពីអ័ក្សផ្លូវទៅកាន់ក្បាលដីឬទ្រព្យសម្បត្តិឯកជន ដោយសារតែមានការចូលមកតាំងទីលំនៅតាមបណ្តោយផ្លូវថ្នល់។ ជារួមច្បាប់ស្តីពីផ្លូវថ្នល់ផ្តល់មូលដ្ឋានយ៉ាងសំខាន់សម្រាប់ការកសាងផែនការរៀបចំដែនដីនិងផែនការអភិវឌ្ឍន៍ផ្សេងៗទៀត ដោយកំណត់ឱ្យមានការត្រៀមបម្រុងទុកដីចំណីផ្លូវនិងដីសម្រាប់សំណង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ជាដើម។

ទោះជាយ៉ាងណាក៏ដោយ ការពង្រីកបណ្តាញផ្លូវថ្នល់តែងនាំឱ្យមានផលប៉ះពាល់នានា។ ផ្លូវតភ្ជាប់ពីកន្លែងមួយទៅកន្លែងមួយទៀតនឹងធ្វើឱ្យមានការបន្លាស់ទីរបស់មនុស្សនិងទំនិញ ហើយក៏ជំរុញឱ្យមានមនុស្សមករស់នៅដែរ រួមទាំងអ្នកចំណាកស្រុក ការតាំងលំនៅនៅតាមដងផ្លូវជាដើម។ កត្តាទាំងនេះបង្កឱ្យមានការផ្លាស់ប្តូរការប្រើប្រាស់ដី។ បទពិសោធនៅក្នុងខេត្តមណ្ឌលគិរីកន្លងមកបានបង្ហាញថា គម្របព្រៃឈើបានបាត់បង់នៅពេលដែលហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ត្រូវបានពង្រីក ហើយនាំឱ្យជះឥទ្ធិពលអវិជ្ជមានដល់ជីវៈចម្រុះនិងសត្វព្រៃ។ ក្នុងន័យនេះ ការថ្លឹងថ្លែងរវាងការអភិវឌ្ឍនិងការអភិរក្សធនធានធម្មជាតិត្រូវតែពិចារណាឱ្យបានហ្មត់ចត់ ដើម្បីនិរន្តរភាពបរិស្ថាន។

### ២.៥.២- អគ្គិសនី

ខេត្តមណ្ឌលគិរីមានរោងចក្រអគ្គិសនីប្រើប្រេងឥន្ធនៈខ្នាតតូចចំនួន២កន្លែងដែលកន្លែងនីមួយៗមានកម្លាំង១៨៥គីឡូវ៉ុល ហើយមានម៉ាស៊ីនភ្លើងចំនួន១គ្រឿងនៅក្រុងសែនមនោរម្យដែលអាចផលិតថាមពលអគ្គិសនីមានកម្លាំង៣០០ជីកាវ៉ាត់។ បន្ថែមលើនេះ ខេត្តមណ្ឌលគិរីក៏បានទិញថាមពលអគ្គិសនីមានកម្លាំង២មេហ្គាវ៉ុលបន្ថែមពីប្រទេសវៀតណាមដែលឆ្លងកាត់តាមច្រកព្រំដែនដាក់ដាំសម្រាប់ផ្គត់ផ្គង់ក្នុងស្រុកអូររាំងនិងតាមច្រកព្រំដែនឡាប៉ាខេសម្រាប់ផ្គត់ផ្គង់ក្នុងស្រុកកែវសីមា។ ខេត្តមណ្ឌលគិរីក៏មានតំបន់ជាច្រើន ដូចជាទន្លេ ស្ទឹង ភ្នំ ខ្ពង់រាប និងជ្រលងភ្នំដែលមានសក្តានុពលសម្រាប់កសាងវារីអគ្គិសនីខ្នាតធំ ខ្នាតមធ្យម និងខ្នាតតូចនាពេលអនាគត។

ដូចករណីការពង្រីកបណ្តាញផ្លូវថ្នល់ដែរ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីក៏ជះឥទ្ធិពលដល់ប្រព័ន្ធអេកូឡូស៊ីដែរ។ ការស្ថាបនាបណ្តាញខ្សែអគ្គិសនីឬប្រតិបត្តិការទំនប់វារីអគ្គិសនីបណ្តាលឱ្យមានការឈូសឆាយកាប់ឆ្ការព្រៃឈើនិងការរំខាននានា ដូចជារំញ័រនិងសំឡេងរំខានជាដើមដែលជះឥទ្ធិពលដល់រចនាសម្ព័ន្ធទ្រទ្រង់មុខងារ និងការទាញយកផលផ្សេងៗពីប្រព័ន្ធព្រៃឈើដែលកត្តាទាំងនេះត្រូវថ្លឹងថ្លែងនៅក្នុងការកសាងផែនការរៀបចំដែនដី។

## ២.៦- ប្រជាសាស្ត្រ

ការសិក្សាវិភាគគ្រប់ខ័ណ្ឌប្រជាសាស្ត្រសម្រាប់ការកសាងផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីគឺផ្អែកលើទិន្នន័យស្ថិតិឃុំ/សង្កាត់ជាមូលដ្ឋាន ព្រមទាំងទិន្នន័យជំរឿនប្រជាជនឆ្នាំ១៩៩៨ ឆ្នាំ២០០៨ និងឆ្នាំ២០១៩ ក៏ត្រូវបានយកមកប្រើប្រាស់ ដើម្បីការវិភាគតាមករណីចាំបាច់។

ក្នុងឆ្នាំ២០១៩ ខេត្តមណ្ឌលគិរីមានប្រជាជនសរុបចំនួន៩០ ៩៤៩នាក់ដែលជាខេត្តមានចំនួនប្រជាជនតិចជាងគេក្នុងប្រទេសកម្ពុជា។ ខេត្តមណ្ឌលគិរីមានដង់ស៊ីតេប្រជាជនត្រឹម៦,០៣នាក់/គីឡូម៉ែត្រក្រឡា ហើយក៏ជាចំនួនដង់ស៊ីតេតិចជាងគេក្នុងប្រទេសកម្ពុជាដែរ។ ក្រុងសែនមនោរម្យមានដង់ស៊ីតេប្រជាជនច្រើនជាងគេនៅក្នុងខេត្តមណ្ឌលគិរី គឺ២៦,៤នាក់/គីឡូម៉ែត្រក្រឡា។ យោងតាមទិន្នន័យស្ថិតិឃុំ/សង្កាត់ កំណើនប្រជាសាស្ត្រក្នុងទសវត្សរ៍ចុងក្រោយ គឺ៤,៥៦ភាគរយក្នុងមួយឆ្នាំ ហើយមានភាពខុសៗគ្នាទៅតាមស្រុក ដូចជាស្រុកកោះញែកមានកំណើនតិចជាងគេ គឺ៣,៣៦ភាគរយក្នុងមួយឆ្នាំ និងស្រុកពេជ្រាដាមានកំណើនច្រើនជាងគេ គឺ៦,៦៩ភាគរយក្នុងមួយឆ្នាំ។ អត្រាកំណើនប្រជាសាស្ត្រខេត្តមណ្ឌលគិរីមានការថយចុះពីមួយឆ្នាំទៅមួយឆ្នាំ។ ទោះបីជាយ៉ាងណាក្តី កំណើនប្រជាជនទូទៅនៅក្នុងខេត្តមណ្ឌលគិរីនៅតែខ្ពស់ដដែល ហើយខ្ពស់ជាងកំណើនមធ្យមថ្នាក់ជាតិដែលមាន

ត្រឹម១,២ភាគរយរវាងឆ្នាំ២០០៨ និងឆ្នាំ២០១៩។ ចំនួនសមាជិកជាមធ្យមក្នុងមួយគ្រួសារក្នុងខេត្តមណ្ឌលគិរីបានធ្លាក់ចុះពី៤,៥ទៅ៤,២នាក់ក្នុងចន្លោះឆ្នាំ២០០៩ ដល់ឆ្នាំ២០១៩ ហើយសមាមាត្រភេទបានផ្លាស់ប្តូរពី១,០០ទៅ១,០៦ដែលបានបង្ហាញថា ចំនួនបុរសមាននិន្នាការកើនឡើងលឿនជាងចំនួនស្ត្រី។

គួរកត់សម្គាល់ជាងនេះទៀត សមាមាត្រងករាជ្យ(សមាមាត្ររវាងប្រជាជនអសកម្មនិងប្រជាជនសកម្ម) បានធ្លាក់ចុះពី០,៨៤ដល់០,៧១ ក្នុងចន្លោះឆ្នាំ២០០៩និងឆ្នាំ២០១៩ដែលមានន័យថា ចំនួនប្រជាជនដែលមានអាយុអាចធ្វើការបានកើនឡើង បើប្រៀបធៀបទៅនឹងចំនួនប្រជាជនក្រោមអាយុធ្វើការ។ ការផ្លាស់ប្តូររចនាសម្ព័ន្ធអាយុគឺជាចំណុចដ៏សំខាន់និងមានសក្តានុពលសម្រាប់កំណើនសេដ្ឋកិច្ចរបស់ខេត្តមណ្ឌលគិរី។

ទន្ទឹមនឹងនេះ ខេត្តមណ្ឌលគិរីមានភាពលេចធ្លោចំពោះការធ្វើចំណូលស្រុក។ អត្រាការធ្វើចំណូលស្រុកក្នុងខេត្តមណ្ឌលគិរីមានចាប់ពី២,២ទៅ២៣,៣ភាគរយគឺច្រើនជាងកម្រិតថ្នាក់ជាតិដែលមានត្រឹម០,៨៦ភាគរយ។ ការធ្វើចំណូលស្រុកបង្កឡើងដោយសារការស្វែងរកដីធ្វើកសិកម្ម។ ចំពោះប្រជាកសិករទូទាំងប្រទេស ពិសេសអ្នកដែលរស់នៅតំបន់ទំនាប ការធ្វើចំណាកស្រុករបស់ពួកគេទៅកាន់តំបន់ខ្ពង់រាប ដើម្បីស្វែងរកឱកាសសេដ្ឋកិច្ចដោយសារបញ្ហាកង្វះដីសម្រាប់ធ្វើកសិកម្មនិងកង្វះការងារ។ ជាក់ស្តែងការពង្រីកដីកសិកម្មក្នុងខេត្តមណ្ឌលគិរីបានកើតឡើងដោយសារមានចលនាធ្វើចំណូលស្រុក។ វត្តមានរបស់អ្នកចំណូលស្រុកបានផ្តល់សក្តានុពលសម្រាប់ការអភិវឌ្ឍខេត្ត ប៉ុន្តែក៏បានផ្តល់សម្ពាធមកលើធនធានព្រៃឈើនិងផ្ទៃដីកសិកម្មផងដែរដែលតម្រូវឱ្យមានការរៀបចំលិខិតបទដ្ឋានគតិយុត្តនិងការគ្រប់គ្រងឱ្យបានត្រឹមត្រូវ។

គួរកត់សម្គាល់ផងដែរ ការធ្វើចំណូលស្រុកបានធ្វើឱ្យមានការផ្លាស់ប្តូរសមាមាត្រនៃជនជាតិដើមភាគតិចនៅខេត្តមណ្ឌលគិរី។ ក្នុងឆ្នាំ២០០៩ ជនជាតិដើមភាគតិចស្មើនឹង៥១ភាគរយបានថយចុះមកត្រឹម៤៤ភាគរយនៃប្រជាជនសរុបខេត្តមណ្ឌលគិរីក្នុងឆ្នាំ២០១៩។ ផ្ទុយទៅវិញ ប្រជាជនដែលជាជនជាតិខ្មែរនិងខ្មែរអ៊ីស្លាមស្មើនឹងត្រឹម៤៦ភាគរយនៅឆ្នាំ២០០៩ បានកើនរហូតដល់៥៣ភាគរយនៃប្រជាជនសរុបខេត្តមណ្ឌលគិរីនៅឆ្នាំ២០១៩។ មូលហេតុនៃការផ្លាស់ប្តូរនេះ ដោយសារចំនួនដ៏ច្រើននៃអ្នកចំណូលស្រុកគឺជាជនជាតិខ្មែរឬខ្មែរអ៊ីស្លាម។ ការហូរចូលនៃអ្នកចំណាកស្រុកបានដាក់សម្ពាធបន្ថែមទៅលើក្រុមជនជាតិដើមភាគតិចដែលជាក្រុមងាយរងគ្រោះដោយសារគោលយោបាយរបស់រដ្ឋក្នុងការធ្វើទំនើបកម្មព្រៃឈើនិងកសិកម្មជាដើម។

### ២.៧- ការផ្តល់សេវាសង្គម

ហេដ្ឋារចនាសម្ព័ន្ធសង្គមគឺជាផ្នែកមួយដ៏សំខាន់ក្នុងផែនការរៀបចំដែនដី ពិសេសទាក់ទងនឹងវិស័យសុខាភិបាលនិងវិស័យអប់រំ។ ការរៀបចំសេវាសុខាភិបាលនៅក្នុងភូមិសាស្ត្រខេត្តនីមួយៗមានទម្រង់ខុសៗគ្នាតាមកម្រិតរដ្ឋបាលខេត្ត ស្រុក និងឃុំ។ ស្រុកមួយចំនួនត្រូវប្រមូលផ្តុំបង្កើតជាស្រុកប្រតិបត្តិ ដើម្បីបង្កលទ្ធភាពផ្តល់នូវសេវាសុខាភិបាលសម្រាប់ប្រជាជន។ ស្រុកប្រតិបត្តិនីមួយៗមានមន្ទីរពេទ្យបង្អែកមួយដែលអាចបម្រើសេវាជូនប្រជាជនយ៉ាងតិច៥០ ០០០នាក់និងមណ្ឌលសុខភាពសម្រាប់ប្រជាជនយ៉ាងតិច៥ ០០០នាក់។ ខេត្តមណ្ឌលគិរីមានស្រុកប្រតិបត្តិតែមួយប៉ុណ្ណោះ រួមទាំងអតីតមន្ទីរពេទ្យស្រុកចំនួន៣និងមណ្ឌលសុខភាពចំនួន៣។ ទោះជាយ៉ាងណាក៏ដោយ ដោយសារមានចលនានៃការធ្វើចំណូលស្រុកនិងការតាំងលំនៅរាយប៉ាយក្នុងខេត្តមណ្ឌលគិរីដែលមានសន្ទឹងធំទូលាយ នាំឱ្យមានការលំបាកក្នុងការផ្តល់សេវាកម្មឱ្យបានពេញលេញ។

រីឯសម្រាប់វិស័យអប់រំ ខេត្តមណ្ឌលគិរីមានសាលាបឋមសិក្សាច្រើនជាងអនុវិទ្យាល័យនិងវិទ្យាល័យ។ ខណៈអាយុរបស់សិស្សកើនឡើង ចម្ងាយជាមធ្យមទៅកាន់សាលារៀនសម្រាប់សិស្សថ្នាក់ខ្ពស់គឺឆ្ងាយជាងសិស្សថ្នាក់ទាប។ ការធ្វើដំណើររបស់សិស្សទៅអនុវិទ្យាល័យនិងវិទ្យាល័យគឺជាបញ្ហាចម្បងនៅក្នុងតំបន់មួយចំនួន ដូចជានៅភាគពាយ័ព្យនៃស្រុកកែវសីមានិងស្រុកកោះញែក។

## ២.៨- ការងារ

រចនាសម្ព័ន្ធការងារនៅខេត្តមណ្ឌលគិរីបានឆ្លុះបញ្ចាំងពីភាពលេចធ្លោនៃការប្រើប្រាស់ដីពាក់ព័ន្ធនឹងព្រៃឈើនិងកសិកម្ម។ ចំនួន៨២ភាគរយនៃបុរសនិងស្ត្រីដែលមានអាយុចាប់ពី១៨ឆ្នាំឡើងប្រកបមុខរបរក្នុងវិស័យកសិកម្មជាមុខរបរចម្បង។ ចំនួន១៥ភាគរយផ្សេងទៀតប្រកបមុខរបរក្នុងវិស័យសេវាកម្ម ហើយភាគច្រើនជាកម្មករស៊ីឈ្នួល។ ប្រសិនបើយើងពិនិត្យមើលលើប្រភេទមុខរបរបន្ទាប់បន្សំវិញនោះគឺចំនួន៦៨ភាគរយនៃប្រជាពលរដ្ឋប្រកបរបរក្នុងវិស័យកសិកម្ម។ នេះមានន័យថា នៅខេត្តមណ្ឌលគិរីសមាមាត្រប្រជាជនភាគច្រើនកំពុងរស់នៅដោយផ្សារភ្ជាប់ជាមួយដីកសិកម្ម។ ចំនួន២៥ភាគរយផ្សេងទៀតគឺពឹងផ្អែកលើអនុផលព្រៃឈើឬនេសាទជាមុខរបរបន្ទាប់បន្សំដែលអាចនិយាយបានថា ការងារចម្រុះមានរួមបញ្ចូលការងារកសិកម្មនិងការប្រមូលផលពីធនធានធម្មជាតិ។ ការពឹងផ្អែកលើកសិកម្មជាមុខរបរចម្បងគឺមានទូទាំងខេត្តមណ្ឌលគិរី ប៉ុន្តែឃុំសង្កាត់ស្ថិតនៅក្បែរឬជាមជ្ឈមណ្ឌលទីប្រជុំជនសំខាន់ៗ មានរចនាសម្ព័ន្ធការងារចម្រុះ និងមានប្រជាពលរដ្ឋធ្វើការក្នុងវិស័យសេវាកម្មច្រើនគឺនៅក្រុងសែនមនោរម្យ ស្រុកកោះញែក និងស្រុកកែវសីមា។

## ២.៩- សមាសធាតុសំខាន់ៗនៃទម្រង់ការរៀបចំដែនដី

### ២.៩.១- បណ្តាញទំនាក់ទំនងក្នុងតំបន់និងបណ្តាញផ្លូវថ្នល់

ខេត្តមណ្ឌលគិរីគឺជាខេត្តមួយក្នុងចំណោមខេត្តទាំងបួននៃព្រះរាជាណាចក្រកម្ពុជាដែលស្ថិតក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម និងមានព្រំប្រទល់ជាប់នឹងខេត្តដាក់ណុង ខេត្តប៊ិញភឿក និងខេត្តដាក់ឡាក់នៃប្រទេសវៀតណាម។ ខេត្តមណ្ឌលគិរីអាចនឹងទទួលផលយ៉ាងច្រើនពីគំនិតផ្តួចផ្តើមក្នុងការអភិវឌ្ឍតំបន់ត្រីកោណអភិវឌ្ឍន៍នេះ។ ផែនការមេនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៃតំបន់ត្រីកោណអភិវឌ្ឍន៍ ឆ្នាំ២០០៤ បានផ្តល់អាទិភាពដល់គម្រោងអភិវឌ្ឍជាច្រើននៅក្នុងតំបន់ រួមមានហេដ្ឋារចនាសម្ព័ន្ធ កសិកម្ម ជលផល ព្រៃឈើ សេវាកម្ម ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា ការការពារបរិស្ថាននិងការគ្រប់គ្រងដីធ្លីប្រកបដោយប្រសិទ្ធភាព ការរក្សាសន្តិសុខ និងការការពារជាតិនិងតំបន់ ព្រមទាំងការសម្រួលដល់ការវិនិយោគនានា។ ទោះជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍសេវាកម្មនានា រួមមានឧស្សាហកម្មទេសចរណ៍មិនទាន់បានឆ្លើយតបទៅនឹងសក្តានុពលនៃខេត្តនៅឡើយ។

បណ្តាញផ្លូវនិងហេដ្ឋារចនាសម្ព័ន្ធ ប្រៀបដូចជាសរសៃឈាមនៃការអភិវឌ្ឍលើគ្រប់វិស័យនិងកំណើនសេដ្ឋកិច្ច និងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននិងជួយសម្រួលដល់ការធ្វើពាណិជ្ជកម្ម ការដឹកជញ្ជូនទំនិញ និងសេវាកម្ម ក៏ដូចជាលើកកម្ពស់វិស័យទេសចរណ៍ ការអភិវឌ្ឍជនបទ និងជំរុញការធ្វើសមាហរណកម្មទីផ្សារក្នុងតំបន់និងពិភពលោក។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផ្តោតលើសារៈសំខាន់នៃប្រព័ន្ធដឹកជញ្ជូននិងលើកកម្ពស់ការដឹកជញ្ជូន ថាមពល ប្រព័ន្ធឌីជីថល ដើម្បីគាំទ្រដល់ការអភិវឌ្ឍ

សេដ្ឋកិច្ចនិងការធ្វើពិពិធកម្មកសិកម្ម ការធ្វើឱ្យមានតុល្យភាពនៃការអភិវឌ្ឍ ការផ្សារភ្ជាប់តម្លាតរវាងការអភិវឌ្ឍជនបទនិងទីក្រុង ការរក្សាល្បឿនជាមួយការផ្លាស់ប្តូរក្នុងតំបន់និងពិភពលោក និងការទទួលបានអត្ថប្រយោជន៍អតិបរមាពីការរីកចម្រើនបច្ចេកវិទ្យានិងសេដ្ឋកិច្ចឌីជីថល ពិសេស ក្នុងបរិបទឧស្សាហកម្មជំនាន់ទី៤។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក៏បានសង្កត់ធ្ងន់លើប្រសិទ្ធភាពនៃការគ្រប់គ្រង ការការពារ ការអភិរក្សធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ី និងការបន្សាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុផងដែរ។ ក្នុងន័យនេះ ការអភិវឌ្ឍបណ្តាញផ្លូវនិងហេដ្ឋារចនាសម្ព័ន្ធក្នុងខេត្តមណ្ឌលគិរីមិនអាចមើលរំលងលើភាពសម្បូរបែបនៃធនធានធម្មជាតិនិងជីវៈចម្រុះបានឡើយ។

ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការផ្សារភ្ជាប់ប្រទេសទៅក្នុងតំបន់ ពិសេសជាមួយប្រទេសជិតខាងត្រូវបានគិតគូរជាយូរមកហើយ ដូចជាការអភិវឌ្ឍតាមច្រករបៀងនិងតាមតំបន់ព្រំដែនជាដើម។ រាជរដ្ឋាភិបាលក៏បានធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តដទៃទៀត ដើម្បីទ្រទ្រង់រាល់សកម្មភាពសេដ្ឋកិច្ចជាតិតាមរយៈការកែលម្អនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដូចជាផ្លូវជនបទ កំពង់ផែ ផ្លូវដែក ផ្លូវអាកាស និងហេដ្ឋារចនាសម្ព័ន្ធទីក្រុងផ្សេងៗទៀត។ សម្រាប់វិស័យឡូជីស្ទិក ចំណាត់ថ្នាក់របស់ប្រទេសកម្ពុជាត្រូវបានកែលម្អគួរឱ្យកត់សម្គាល់ដែលមានចំណាត់ថ្នាក់នៅលេខរៀងទី១២៩ ក្នុងឆ្នាំ២០១០ មកនៅទី៩៨ ក្នុងឆ្នាំ២០១៨ តាមសន្ទស្សន៍នៃការអនុវត្តការងារឡូជីស្ទិករបស់ធនាគារពិភពលោក។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក៏បានចង្អុលបង្ហាញពីបញ្ហាប្រឈមចម្បងៗរបស់ប្រទេសកម្ពុជានៅក្នុងវិស័យមួយចំនួន រួមមានថ្លៃដើមដឹកទំនិញខ្ពស់ ចំណុចខ្វះខាតរបស់ស្ថាប័នក្នុងការសម្របសម្រួល ដើម្បីការអភិវឌ្ឍនិងការថែទាំហេដ្ឋារចនាសម្ព័ន្ធ ហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់ក្នុងការឆ្លើយតបនឹងតម្រូវការនៅក្នុងដំណាក់កាលថ្មីនៃការអភិវឌ្ឍ និងកង្វះខាតការគិតគូរពីទីតាំងសហគ្រាសឬរោងចក្រទៅតាមផែនការនៃការអភិវឌ្ឍទីក្រុងនិងការគ្រប់គ្រងដីធ្លីនៅអំឡុងពេលរៀបចំផែនការនិងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធជាដើម។

ផែនការមេអភិវឌ្ឍន៍បណ្តាញផ្លូវ ឆ្នាំ២០០៩ ជាឯកសារគោលនយោបាយដ៏សំខាន់សម្រាប់វិស័យដឹកជញ្ជូននិងឯកសារយោងសម្រាប់វិស័យផ្សេងទៀត ដូចជាពាណិជ្ជកម្ម ទេសចរណ៍ កសិកម្ម និងនគរូបនីយកម្ម។ ដូច្នេះ ផែនការមេនេះក៏ជាឯកសារគន្លឹះ ដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណនិងគោលនយោបាយផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល។ យុទ្ធសាស្ត្រចំនួន៦ ត្រូវបានកំណត់ក្នុងផែនការមេនេះ ដើម្បីសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍បណ្តាញផ្លូវ រួមមាន ១)ការលើកកម្ពស់ប៉ូលអភិវឌ្ឍពហុវិស័យ ២)ការធ្វើសមាហរណកម្មជាតិ ៣)ការអភិវឌ្ឍច្រករបៀងអន្តរជាតិសម្រាប់សមាហរណកម្មតំបន់កម្ពុជា ៤)ការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ពិសេសការអភិវឌ្ឍវិស័យកសិកម្ម ដើម្បីកាត់បន្ថយភាពក្រីក្រនៅជនបទ ៥)ការពង្រឹងការអភិវឌ្ឍសេដ្ឋកិច្ចនិងរបៀងកំណើន និង ៦)ការលើកកម្ពស់ការអភិវឌ្ឍទេសចរណ៍។ ផែនការមេនេះក៏បានលើកឡើងពីតម្រូវការផ្លូវក្នុងតំបន់ដាច់ស្រយាល ដើម្បីលើកកម្ពស់វិស័យឧស្សាហកម្មជនបទ ការពង្រីកការវិនិយោគ ក៏ដូចជាការបង្កើនឱកាសការងារ ស្របពេលដែលខេត្តមណ្ឌលគិរីក៏ត្រូវបានកំណត់នៅក្នុងបរិបទនេះផងដែរ។ យុទ្ធសាស្ត្រដែលហៅថា ការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចជនបទសម្រាប់ការកាត់បន្ថយភាពក្រីក្រ(យុទ្ធសាស្ត្រទី៤)មានគោលបំណងដាក់បញ្ចូលនិងទាក់ទាញការវិនិយោគ ដើម្បីធ្វើឱ្យខេត្តមណ្ឌលគិរីនឹងប្រែក្លាយទៅជាប៉ូលសមាហរណកម្មអនុតំបន់។

ទិដ្ឋភាពពាក់ព័ន្ធមួយទៀតនៃផែនការមេអភិវឌ្ឍន៍បណ្តាញផ្លូវគឺការកំណត់យកខេត្តមណ្ឌលគិរីជាខេត្តស្នូលនៃតំបន់ ដើម្បីលើកកម្ពស់វិស័យទេសចរណ៍ រួមជាមួយរាជធានីភ្នំពេញ សៀមរាប ព្រះវិហារ និងតំបន់ឆ្នេរសមុទ្រ(យុទ្ធសាស្ត្រទី៦)។ ប្រព័ន្ធអេកូឡូស៊ីលក្ខណៈចម្រុះនិងវប្បធម៌សម្បូរបែបនៃសហគមន៍ជនជាតិដើមក្នុងខេត្តមណ្ឌលគិរីគឺជាទ្រព្យដ៏សំខាន់សម្រាប់ការលើកកម្ពស់សមាហរណកម្មក្នុងការអភិវឌ្ឍវិស័យអេកូទេសចរណ៍ ដោយទទួលបានអត្ថប្រយោជន៍ពីមធ្យោបាយក្នុងការធ្វើដំណើរក្នុងតំបន់។ ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីដើរតួយ៉ាងសំខាន់ក្នុងការតម្រង់ទិសសម្រាប់ធ្វើសមាហរណកម្មវិស័យផ្សេងៗ ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍរយៈពេលវែងរបស់ខេត្តនិងរាជរដ្ឋាភិបាល។

### ២.៩.២- ប្រព័ន្ធប្រើប្រាស់ដី

ការកំណត់ប្រព័ន្ធប្រើប្រាស់ដីមានសារៈសំខាន់ក្នុងការសំយោគព័ត៌មានអំពីការប្រើប្រាស់ដី ការប្រែប្រួលគម្របដី និងវិធាននៃការគ្រប់គ្រងដីដែលមានកន្លងមក។ ហេតុនេះ ប្រព័ន្ធប្រើប្រាស់ដីគឺជាកិច្ចការចាំបាច់ក្នុងរចនាសម្ព័ន្ធដែនដីនៃខេត្តមណ្ឌលគិរី។ ព័ត៌មានអំពីការប្រើប្រាស់ដីដែលទទួលបានមានសារៈប្រយោជន៍សម្រាប់ការវិភាគដែលទាក់ទងនឹងរចនាសម្ព័ន្ធពហុមជ្ឈមណ្ឌលទីក្រុងឬទីប្រជុំជន ប៉ូលអភិវឌ្ឍសេដ្ឋកិច្ច និងបណ្តាញដឹកជញ្ជូន។ ប្រព័ន្ធប្រើប្រាស់ដីចំនួន៥ប្រភេទត្រូវបានកំណត់សម្រាប់ខេត្តមណ្ឌលគិរី រួមមានតំបន់អភិរក្ស តំបន់ការពារធម្មជាតិមានការគ្រប់គ្រងរួមគ្នា តំបន់កសិឧស្សាហកម្មខ្នាតធំ(សម្បទានដីសេដ្ឋកិច្ច) តំបន់កសិកម្មខ្នាតតូច(កម្រិតខ្ពស់) និងតំបន់កសិកម្មខ្នាតតូច(កម្រិតទាប)។

ការប្រើប្រាស់ដី "**តំបន់អភិរក្ស**" រួមមានតំបន់ស្នូលនិងតំបន់អភិរក្សដែលស្ថិតនៅក្នុងប្រព័ន្ធក្នុងតំបន់ការពារធម្មជាតិ។ តំបន់នេះអាចមានប្រជាជនចូលទៅ ដើម្បីប្រមូលអនុផលព្រៃឈើសម្រាប់ចិញ្ចឹមជីវិត ហើយភាគច្រើនតំបន់នេះគ្មានមនុស្សរស់នៅគឺសម្រាប់តែសត្វព្រៃប៉ុណ្ណោះ។ ប្រភេទការប្រើប្រាស់ដីសំខាន់ក្នុងតំបន់អភិរក្សនេះ គ្របដណ្តប់ដោយព្រៃល្បោះ ព្រៃពាក់កណ្តាលស្រោង និងព្រៃស្រោង។ ក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះមានការប្រែប្រួលគម្របដីដែលកើតឡើងដោយការកាប់ទន្ទ្រានព្រៃឈើ ការសឹករេចរឹលព្រៃឈើ និងការធ្វើអាជីវកម្មឈើខុសច្បាប់។ ទោះបីយ៉ាងណាក៏ដោយ ក៏ឃើញមាននូវតំបន់ដាំដុះព្រៃឡើងវិញក្នុងតំបន់អភិរក្សទាំងនេះដែរដែលនេះបង្ហាញពីភាពជោគជ័យមួយនៃកិច្ចប្រឹងប្រែងការពារព្រៃឈើ។

ការប្រើប្រាស់ដី "**តំបន់ការពារធម្មជាតិមានការគ្រប់គ្រងរួម**" រួមមានតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ដែលស្ថិតនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ។ ការប្រែប្រួលគម្របដីសំខាន់ៗដែលកើតឡើងក្នុងរយៈពេល២០ឆ្នាំចុងក្រោយគឺដោយសារកត្តាចំណូលស្រុកដែលនាំឱ្យមានការកាប់ទន្ទ្រានព្រៃឈើ។ ប្រព័ន្ធប្រើប្រាស់ដីបច្ចុប្បន្នមានលក្ខណៈជាព្រៃឈើលាយឡំជាមួយដីលំនៅឋាននិងដីកសិកម្ម។ ការគ្រប់គ្រងតំបន់នេះត្រូវបានបង្កើតឡើងដោយពាក្យថា "**ការគ្រប់គ្រងរួមគ្នា**" ដែលជាចំណុចស្នូលនៃក្រមបរិស្ថាន។ ការគ្រប់គ្រងរួមគ្នាបង្កើតឡើង ដើម្បីជំរុញនិងពង្រឹងប្រព័ន្ធតំបន់ការពារសហគមន៍នាពេលបច្ចុប្បន្ន។ ក្រមនេះនឹងប្រែក្លាយយន្តការសហគមន៍តំបន់ការពារធម្មជាតិពីការបែងចែកដីតូចៗទៅជាប្រព័ន្ធគ្រប់គ្រងទូលំទូលាយដែលជាទិដ្ឋភាពដ៏សំខាន់នៃការគ្រប់គ្រងតំបន់ការពារទាំងមូលនិងការអភិវឌ្ឍជីវភាពរស់នៅក្នុងមូលដ្ឋាន។

ការប្រើប្រាស់ដី "**តំបន់កសិឧស្សាហកម្មខ្នាតធំឬសម្បទានដីសេដ្ឋកិច្ច**" ជាដីមួយផ្នែកធំនៃដីឯកជនរបស់រដ្ឋដែលរដ្ឋផ្តល់ឱ្យក្រុមហ៊ុនសម្រាប់ដំណាំចម្ការខ្នាតធំ។ សម្បទានដីសេដ្ឋកិច្ចគឺជាកត្តាជំរុញដ៏ធំមួយដែលបានធ្វើឱ្យមានការបាត់បង់ព្រៃឈើជាច្រើនក្នុងខេត្តមណ្ឌលគិរី។ ការផ្តល់សម្បទានដីសេដ្ឋកិច្ចបណ្តាលឱ្យមានបញ្ហាជាច្រើន។ សម្បទានដីសេដ្ឋកិច្ចត្រូវបានផ្តល់ឱ្យក្រុមហ៊ុនវិនិយោគជាច្រើនទូទាំងខេត្តមណ្ឌលគិរីដែលបង្កើតឱ្យមានផ្ទៃដីកសិកម្មដាច់ៗពីគ្នានិងមានកសិករខ្នាតតូចរស់នៅ។

រីឯការប្រើប្រាស់ដី "**កសិកម្មខ្នាតតូចកម្រិតខ្ពស់**" ជាតំបន់ដែលប្រើប្រាស់សម្រាប់កសិកម្មខ្នាតតូចជាចម្បង លើកលែងតែតំបន់សាងសង់។ ប្រព័ន្ធប្រើប្រាស់ដីប្រភេទនេះ មានលក្ខណៈសកម្ម ដោយសារមានការប្រែប្រួលគម្របដីនិងកំណើនប្រជាជនដែលកើតមានក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ។ តំបន់កសិកម្មខ្នាតតូចនេះមានលក្ខណៈដាច់ៗពីគ្នាជាច្រើនចំណែកតូចៗ ស្ថិតនៅជុំវិញក្រុងសែនមនោរម្យ នៅជុំវិញតំបន់ការពារធម្មជាតិ និងនៅក្បែរតំបន់សម្បទានដីសេដ្ឋកិច្ច។

ការប្រើប្រាស់ដី "**តំបន់កសិកម្មខ្នាតតូចកម្រិតទាប**" ជាតំបន់មានប្រជាជនរស់នៅនិងត្រូវបានប្រើដោយកសិករខ្នាតតូចសម្រាប់កសិកម្មជាចម្បង ប៉ុន្តែក៏ជាតំបន់នៃបណ្តុំប្រភេទព្រៃឈើសំខាន់ផងដែរ។ តំបន់កសិកម្មខ្នាតតូចកម្រិតទាបក៏ឃើញមានការកាប់ទន្ទ្រានព្រៃឈើតិចតួចនាពេលកន្លងមកដែរ ដោយសារមានអ្នកចំណូលស្រុកតិចតួចមកក្នុងតំបន់នេះ។ តំបន់នេះ ជាទូទៅពាក់ព័ន្ធនឹងរបៀងអភិរក្សជីវៈចម្រុះ។

### ២.៩.៣- រចនាសម្ព័ន្ធឋានានុក្រមមជ្ឈមណ្ឌលទីប្រជុំជន

នៅព្រះរាជាណាចក្រកម្ពុជា គោលការណ៍កំណត់ឃុំជា "**តំបន់ទីប្រជុំជន**" គឺផ្អែកលើការរួមបញ្ចូលគ្នានៃលក្ខខណ្ឌវិនិច្ឆ័យចំនួន៣ រួមមានទំហំចំនួនប្រជាជន(លើសពី២ ០០០នាក់) ដង់ស៊ីតេប្រជាជន(ខ្ពស់ជាង២០០នាក់/គីឡូម៉ែត្រក្រឡា) និងមុខរបររបស់ប្រជាជន(កម្លាំងពលកម្មសរុបតិចជាង៥០ភាគរយក្នុងវិស័យកសិកម្ម)។ យោងតាមលក្ខខណ្ឌនេះ ខេត្តមណ្ឌលគិរីពុំមានឃុំនិងសង្កាត់ណាមួយអាចចាត់ថ្នាក់ជាទីប្រជុំជនបានទេ។ ឃុំសង្កាត់ទាំងអស់មិនឆ្លើយតបនឹងលក្ខខណ្ឌវិនិច្ឆ័យនេះទេ លើកលែងតែសង្កាត់មនោរម្យតែមួយប៉ុណ្ណោះដែលឆ្លើយតបនឹងលក្ខខណ្ឌទី២ គឺមានដង់ស៊ីតេប្រជាជន២១៤នាក់/គីឡូម៉ែត្រក្រឡា។

ដូច្នេះ លក្ខខណ្ឌវិនិច្ឆ័យទាំងនេះមិនសមស្របសម្រាប់ការធ្វើចំណាត់ថ្នាក់មជ្ឈមណ្ឌលទីប្រជុំជនក្នុងខេត្តមណ្ឌលគិរីទេ។ ប៉ុន្តែការចាត់ចំណាត់ថ្នាក់មុខងារនៃមជ្ឈមណ្ឌលទីប្រជុំជនគឺមានកត្តាជាច្រើនទៀត ដូចជាកត្តាសេវាកម្មដែលជាចំណុចសំខាន់នៅក្នុងការធ្វើចំណាត់ថ្នាក់ទីប្រជុំជននៅក្នុងខេត្តមណ្ឌលគិរី។ ដូច្នេះ ការធ្វើចំណាត់ថ្នាក់សេវាកម្មសម្រាប់មជ្ឈមណ្ឌលទីប្រជុំជន មានលក្ខណៈទូលំទូលាយ មានកម្រិតនិងប្រភេទខុសៗគ្នារួមមានសេវាកម្មសង្គម សេវាកម្មវប្បធម៌ ការកម្សាន្ត និងសេវាកម្មសេដ្ឋកិច្ច។ នៅពេលដែលឋានានុក្រមនៃមជ្ឈមណ្ឌលទីប្រជុំជនត្រូវបានកំណត់រួច ការពិនិត្យមើលមុខងារនិងតួនាទីសំខាន់ៗនៃមជ្ឈមណ្ឌលនីមួយៗនិងទំនាក់ទំនងរវាងពួកគេមានការចាំបាច់ ដើម្បីឈានទៅកំណត់ទំនាក់ទំនងរវាងបរិក្ខារនិងសេវាកម្មដែលមាននៅក្នុងមជ្ឈមណ្ឌលទីប្រជុំជននិងនៅកន្លែងផ្សេងៗនៅទូទាំងខេត្តមណ្ឌលគិរី។

### ២.៩.៤- ប៉ូលអភិវឌ្ឍសេដ្ឋកិច្ច

#### ក- ច្រកព្រំដែន

បច្ចុប្បន្នខេត្តមណ្ឌលគិរីមានច្រកព្រំដែនចំនួន៤ ជាមួយប្រទេសវៀតណាម រួមមាន ១)ច្រកឡាប៉ាខេ (ច្រកចម្បង) ក្នុងស្រុកកែវសីមា ២)ច្រកដាក់ដាំ(ច្រកចម្បង) ក្នុងស្រុកអូររាំង ៣)ច្រកណាមលៀរ(កំពុងអភិវឌ្ឍ) ក្នុងស្រុកពេជ្រាដា និង ៤)ច្រកជីមៀតឬកោះម្មើល(ផ្លូវត្រួសក្រហម) ក្នុងស្រុកកោះញែក។ ក្រៅពីនេះ ខេត្តមណ្ឌលគិរីអាចតភ្ជាប់ទៅប្រទេសឡាវ ដោយឆ្លងកាត់ខេត្តរតនគិរីនិងខេត្តស្ទឹងត្រែង។ ការរក្សាទំនាក់ទំនងល្អជាមួយប្រទេសវៀតណាមបានធ្វើឱ្យប្រជាជនទទួលបានសារៈប្រយោជន៍ច្រើនតាមរយៈការបង្កើតការងារនិងការរីកចម្រើននៃសេដ្ឋកិច្ចក្នុងខេត្ត។

#### ខ- ការអភិវឌ្ឍទេសចរណ៍

ខេត្តមណ្ឌលគិរីជាគោលដៅទេសចរណ៍កម្សាន្តសម្រាប់អ្នកមកពីតំបន់ផ្សេងៗ ដោយសារខេត្តនេះមានអាកាសធាតុធម្មជាតិនៃតំបន់ខ្ពង់រាបត្រជាក់ពិសេសនិងទេសភាពគួរឱ្យទាក់ទាញ ដូចជាជួរភ្នំ ទឹកជ្រោះ ទឹកធ្លាក់ វាលស្មៅបៃតងដ៏ស្រស់ស្អាត តំបន់ព្រៃការពារ ព្រៃឈើ សត្វព្រៃ កសិកម្មតំបន់ខ្ពង់រាប វាលទំនាប ទន្លេ ស្ទឹង ព្រែក និងអាងស្តុកទឹកធម្មជាតិជាដើម។ ក្រៅពីនេះ ខេត្តមណ្ឌលគិរីមានជនជាតិដើមភាគតិចដែលអាចជាគោលដៅទាក់ទាញភ្ញៀវទេសចរទាំងទេសចរជាតិនិងអន្តរជាតិមកទស្សនាសហគមន៍ ស្វែងយល់ពីវប្បធម៌ជនជាតិដើមភាគតិចនិង/ឬសាកល្បងពិសាអាហារប្រពៃណីនិងស្រារបស់ពួកគេ។ ខេត្តមណ្ឌលគិរីមានទីតាំងទេសចរណ៍ជាច្រើនដែលអាចចែកជាអេកូទេសចរណ៍ រួមជាមួយទេសចរណ៍កែច្នៃ អេកូទេសចរណ៍វប្បធម៌ ទេសចរណ៍កសិកម្ម និងទេសចរណ៍សាសនា ហើយទីតាំងទាំងនេះផ្តល់សក្តានុពលដ៏វិសេសវិសាលក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។

ទេសចរណ៍គឺជាវិស័យចម្បងមួយក្នុងការអភិវឌ្ឍនិងត្រូវបានចាត់ទុកថា ឧស្សាហកម្មគ្មានផ្សែងសម្រាប់ខេត្តមណ្ឌលគិរី។ វិស័យនេះបានផ្តល់ការងារជាច្រើនដល់ប្រជាពលរដ្ឋនិងលើកស្ទួយសកម្មភាពអាជីវកម្ម សហគ្រាសធុនតូចនិងមធ្យម ដូចជាការដឹកជញ្ជូន សណ្ឋាគារ ផ្ទះសំណាក់ រមណីយដ្ឋាន ភោជនីយដ្ឋាន ហាងទំនិញ ហាងកាហ្វេ និងសេដ្ឋកិច្ចក្រៅប្រព័ន្ធជាច្រើនទៀត។ ដូច្នេះ ដើម្បីចៀសវាងផលប៉ះពាល់អវិជ្ជមាននានា ធាតុសំខាន់ៗសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ក្នុងខេត្តមណ្ឌលគិរី ដូចជាការអភិវឌ្ឍបរិក្ខារឬសេវាកម្មទេសចរណ៍ ការចូលរួមរបស់សហគមន៍មូលដ្ឋាន ការចូលរួមសហការរបស់រាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងអង្គការនានា ត្រូវមានយន្តការត្រួតពិនិត្យត្រឹមត្រូវ ព្រមទាំងគោលនយោបាយអន្តរាគមន៍ និងក្របខ័ណ្ឌច្បាប់គាំទ្រផ្សេងៗបន្ថែមទៀត។

#### គ- កសិឧស្សាហកម្ម

ខេត្តមណ្ឌលគិរីមានផ្ទៃដីធំទូលាយនិងមានដីជាតិដែលមានអំណោយផលល្អដល់ដំណាំកសិឧស្សាហកម្ម។ ខេត្តមណ្ឌលគិរីបានផលិតបរិមាណវត្ថុធាតុដើមច្រើនគួរឱ្យកត់សម្គាល់ ដូចជាកៅស៊ូ ដំឡូងមី ពោត និងគ្រាប់ស្វាយចន្ទីជាដើម។ ទោះបីមានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ សកម្មភាពកសិឧស្សាហកម្មនៅខេត្តមណ្ឌលគិរីនៅមានកម្រិតនាពេលបច្ចុប្បន្ន។ ខេត្តមណ្ឌលគិរីមានរោងចក្រចំនួន២កន្លែងប៉ុណ្ណោះដែលស្ថិតនៅក្នុងស្រុកពេជ្រាដាសម្រាប់កែច្នៃផលិតផលកៅស៊ូនិងមានសហគ្រាសធុនតូចនិងមធ្យមមួយចំនួនតូចដែលកែច្នៃផលិតផលកាហ្វេ។ ចំពោះផលិតផលដំឡូងមី ម្រេច និងគ្រាប់ស្វាយចន្ទីមានឈ្មួញមកទិញផ្ទាល់ពីកសិករនិងលក់ចេញវិញទៅឱ្យអ្នកកែច្នៃដែលនៅក្នុងខេត្តជិតខាងឬនាំចេញទៅប្រទេសជិតខាង អាស្រ័យលើតម្រូវការនិងតម្លៃ។

ប្រទេសកម្ពុជាបានចាត់ទុកតួនាទីកសិឧស្សាហកម្ម ពិសេសសគ្រាសធុនតូចនិងមធ្យម ជាចលករដ៏សំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ ហើយជាបណ្តើរៗបាននិងកំពុងប្រែក្លាយខ្លួនទៅជាប្រទេសកសិ-ឧស្សាហកម្ម។ ទោះបីជាយ៉ាងនេះក៏ដោយ រាជរដ្ឋាភិបាលគួរមានការរៀបចំយន្តការ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីឱ្យបានកាន់តែប្រសើរ ដើម្បីទាក់ទាញអ្នកវិនិយោគទាំងក្នុងស្រុកនិងក្រៅស្រុកលើកសិ-ឧស្សាហកម្ម រួមទាំងការកែច្នៃផលិតផលសម្រេចនិងម្ហូបអាហារជាដើម។

## ៣- ចក្ខុវិស័យ

ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី ចក្ខុវិស័យឆ្នាំ២០៤០ ត្រូវបានកសាងឡើងដោយផ្អែកលើធាតុចូលសំខាន់ៗរបស់ភាគីពាក់ព័ន្ធ ការសិក្សានិងវិភាគចម្បងៗនូវក្របខ័ណ្ឌសេដ្ឋកិច្ច សង្គម និងបរិស្ថាន ធាតុផ្សំនៃរចនាសម្ព័ន្ធដែនដី ពិសេសសេណារីយ៉ូការប្រើប្រាស់ដីនិងប្រព័ន្ធអេកូឡូស៊ីនិងសេណារីយ៉ូប្រជាសាស្ត្រ ព្រមទាំងជម្រើសសម្រាប់ការកាត់បន្ថយហានិភ័យ និងការបន្សាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ហើយមានការថ្លឹងថ្លែងនូវផលវិជ្ជមាននិងអវិជ្ជមាន សំយោគនូវជម្រើសនិងសេណារីយ៉ូ ព្រមទាំងកត្តាពាក់ព័ន្ធនានាជាច្រើនស្របតាមនិន្នាការនៃការអភិវឌ្ឍ សក្តានុពលនៃទីតាំងភូមិសាស្ត្រក្នុងខេត្តនិងតំបន់ ក្របខ័ណ្ឌគោលនយោបាយយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ជាតិនិងអន្តរជាតិ ដើម្បីតម្រង់ទិសទៅរកគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចនិងអភិរក្សធនធានធម្មជាតិប្រកបដោយតុល្យភាពក្នុងដែនដីខេត្តមណ្ឌលគិរីសម្រាប់រយៈពេល២០ឆ្នាំខាងមុខ។ គោលដៅអភិវឌ្ឍន៍ទាំងនេះ រួមមានការធ្វើពិពិធកម្មកសិកម្មលើដីកសិកម្មខ្នាតតូចនិងដំណាំកសិឧស្សាហកម្មខ្នាតធំ ការអភិវឌ្ឍខេត្តមណ្ឌលគិរីជាមជ្ឈមណ្ឌលសេដ្ឋកិច្ចនិងគមនាគមន៍ក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា- ឡាវ- វៀតណាម និងការជំរុញការអភិវឌ្ឍអេកូទេសចរណ៍។ កិច្ចខិតខំប្រឹងប្រែងទាំងនេះនឹងបង្កើតការងារនិងអត្រាមានការងារធ្វើជាច្រើនសម្រាប់ប្រជាជននិងជំរុញឆ្ពោះទៅរកការកាត់បន្ថយភាពក្រីក្រ។

គោលបំណងអភិរក្សធនធានធម្មជាតិ រួមបញ្ចូលនូវការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងដែនជម្រកសត្វព្រៃ ការតាមដាននិងការវាយតម្លៃយ៉ាងហ្មត់ចត់លើគម្រោងធំៗ និងផលប៉ះពាល់របស់វាលើប្រព័ន្ធអេកូឡូស៊ី។ ចីរភាពបរិស្ថានត្រូវបានគិតគូរជាចម្បងក្នុងផែនការ ហើយការអនុវត្ត ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច ព្រមទាំងការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច ពិតជាមានការចាំបាច់និងជួយគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងធ្វើការអភិរក្សធនធានធម្មជាតិ។ ជាលទ្ធផលកិច្ចខិតខំប្រឹងប្រែងទាំងនេះមិនត្រឹមតែបានជួយបន្សាំប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយកាត់បន្ថយការប្រែប្រួលអាកាសធាតុដែលជាក្តីកង្វល់របស់ពិភពលោក។ សេណារីយ៉ូសេដ្ឋកិច្ចបៃតងមានលក្ខណៈពិសេសចាំបាច់សម្រាប់ការអភិវឌ្ឍខេត្តមណ្ឌលគិរី។ សេណារីយ៉ូនេះ រួមបញ្ចូលនូវកិច្ចខិតខំប្រឹងប្រែងធ្វើការអភិវឌ្ឍ បានផ្តោតសំខាន់លើការអភិរក្សដែនជម្រកសត្វព្រៃរួមគ្នា កសិកម្មដែលមាននិរន្តរភាព ព្រមទាំងការលើកកម្ពស់អេកូទេសចរណ៍-វប្បធម៌ប្រកបដោយការទទួលខុសត្រូវខ្ពស់។ ផ្អែកលើសមាសធាតុសំខាន់ៗទាំងនេះ បង្កើតបាននូវចក្ខុវិស័យសម្រាប់ការអភិវឌ្ឍដែនដីខេត្តមណ្ឌលគិរីដូចខាងក្រោមៈ

**“ខេត្តមណ្ឌលគិរីគឺជាមជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ចបៃតងនៃព្រះរាជាណាចក្រកម្ពុជាដ៏មានជីវភាពនិងរស់រវើក ផ្អែកលើធនធានធម្មជាតិនិងវប្បធម៌សម្បូរបែប អាកាសធាតុ ធម្មជាតិ ទេសភាព ទន្លេ ប្រជុំភ្នំ- សមុទ្រឈើដ៏សែនមនោរម្យរបស់ខេត្ត រួមចំណែកជាចម្បងក្នុងការលើកកម្ពស់ប៉ូលអភិវឌ្ឍជាតិនៅភាគឦសាន ស្របតាមការតម្រង់ទិសការគ្រប់គ្រងនិងការអភិវឌ្ឍដែនដីដ៏ត្រឹមត្រូវ មានសណ្តាប់ធ្នាប់ និងគុណភាពបរិស្ថានរស់នៅល្អប្រសើរ ដើម្បីគាំទ្រនិងលើកស្ទួយការអភិវឌ្ឍអេកូទេសចរណ៍និងទេសចរណ៍វប្បធម៌ដែលផ្តល់ផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន ប្រកបដោយប្រសិទ្ធភាព ចីរភាព ភាពឆ្លាត និងបរិយាបន្នដល់ប្រជាជន ទេសចរ**

**និងអ្នកវិនិយោគទាំងអស់។"** តាមរយៈការពង្រឹងការគ្រប់គ្រង អភិបាលកិច្ចល្អ ការអភិវឌ្ឍសមត្ថភាពនិងស្ថាប័ន ចំពោះសសរស្តម្ភអភិរក្សនិងអភិវឌ្ឍ : ១)ការការពារនិងការគ្រប់គ្រងសេវាកម្មអេកូឡូស៊ីរួមគ្នា ២)អេកូទេសចរណ៍ដែលផ្តល់តម្លៃអត្តសញ្ញាណវប្បធម៌ចម្រុះជនជាតិនិងបរិស្ថានរបស់ខេត្ត ៣)ការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាពដែលគិតគូរដល់ជីវៈចម្រុះនិងផលប្រយោជន៍កសិករខ្នាតតូច ៤)មជ្ឈមណ្ឌលប៉ូលអភិវឌ្ឍសេដ្ឋកិច្ចជាតិភាគឦសានប្រកបដោយភាពរស់រវើកផ្សារភ្ជាប់នឹងសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់អភិវឌ្ឍន៍ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និង ៥)ការរីកចម្រើននៃនគរូបនីយកម្មដែលផ្តល់តម្លៃលើធម្មជាតិនិងទេសភាព។

សសរស្តម្ភចំនួន៥ដែលត្រូវបានរៀបចំឡើង មានដូចខាងក្រោម៖

**១-ការការពារនិងការគ្រប់គ្រងសេវាកម្មអេកូឡូស៊ីរួមគ្នា**

ខេត្តមណ្ឌលគិរីមានធនធានធម្មជាតិយ៉ាងសម្បូរបែបដែលផ្តល់នូវសេវាកម្មធម្មជាតិ សេដ្ឋកិច្ច សង្គម និងវប្បធម៌យ៉ាងច្រើន សុទ្ធសឹងមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍខេត្តប្រកបដោយចីរភាព។ ក្របខ័ណ្ឌស្ថាប័នត្រូវបង្កើតឡើងសម្រាប់ធ្វើការគ្រប់គ្រងធនធានទាំងនេះ ដើម្បីទទួលបាននូវអត្ថប្រយោជន៍ពីការគាំទ្រនិងការសហការពីអ្នកពាក់ព័ន្ធនានា ហើយដាក់សហគមន៍មូលដ្ឋានជាតួអង្គសំខាន់ក្នុងកិច្ចខិតខំប្រឹងប្រែងអភិរក្សនេះ។ ការអភិរក្សព្រៃឈើក៏ជាផ្នែកមួយនៃការចូលរួមចំណែករបស់ប្រទេសកម្ពុជាក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

**២-អេកូទេសចរណ៍ដែលផ្តល់តម្លៃអត្តសញ្ញាណវប្បធម៌ចម្រុះជនជាតិនិងបរិស្ថានរបស់ខេត្ត**

ភាពពិសេសនៃវប្បធម៌និងបរិស្ថានធម្មជាតិរបស់ខេត្តមណ្ឌលគិរីគឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍។ ភាពចម្រុះនិងសម្បូរបែបនៃព្រៃឈើ ទេសភាពកសិកម្ម ក៏ដូចជាវប្បធម៌ជនជាតិដើមភាគតិចរបស់ខេត្តគឺជាសម្បត្តិដ៏សំខាន់និងវិសេសវិសាលសម្រាប់ការអភិវឌ្ឍវិស័យនេះ។ ស្របពេលជាមួយគ្នាការអភិវឌ្ឍទេសចរណ៍ដោយមានទំនួលខុសត្រូវផ្សារភ្ជាប់នឹងគុណតម្លៃបរិស្ថាននិងវប្បធម៌ប្រពៃណី មានសារៈសំខាន់ ដើម្បីថែរក្សាភាពពិសេសគ្មានពីរសម្រាប់ខេត្តមណ្ឌលគិរី។

**៣-ការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាពដែលគិតគូរដល់ជីវៈចម្រុះនិងផលប្រយោជន៍កសិករខ្នាតតូច**

ការអភិវឌ្ឍដោយយកចិត្តទុកដាក់លើការនាំចេញដែលមានទុនពឹងផ្អែកលើផ្នែកកសិឧស្សាហកម្ម (សម្បទានដីសេដ្ឋកិច្ចនិងចម្ការដំណាំឯកជនខ្នាតមធ្យម)និងកសិកម្មខ្នាតតូចជាលក្ខណៈគ្រួសារដែលកំពុងមានកំណើនមានសារៈសំខាន់ណាស់សម្រាប់ខេត្តមណ្ឌលគិរី។ វិស័យទាំងពីរនឹងវិវត្តរួមគ្នាតាមរយៈភាពជាដៃគូប្រកបដោយទំនួលខុសត្រូវនិងផ្តល់ផលប្រយោជន៍ទៅវិញទៅមក។ មាគ៌ានេះត្រូវដើរតាមគោលការណ៍ពិពិធកម្មកសិកម្មតាមបែបធម្មជាតិដែលអនុញ្ញាតឱ្យមានការបង្កើនផលិតកម្មនិងផលិតភាព ការអភិរក្សធនធានធម្មជាតិ ដូចជាដីនិងទឹក ព្រមទាំងបង្កើនភាពធន់របស់គ្រួសារនិងជីវភាពកសិករទប់ទល់ពេលអាកាសធាតុមិនទៀងទាត់។

ការពង្រីកផ្ទៃដីកសិកម្មដោយគ្មានផែនការគ្រោងទុកជាមុនត្រូវបញ្ចប់។ ការឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ ការរីកចម្រើននៃកសិកម្មដែលមានផែនការច្បាស់លាស់គឺពិតជាមានសារៈសំខាន់ណាស់ក្នុងការតម្រង់ទិសការអភិវឌ្ឍដែនដី ដើម្បីធានាការអភិវឌ្ឍដោយផ្អែកឬការអភិវឌ្ឍបន្ថែមនៃផ្ទៃដីកសិកម្មក្នុងតំបន់ការពារធម្មជាតិនិងតំបន់ព្រៃឈើ ដើម្បីធានាបាននូវចីរភាពបរិស្ថាននិងប្រព័ន្ធអេកូឡូស៊ី ដោយត្រូវរក្សាស្ថានភាពនិងទេសភាពភូមិសាស្ត្រធម្មជាតិនៃតំបន់ខ្ពង់រាប។ ការលើកកម្ពស់ការអភិវឌ្ឍបៃតង ការអភិវឌ្ឍកសិកម្ម ការបង្កើតរបៀងធម្មជាតិ និងការដាំតម្រូបព្រៃឡើងវិញនឹងរួមចំណែកដល់ការកាត់បន្ថយការសាយភាយឧស្ម័នផ្ទះកញ្ចក់និងកម្រិតផលប៉ះពាល់ចំពោះការប្រែប្រួលអាកាសធាតុ។

### ៤-មជ្ឈមណ្ឌលប៉ូលអភិវឌ្ឍសេដ្ឋកិច្ចជាតិភាគឦសានប្រកបដោយភាពរស់រវើកផ្សារភ្ជាប់ទៅនឹងសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់អភិវឌ្ឍន៍ត្រីកោណកម្ពុជា-ឡាវ-វៀតណាម

ខេត្តមណ្ឌលគីរីជាខេត្តមួយស្ថិតក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាមដែលមានសេដ្ឋកិច្ចរស់រវើកនិងចូលរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងសមាហរណកម្មអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងតំបន់តាមរយៈការផ្តល់សេវាកម្មដឹកជញ្ជូន ការជំរុញផលិតកម្មកសិឧស្សាហកម្មមានគុណភាពខ្ពស់ ការអភិវឌ្ឍឧស្សាហកម្មធុនស្រាលផ្អែកលើចំណេះដឹង បច្ចេកវិទ្យា និងនវានុវត្តន៍ ការជំរុញពាណិជ្ជកម្មឪជីថលនិងជាច្រកទ្វារពាណិជ្ជកម្មជាមួយប្រទេសវៀតណាមនិងតំបន់។

### ៥-ការរីកចម្រើននៃនគរូបនីយកម្មដែលផ្តល់តម្លៃលើធម្មជាតិនិងទេសភាព

ក្នុងបរិបទនៃការរីកលូតលាស់នៃសេដ្ឋកិច្ចនិងការកើនឡើងនៃអត្រាចំណូលស្រុកខ្ពស់នាពេលអនាគតចំនួនប្រជាជននៅតាមទីប្រជុំជនក្នុងខេត្តនឹងមានសម្ពាធទាំងលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត លើដី និងលើសេវាកម្មគ្រប់ប្រភេទ។ ចំពោះស្ថានភាពនេះ មជ្ឈមណ្ឌលទីប្រជុំជនបច្ចុប្បន្ននិងមជ្ឈមណ្ឌលទីប្រជុំជនដែលរីកចម្រើនថ្មីៗត្រូវការប្លង់គោលប្រើប្រាស់ដីដ៏ប្រសើរ ដើម្បីបញ្ចៀសពីការរីកដុះដាលនៃទីប្រជុំជនដោយមិនទៅតាមការចង់បាននិងទម្រង់នៃការអភិវឌ្ឍដែលគ្មានផែនការជាមុន។ ការឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ ការីកចម្រើននៃនគរូបនីយកម្មដែលមានផែនការច្បាស់លាស់គឺពិតជាមានសារៈសំខាន់ណាស់ក្នុងការតម្រង់ទិសការអភិវឌ្ឍដែនដីដើម្បីធានាការអភិវឌ្ឍដោយផ្អែកឬការអភិវឌ្ឍបន្ថែមនៃមជ្ឈមណ្ឌលទីប្រជុំជននិងការតាំងលំនៅឋានកាន់តែមានគុណភាពរស់នៅកាន់តែប្រសើរនិងមាននិរន្តភាព ដោយត្រូវរក្សាស្ថានភាពនិងទេសភាពភូមិសាស្ត្រនៃតំបន់ខ្ពង់រាប។ ការលើកកម្ពស់ការអភិវឌ្ឍទីក្រុង ទីប្រជុំជនបៃតងក៏នឹងរួមចំណែកដល់ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់និងកម្រិតផលប៉ះពាល់នៃនគរូបនីយកម្មចំពោះការប្រែប្រួលអាកាសធាតុ។

រូបភាពទី១ ចក្ខុវិស័យនៃការអភិវឌ្ឍខេត្តមណ្ឌលគីរី ឆ្នាំ២០៤០



## ៤- គោលបំណងអភិវឌ្ឍរយៈពេលវែងនិងគោលដៅ

ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះគឺត្រូវរៀបចំការងារស្នូលជាមូលដ្ឋានសម្រាប់ការអនុវត្តនិងការតាមដានត្រួតពិនិត្យលើសកម្មភាព គម្រោង និងកម្មវិធីពាក់ព័ន្ធនានា រួមមានការអភិវឌ្ឍនិងការលើកកម្ពស់មូលធនមនុស្សដោយផ្ដល់នូវចំណេះដឹង ជំនាញ និងបទពិសោធទាំងស្ថាប័នរដ្ឋនិងឯកជន ដោយឈរលើគោលការណ៍អភិបាលកិច្ចល្អ។ គោលនយោបាយកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការគួរយកមកអនុវត្តប្រកបដោយតម្លាភាព យុត្តិធម៌ ប្រជាធិបតេយ្យ និងស្របតាមលក្ខខណ្ឌច្បាប់។ កិច្ចការនេះទាមទារឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពពីតំណាងភាគីពាក់ព័ន្ធ រួមមានអង្គការតាមសហគមន៍ អង្គភាពរាជរដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន និងសាធារណជន។ ភាពជាដៃគូក្នុងការគ្រប់គ្រងរវាងវិស័យសាធារណៈនិងឯកជននៅក្នុងតំបន់ប្រកបដោយភាពច្នៃប្រឌិតនឹងបង្កើតឡើង ហើយទទួលស្គាល់ដោយសហគមន៍ជនបទទាំងអស់ដែលជាតួអង្គដ៏សំខាន់ក្នុងការអភិវឌ្ឍមូលដ្ឋាន។

គោលបំណងអភិវឌ្ឍរយៈពេលវែងត្រូវបានកំណត់ឡើង ដើម្បីធ្វើឱ្យសម្រេចនូវចក្ខុវិស័យដល់ឆ្នាំ២០៤០។ គោលបំណងអភិវឌ្ឍរយៈពេលវែងនេះ កំណត់និន្នាការអភិវឌ្ឍដែនដីនិងរចនាសម្ព័ន្ធរបស់ខេត្តពាក់ព័ន្ធនឹងធាតុផ្សំសំខាន់ៗនៃរចនាសម្ព័ន្ធដែនដីដែលបានកំណត់ពីខាងដើម។ គោលបំណងអភិវឌ្ឍរយៈពេលវែងនីមួយៗអាចសម្រេចបានតាមរយៈការអនុវត្តគោលដៅដែលបានកំណត់ជាក់លាក់។

### ៤.១- គោលបំណងអភិវឌ្ឍរយៈពេលវែង ១ : ទទួលបានការអភិរក្សជីវៈចម្រុះប្រកបដោយនិរន្តរភាពនិងការអភិវឌ្ឍជីវភាពរស់នៅរបស់ប្រជាជននៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ(ដែនជម្រកសត្វព្រៃនិងរបៀងអភិរក្សជីវៈចម្រុះ)

បញ្ហាប្រឈមចម្បងសម្រាប់ការរៀបចំប្រព័ន្ធប្រើប្រាស់ដី ដើម្បីធ្វើឱ្យមានតុល្យភាពរវាងការពង្រឹងកិច្ចខិតខំប្រឹងប្រែងអភិរក្សធនធានធម្មជាតិនិងការគាំទ្រការអភិវឌ្ឍជីវភាពប្រជាជនប្រកបដោយនិរន្តរភាពនៅក្នុងតំបន់ការពារធម្មជាតិ។ ការថ្លឹងថ្លែងផលវិជ្ជមាននិងអវិជ្ជមានរវាងការអភិរក្សនិងការអភិវឌ្ឍគឺផ្អែកលើការសន្មត់ដែលផ្ដល់ឱ្យប្រជាជនរស់នៅក្នុងតំបន់ការពារធម្មជាតិមានឱកាសអភិវឌ្ឍជីវភាពរស់នៅនិងជួយបង្កើនកិច្ចការពារព្រៃឈើក្នុងតំបន់នេះឡើងវិញ។ ស្របពេលជាមួយគ្នានេះ ការលើកឡើងពីហេតុផលប៉ះពាល់ដែលអាចកើតចេញពីគម្រោងខ្នាតធំ ដូចជាអាជីវកម្មរ៉ែ គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ គម្រោងទំនប់វារីអគ្គិសនីជាដើម។ ដើម្បីសម្រេចនូវគោលបំណងអភិវឌ្ឍរយៈពេលវែងនេះត្រូវអនុវត្តគោលដៅចំនួន៣ដូចខាងក្រោម៖

- **គោលដៅ ៤.១.១** ជំរុញការអភិរក្សប្រកបដោយនិរន្តរភាពក្នុងដែនជម្រកសត្វព្រៃនិងរបៀងអភិរក្សជីវៈចម្រុះ
- **គោលដៅ ៤.១.២** កំណត់ហេតុប៉ះពាល់សេដ្ឋកិច្ច សង្គម និងបរិស្ថាននៃគម្រោងអភិវឌ្ឍខ្នាតធំ
- **គោលដៅ ៤.១.៣** គាំទ្រការអភិវឌ្ឍមជ្ឈមណ្ឌលអប់រំ ដើម្បីលើកកម្ពស់ការសិក្សានិងការស្រាវជ្រាវអំពីជីវៈចម្រុះនិងការអភិរក្សប្រកបដោយនិរន្តរភាព។

### ៤.២- គោលបំណងអភិវឌ្ឍរយៈពេលវែង ២ : ជំរុញការអភិវឌ្ឍអេកូទេសចរណ៍ផ្សារភ្ជាប់ទៅនឹងការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍មូលដ្ឋាន

សក្តានុពលសេដ្ឋកិច្ចនៃខេត្តមណ្ឌលគិរីផ្សារភ្ជាប់ទៅនឹងភាពវិសេសវិសាលតែមួយគត់នៃធនធានជីវៈចម្រុះវប្បធម៌មូលដ្ឋានដ៏សម្បូរបែបនិងមានទីតាំងស្ថិតនៅក្នុងតំបន់អភិវឌ្ឍន៍ត្រីកោណកម្ពុជា- ឡាវ- វៀតណាម។ ក្នុងបរិបទនេះ ខេត្តមណ្ឌលគិរីត្រូវកំណត់ជាពិសេសទៅជាប៉ូលអេកូទេសចរណ៍តែមួយគត់សម្រាប់ទាក់ទាញភ្ញៀវទេសចរជាតិនិងអន្តរជាតិ។ ដើម្បីសម្រេចនូវគោលបំណងអភិវឌ្ឍរយៈពេលវែងនេះត្រូវអនុវត្តគោលដៅចំនួន២ដូចខាងក្រោម៖

- **គោលដៅ ៤.២.១** ពង្រឹងការអភិវឌ្ឍអេកូទេសចរណ៍ ដោយផ្សារភ្ជាប់ទៅនឹងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាពនិងការថែរក្សាវប្បធម៌ប្រពៃណីមូលដ្ឋាន
- **គោលដៅ ៤.២.២** គាំទ្រដល់ការអភិវឌ្ឍមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដែលលើកកម្ពស់ផលិតផលទេសចរណ៍និងសេវាកម្មផ្អែកលើធនធានមូលដ្ឋាន។

### ៤.៣- គោលបំណងអភិវឌ្ឍរយៈពេលវែង ៣ : លើកកម្ពស់ការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាពសម្រាប់កសិករខ្នាតតូច ព្រមទាំងការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍មូលដ្ឋាននៅក្រៅតំបន់ការពារធម្មជាតិ

ដើម្បីការពារកុំឱ្យកសិករពង្រីកផ្ទៃដីកសិកម្មនៅក្នុងដែនជម្រកសត្វព្រៃគួរតែផ្តល់នូវលក្ខខណ្ឌចាំបាច់មួយចំនួន ដើម្បីធ្វើឱ្យកម្រិតជីវភាពកសិករមានភាពប្រសើរឡើងពីការប្រកបរបរកសិកម្ម។ ដើម្បីសម្រេចនូវគោលបំណងអភិវឌ្ឍន៍រយៈពេលវែងនេះត្រូវអនុវត្តគោលដៅចំនួន៣ដូចខាងក្រោម៖

- **គោលដៅ ៤.៣.១** លើកកម្ពស់ការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តភាពសម្រាប់កសិករខ្នាតតូច
- **គោលដៅ ៤.៣.២** លើកកម្ពស់ការអភិវឌ្ឍកសិឧស្សាហកម្មខ្នាតធំប្រកបដោយទំនួលខុសត្រូវដែលស្វែងរកផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមកជាមួយកសិករខ្នាតតូច
- **គោលដៅ ៤.៣.៣** ជំរុញការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍មូលដ្ឋាននៅក្រៅប្រព័ន្ធតំបន់ការពារធម្មជាតិ។

### ៤.៤- គោលបំណងអភិវឌ្ឍរយៈពេលវែង ៤ : ពង្រឹងតួនាទីរបស់ខេត្តមណ្ឌលគិរីនៅក្នុងការអភិវឌ្ឍជាតិនិងការធ្វើសមាសហរណកម្មសេដ្ឋកិច្ចទៅក្នុងតំបន់

ខេត្តមណ្ឌលគិរីដើរតួជាប៉ូលសេដ្ឋកិច្ចមួយដ៏មានថាមភាពដែលពង្រឹងនិងគាំទ្រដល់ការអភិវឌ្ឍនៅភាគឦសាននៃព្រះរាជាណាចក្រកម្ពុជានិងតំបន់អភិវឌ្ឍន៍ត្រីកោណកម្ពុជា- ឡាវ- វៀតណាម។ ទិដ្ឋភាពសំខាន់នៃកិច្ចខិតខំប្រឹងប្រែងទាំងនេះគឺការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនត្រូវតែឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនក្នុងមូលដ្ឋាននិងកម្រិតផលប៉ះពាល់លើការការពារធនធានធម្មជាតិ។ ទន្ទឹមនឹងនេះក៏មានភាពចាំបាច់ផងដែរដែលត្រូវរៀបចំយុទ្ធសាស្ត្រសម្រាប់ខេត្តក្នុងការទាញយកផលប្រយោជន៍ ដើម្បីធ្វើការអភិវឌ្ឍសេដ្ឋកិច្ចនិងទេសចរណ៍ពីការពង្រឹងនិងការតភ្ជាប់បណ្តាញគមនាគមន៍នៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងរបៀងគមនាគមន៍ សេដ្ឋកិច្ចនៃមហាអនុតំបន់ទន្លេមេគង្គ(របៀងកណ្តាល របៀងខាងត្បូង និងរបៀងឆ្នេរសមុទ្រខាងត្បូង)និងជាមួយបណ្តាញគមនាគមន៍នៃតំបន់អភិវឌ្ឍន៍ត្រីកោណកម្ពុជា- ឡាវ- វៀតណាម។ កិច្ចការនេះរួមបញ្ចូលផងដែរនូវការអភិវឌ្ឍច្រកព្រំដែននិងឧស្សាហកម្មដែលពឹងផ្អែកលើផលិតផលកសិកម្មឬសក្តានុពលដទៃទៀតដែលមាននៅក្នុងខេត្ត។ ដើម្បីសម្រេចនូវគោលបំណងអភិវឌ្ឍរយៈពេលវែងនេះត្រូវអនុវត្តគោលដៅចំនួន៣ដូចខាងក្រោម៖

- **គោលដៅ ៤.៤.១** លើកកម្ពស់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននិងចល័តភាព ដើម្បីជំរុញការទទួលបានសេវាសាធារណៈសម្រាប់ប្រជាជន ដើម្បីគាំទ្រដល់ការអភិវឌ្ឍតំបន់អភិវឌ្ឍន៍ត្រីកោណកម្ពុជា-ឡាវ-វៀតណាម
- **គោលដៅ ៤.៤.២** លើកកម្ពស់កំណើននៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពនិងគម្រោងអភិវឌ្ឍតាមតំបន់ច្រកព្រំដែនតាមផែនការច្បាស់លាស់ជាមជ្ឈមណ្ឌលអភិវឌ្ឍន៍ថ្មី ដើម្បីជួយសម្រួលដល់ការផ្លាស់ប្តូរពាណិជ្ជកម្មជាមួយប្រទេសជិតខាង
- **គោលដៅ ៤.៤.៣** លើកកម្ពស់កំណើនប្រកបដោយនិរន្តរភាពនិងការអភិវឌ្ឍឧស្សាហកម្មផ្អែកលើកសិកម្មនិងប្រភេទឧស្សាហកម្មផ្សេងទៀតក្នុងតំបន់មានសក្តានុពលនានា ហើយតភ្ជាប់បណ្តាញដឹកជញ្ជូននិងតំបន់ផែស្ងួតទៅនឹងទីផ្សារក្នុងស្រុកនិងទីផ្សារក្រៅស្រុក។

**៤.៥- គោលបំណងអភិវឌ្ឍរយៈពេលវែង ៥ : ជំរុញការអភិវឌ្ឍនគរូបនីយកម្មដែលយកចិត្តទុកដាក់លើការផ្តល់សេវាសាធារណៈប្រកបដោយនិរន្តរភាពនិងបរិយាបន្ននៅគ្រប់កម្រិត**

ទោះបីខេត្តមណ្ឌលគិរីជាខេត្តជនបទក៏ពិតមែន ប៉ុន្តែមជ្ឈមណ្ឌលទីប្រជុំជនទាំងអស់គឺជាកន្លែងយ៉ាងសំខាន់សម្រាប់ប្រជាជនក្នុងការទទួលបានសេវាកម្មកន្លែងស្នាក់នៅនិងសេវាកម្មគាំទ្រផ្សេងៗទៀត។ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការរីកចម្រើននគរូបនីយកម្មទៅលើធនធានធម្មជាតិ ពោលគឺការរីករាលដាលនៃនគរូបនីយកម្មតាមបណ្តោយផ្លូវ ចាំបាច់ត្រូវមានការគិតទុកជាមុននូវផែនការនគរូបនីយកម្មជាប្រព័ន្ធតាមឋានានុក្រមនៃមជ្ឈមណ្ឌលទីប្រជុំជនដែលមានផលប៉ះពាល់បរិស្ថានកម្រិតទាប។ ដើម្បីសម្រេចគោលបំណងអភិវឌ្ឍរយៈពេលវែងនេះត្រូវអនុវត្តគោលដៅចំនួន៣ដូចខាងក្រោម៖

- **គោលដៅ ៤.៥.១** លើកកម្ពស់ការអភិវឌ្ឍទីក្រុង ទីប្រជុំជនប្រកបដោយនិរន្តរភាព ដើម្បីឆ្លើយតបនឹងកំណើនតម្រូវការសេវាកម្មសាធារណៈនិងឯកជនរបស់ប្រជាជននិងកម្រិតផលប៉ះពាល់នៃកំណើននគរូបនីយកម្មលើបរិស្ថាន
- **គោលដៅ ៤.៥.២** លើកកម្ពស់ទេសភាពទីក្រុង ទីប្រជុំជនតាមរយៈការជំរុញប្រព័ន្ធបៃតងធម្មជាតិនិងការធ្វើកសិកម្មនៅក្នុងមជ្ឈមណ្ឌលសំខាន់ៗនិងតំបន់ជុំវិញ
- **គោលដៅ ៤.៥.៣** ធានាការគ្រប់គ្រងទីក្រុងនិងការផ្តល់សេវាកម្មបរិស្ថានទីក្រុងប្រកបដោយប្រសិទ្ធភាពនិងមានគុណភាពខ្ពស់ឆ្លើយតបនឹងកំណើនទីក្រុងនិងការអភិវឌ្ឍសេដ្ឋកិច្ច។

## ៥- យុទ្ធសាស្ត្រអភិវឌ្ឍដែនដី

យុទ្ធសាស្ត្រអភិវឌ្ឍដែនដីគូសបង្ហាញយ៉ាងច្បាស់ថា តើត្រូវធ្វើដូចម្តេច ដើម្បីសម្រេចបាននូវចក្ខុវិស័យគោលបំណងអភិវឌ្ឍរយៈពេលវែង និងគោលដៅ។ ដើម្បីឱ្យមានភាពប្រសើរឡើងនិងមានភាពស៊ីចង្វាក់គ្នា គោលដៅមួយបង្កើតចេញជាយុទ្ធសាស្ត្រនិងយុទ្ធសាស្ត្រមួយមានយុទ្ធសាស្ត្ររងមួយចំនួនដែលមានចង្កោមសកម្មភាពដែលត្រូវអនុវត្តជាក់លាក់។ គោលបំណងអភិវឌ្ឍរយៈពេលវែង គោលដៅ យុទ្ធសាស្ត្រ យុទ្ធសាស្ត្ររង និងចង្កោមសកម្មភាពបង្កើតបានជារចនាសម្ព័ន្ធអភិវឌ្ឍន៍និងអភិរក្សប្រទាក់ក្រឡាគ្នា។ យុទ្ធសាស្ត្ររង ត្រូវបានបង្កើតឡើងច្បាស់លាស់ ដើម្បីស្វែងយល់ ថ្លឹងថ្លែង និងឆ្លើយតបចំពោះជម្រើសដែលត្រូវអនុវត្ត។

### ៥.១- យុទ្ធសាស្ត្រជំរុញការអភិរក្សប្រកបដោយនិរន្តរភាពក្នុងដែនជម្រកសត្វព្រៃនិងរបៀងអភិរក្សជីវៈចម្រុះ

ការជំរុញការអភិរក្សនិងការអភិវឌ្ឍជីវភាពរស់នៅរបស់សហគមន៍នៅក្នុងតំបន់ដែនជម្រកសត្វព្រៃនិងរបៀងអភិរក្សជីវៈចម្រុះអាចសម្រេចបានតាមរយៈការអនុវត្តវិធីសាស្ត្របំពេញបន្ថែម។ វិធីសាស្ត្រទាំងនេះមានគោលបំណងពង្រឹងការការពារព្រៃឈើនៅក្នុងតំបន់ស្នូលនិងតំបន់អភិរក្សនៃដែនជម្រកសត្វព្រៃទាំងអស់ កាត់បន្ថយការដាច់ជាផ្នែកនៃព្រៃឈើ ដើម្បីអភិរក្សជីវៈចម្រុះ និងលើកស្ទួយជីវភាពរបស់ប្រជាជននៅមូលដ្ឋានតាមតំបន់ព្រៃឈើតាមរយៈសហគមន៍ក្នុងតំបន់ការពារធម្មជាតិសម្រាប់ការពង្រឹងកសិកម្មប្រកបដោយនិរន្តរភាពនៅក្នុងតំបន់សហគមន៍និងរបៀងអភិរក្សជីវៈចម្រុះ។ វិធីសាស្ត្រទាំងនេះជំរុញឱ្យមានការត្រួតពិនិត្យការបាត់បង់ព្រៃឈើនិងកម្រិតការចូលទន្ទ្រានកាន់កាប់ដីព្រៃខុសច្បាប់ក្នុងដែនជម្រកសត្វព្រៃនិងរបៀងអភិរក្សជីវៈចម្រុះ។

#### ៥.១.១- យុទ្ធសាស្ត្ររង : ជំរុញកិច្ចខិតខំប្រឹងប្រែងអភិរក្សនៅក្នុងតំបន់ស្នូលនិងតំបន់អភិរក្សក្នុងដែនជម្រកសត្វព្រៃ

- កំណត់ព្រំប្រទល់តំបន់អភិរក្សឱ្យបានច្បាស់លាស់ ជាមួយនឹងការដាក់បង្គោលសញ្ញានិងស្លាកសញ្ញា ដោយសារប្រជាជនពុំបានស្គាល់ច្បាស់ពីព្រំប្រទល់នៃតំបន់ស្នូលនិងតំបន់អភិរក្សនៅឡើយ ដូច្នេះសកម្មភាពការកំណត់ព្រំប្រទល់និងការបិទឬដាក់ស្លាកសញ្ញានេះពិតជាមានសារៈសំខាន់ណាស់។ គន្លឹះសំខាន់គឺការដាក់បង្គោលសញ្ញានិងស្លាកសញ្ញាឱ្យបានច្រើននៅជុំវិញតំបន់ស្នូលនិងតំបន់អភិរក្ស
- ធ្វើការកំណត់និងការបែងចែកតំបន់គ្រប់គ្រងដែនជម្រកសត្វព្រៃភ្នំណាមលៀរ រួមមានតំបន់ស្នូលនិងតំបន់អភិរក្ស ឱ្យបានច្បាស់លាស់
- ដំណើរការចុះបញ្ជីដីរដ្ឋនិងដីសហគមន៍ជនជាតិដើមភាគតិចទាំងអស់ដែលស្ថិតនៅក្នុងដែនជម្រកសត្វព្រៃ រួមមានតំបន់ស្នូលនិងតំបន់អភិរក្ស
- ពង្រឹងកិច្ចសហប្រតិបត្តិការរវាងមន្ទីរ ស្ថាប័នជំនាញ មន្ត្រីឧទ្យានុរក្ស អាជ្ញាធរខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ និងសហគមន៍មូលដ្ឋានពាក់ព័ន្ធ ក្នុងការគ្រប់គ្រងនិងការពារធនធានធម្មជាតិ
- ពង្រឹងការអភិរក្សព្រៃឈើតាមរយៈការផ្តួចផ្តើមគម្រោងរេដបូក ដោយត្រូវសិក្សាលទ្ធភាពបង្កើតគម្រោងរេដបូកនៅដែនជម្រកសត្វព្រៃភ្នំព្រេចនិងដែនជម្រកសត្វព្រៃស្រែពក។ ចំណុចគន្លឹះក្នុងករណីនេះគឺអាចរៀនពីបទពិសោធនៃគម្រោងរេដបូកនៅដែនជម្រកសត្វព្រៃកែវសីមា
- ធ្វើយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈស្តីពីសកម្មភាពល្មើសច្បាប់ ការធ្វើពាណិជ្ជកម្មសត្វព្រៃ ការដុតព្រៃចាប់សត្វ និងការអភិរក្សជីវៈចម្រុះ ដោយដាក់មេក្រូផ្សព្វផ្សាយតាមភូមិ ការប្រជុំផ្សព្វផ្សាយក្នុងភូមិនិងសហគមន៍ ផ្សព្វផ្សាយតាមបណ្តាញសង្គម ផ្ទាំងផ្សព្វផ្សាយ ដាក់ផែនទីនៅច្រកចេញចូលសំខាន់ៗក្នុងតំបន់ការពារ ផ្សព្វផ្សាយតាមភោជនីយដ្ឋានពាក់ព័ន្ធនឹងការបរិភោគសាច់សត្វព្រៃជាដើម
- អភិវឌ្ឍបច្ចេកវិទ្យាទំនើបសម្រាប់ឃ្លាំមើលនិងតាមដានសកម្មភាពល្មើសច្បាប់ ដោយបំពាក់កាមេរ៉ាសុវត្ថិភាពឬយន្តហោះបញ្ជាដោយម៉ាស៊ីនស្វ័យប្រវត្តិ "ដ្រូន"

- ចុះត្រួតពិនិត្យនិងល្បាតមើលសកម្មភាពបទល្មើសព្រៃឈើនៅក្នុងតំបន់ស្នូលនិងតំបន់អភិរក្ស។ សកម្មភាពទាំងនេះរាប់បញ្ចូលទាំងការរៀបចំឱ្យមានអ្នកពន្លត់ភ្លើងឆេះព្រៃនិងសម្ភារៈសម្រាប់ប្រើប្រាស់(អាជ្ញាធរមូលដ្ឋាន អង្គភាព និងស្ថាប័នពាក់ព័ន្ធ)
- បង្កើតស្ពាន ច្រករបៀង ផ្លូវរូង ដើម្បីតភ្ជាប់ផ្នែកដាច់ពីគ្នាពីតំបន់ស្នូលនិងតំបន់អភិរក្ស។ នេះជាកិច្ចការចាំបាច់ខ្លាំងដែលត្រូវតភ្ជាប់ដែនជម្រកសត្វព្រៃស្រែពកទៅនឹងដែនជម្រកសត្វព្រៃភ្នំព្រេចនិងបន្តទៅកាន់ដែនជម្រកសត្វព្រៃកែវសីមា។ មធ្យោបាយចំនួន២នៃស្ពានតភ្ជាប់នេះគឺស្ពានឆ្លងកាត់ពីលើដីនិងផ្លូវរូងក្រោមដី ក្នុងនោះផ្លូវរូងក្រោមដីជាជម្រើសដ៏ប្រសើរ
- អនុវត្តវិធានការការពារជាក់លាក់នៅទីតាំងដែលមានអេកូឡូស៊ីសំខាន់ៗក្នុងតំបន់ស្នូលនិងតំបន់អភិរក្ស
- កសាងសមត្ថភាពនិងផ្តល់នូវការបណ្តុះបណ្តាលបច្ចេកទេសល្បាតផ្សារភ្ជាប់នឹងការអនុវត្តជាក់ស្តែងការរៀបចំផែនការនិងបច្ចេកវិទ្យាទំនើបដល់មន្ត្រីឧទ្យានុរក្ស
- ដកហូតនិងប្រមូលដីរដ្ឋដែលកាន់កាប់ដោយខុសច្បាប់មកគ្រប់គ្រងជាដីរដ្ឋឡើងវិញ ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

### ៥.១.២- យុទ្ធសាស្ត្រ៖ លើកកម្ពស់ការគ្រប់គ្រងព្រៃឈើដោយសហគមន៍មូលដ្ឋាននិងពង្រឹងកសិកម្មបែបធម្មជាតិនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនិងតំបន់សហគមន៍ក្នុងដែនជម្រកសត្វព្រៃ(ការប្រើប្រាស់ដីសហគ្រប់គ្រង)

- កំណត់និងបែងចែកតំបន់គ្រប់គ្រងដែនជម្រកសត្វព្រៃភ្នំណាមលៀរ រួមមានតំបន់ប្រើប្រាស់ដោយចីរភាពនិងតំបន់សហគមន៍ ឱ្យបានច្បាស់លាស់
- ជំរុញគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពតាមរយៈសហគមន៍តំបន់ការពារធម្មជាតិ(CPA) សម្រាប់ការការពារព្រៃឈើនិងព្រៃឈើសេដ្ឋកិច្ចគ្រប់គ្រងដោយសហគមន៍( ឈើហ៊ុបនិងអនុផលព្រៃឈើ)។ បន្ថែមលើការបង្រួមព្រំប្រទល់និងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិដែលមានស្រាប់ ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិថ្មីអាចត្រូវបានប្រមើលមើលនិងបង្កើតឡើងនៅក្នុងតំបន់ពីរផ្សេងពីគ្នាដែលមានសក្តានុពលអាចបង្កើតបាន
- កំណត់ព្រំប្រទល់តំបន់ប្រើប្រាស់ដោយចីរភាពឱ្យបានច្បាស់លាស់ ដោយដាក់បង្គោលសញ្ញានិងស្លាកសញ្ញាឱ្យបានច្រើន។ ដូចគ្នានឹងករណីកំណត់ព្រំប្រទល់តំបន់ស្នូលនិងតំបន់អភិរក្សដែរដោយសារប្រជាជនពុំបានស្គាល់ច្បាស់ពីព្រំប្រទល់តំបន់ប្រើប្រាស់ដោយចីរភាពនិងតំបន់សហគមន៍នៅឡើយ។ គន្លឹះសំខាន់គឺការដាក់បង្គោលសញ្ញានិងស្លាកសញ្ញាឱ្យបានច្រើននៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនិងតំបន់សហគមន៍
- រៀបចំផែនការប្រើប្រាស់ដីលម្អិតនិងភ្ជាប់ដោយបញ្ញត្តិគ្រប់គ្រងសម្រាប់តំបន់សហគមន៍ជនជាតិដើមភាគតិច ដើម្បីកំណត់តំបន់ប្រើប្រាស់ដីនាពេលអនាគត រួមមានតំបន់កសិកម្ម តំបន់លំនៅឋាននិងតំបន់ព្រៃឈើការពារជាដើម
- ដំណើរការចុះបញ្ជីដីធ្លីទាំងដីរដ្ឋ ដីសហគមន៍ជនជាតិដើមភាគតិច និងដីឯកជនដែលស្ថិតនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនិងតំបន់សហគមន៍នៃដែនជម្រកសត្វព្រៃ

- លើកកម្ពស់ប្រពលវប្បកម្មកសិកម្មបែបធម្មជាតិក្នុងតំបន់សហគមន៍តាមរយៈការអនុវត្តបច្ចេកទេស ដូចជាការដាំដុះដោយមិនភ្ជួររាស់ដី ការដាំដំណាំគម្របដីជាអចិន្ត្រៃយ៍ កាត់បន្ថយការប្រើប្រាស់ថ្នាំពុលនិងជីគីមី។ គន្លឹះសំខាន់គឺគ្រប់គ្រងជីវជាតិដីនិងប្រភពទឹកសម្រាប់ការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាព
- កសាងអាងស្តុកទឹកនិងប្រព័ន្ធធារាសាស្ត្រដែលមានតម្លៃសមរម្យនៅតាមប្រភពទឹក ដើម្បីរក្សាទឹកទុកសម្រាប់ដោះស្រាយពេលមានគ្រោះរាំងស្ងួត។ អាងស្តុកទឹកទាំងនេះអាចជួយកាត់បន្ថយគ្រោះទឹកជំនន់ផងដែរ។ ដូច្នេះករណីនេះ អាងស្តុកទឹកនិងប្រព័ន្ធធារាសាស្ត្រនឹងជួយកាត់បន្ថយផលប៉ះពាល់និងបន្សុំានឹងការប្រែប្រួលអាកាសធាតុ
- អនុវត្តវិធានការការពារជាក់លាក់សម្រាប់ធ្វើការវាយតម្លៃទីតាំងដែលមានជីវៈចម្រុះសំខាន់ៗនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនិងតំបន់សហគមន៍
- ផ្តល់ការបណ្តុះបណ្តាលទូលំទូលាយអំពីបច្ចេកទេសកសិកម្មប្រកបដោយនិរន្តរភាពដល់កសិករខ្នាតតូចលើការគ្រប់គ្រងដីនិងទឹក ការផលិតគ្រាប់ពូជ ឧបករណ៍កសិកម្ម ទីផ្សារ។ល។
- លើកកម្ពស់ការអនុវត្តលើការប្រើប្រាស់និងផលិតកម្មប្រកបដោយនិរន្តភាព(SCP)ភ្ជាប់ជាមួយការតម្រង់ទិសសម្រាប់ប្រើប្រាស់ដែលបានផ្តួចផ្តើមដោយក្រសួងបរិស្ថាននិងស្របតាមគោលការណ៍កសិកម្មបែបធម្មជាតិ ដើម្បីធានាបានសុខភាព សុវត្ថិភាពនៃការប្រើប្រាស់និងប្រព័ន្ធផលិតកម្មចំណីអាហារប្រកបដោយនិរន្តរភាពដែលមានផលប៉ះពាល់តិចតួចលើធនធានធម្មជាតិនិងបរិស្ថាន
- ដកហូតនិងប្រមូលដីរដ្ឋដែលកាន់កាប់ដោយខុសច្បាប់មកគ្រប់គ្រងជាដីរដ្ឋឡើងវិញ ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ៥.១.៣- យុទ្ធសាស្ត្ររង : ធានាឱ្យបាននូវការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាពនិងការពារព្រៃឈើនៅក្នុងរបៀងអភិរក្សជីវៈចម្រុះ

- ធ្វើសារពើភណ្ឌធនធាននៅក្នុងរបៀងអភិរក្សជីវៈចម្រុះជាភស្តុតាង ដើម្បីរៀបចំបង្កើតផែនការគ្រប់គ្រងជាក់លាក់
- ធានាឱ្យបាននូវការអភិរក្សធនធានធម្មជាតិ ដើម្បីបន្តរក្សាកិច្ចខិតខំប្រឹងប្រែងអភិរក្សនៅក្នុងតំបន់ការពារធម្មជាតិ។ ខេត្តមណ្ឌលគិរីមានសក្តានុពលមានកំណត់ ដើម្បីបង្កើតរបៀងអភិរក្សឆ្លងខេត្តនៅតំបន់ដែលមានសក្តានុពលសមស្របសម្រាប់បង្កើតរបៀងអភិរក្សឆ្លងខេត្តគួរធ្វើនៅចន្លោះដែនជម្រកសត្វព្រៃលំផាត់និងដែនជម្រកសត្វព្រៃភ្នំព្រេច។ ប៉ុន្តែរបៀងអភិរក្សនេះនឹងប្រឈមជាមួយសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់និងគម្រោងអភិវឌ្ឍបណ្តាញផ្លូវនាពេលអនាគត
- រៀបចំផែនការប្រើប្រាស់ដីលម្អិតនិងភ្ជាប់ដោយបញ្ញត្តិគ្រប់គ្រងសម្រាប់របៀងអភិរក្សជីវៈចម្រុះដើម្បីកំណត់តំបន់ប្រើប្រាស់ដីនាពេលអនាគត ដូចជាតំបន់កសិកម្ម តំបន់លំនៅឋាន និងតំបន់ព្រៃឈើការពារ និងបង្កើតនូវគោលការណ៍ណែនាំច្បាស់លាស់សម្រាប់ការចេញប័ណ្ណកម្មសិទ្ធិ
- បង្កើតគណៈកម្មាធិការគ្រប់គ្រងជាក់លាក់សម្រាប់របៀងអភិរក្សជីវៈចម្រុះ ដូចបានណែនាំដោយក្រសួងបរិស្ថាន។ ពង្រឹងក្រុមល្បាត ដោយមានកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងសហគមន៍មូលដ្ឋាននិងភាគីពាក់ព័ន្ធនានា

- លើកកម្ពស់វិធានការប្រពលវប្បកម្មកសិកម្មបែបធម្មជាតិនៅក្នុងប្រព័ន្ធប្រើប្រាស់ដីកសិកម្មរបស់កសិករខ្នាតតូច រួមមានការមិនភ្ជួររាស់ដី ដាំដំណាំគម្របដីជាអចិន្ត្រៃយ៍ កាត់បន្ថយការប្រើប្រាស់ជីគីមីនិងថ្នាំពុលជាដើម
- កសាងអាងស្តុកទឹកនិងប្រព័ន្ធធារាសាស្ត្រដែលមានតម្លៃសមរម្យនៅតាមប្រភពទឹក ដើម្បីរក្សាទឹកទុកនិងដោះស្រាយពេលមានគ្រោះរាំងស្ងួត។ អាងស្តុកទឹកទាំងនេះក៏ជួយកាត់បន្ថយគ្រោះទឹកជំនន់ផងដែរ។ អាងស្តុកទឹកនិងប្រព័ន្ធធារាសាស្ត្រនឹងជួយកាត់បន្ថយផលប៉ះពាល់និងបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ
- ផ្តល់ការបណ្តុះបណ្តាលទូលំទូលាយអំពីបច្ចេកទេសកសិកម្មប្រកបដោយនិរន្តរភាពដល់កសិករខ្នាតតូចលើការគ្រប់គ្រងដីនិងទឹក ការផលិតគ្រាប់ពូជ ឧបករណ៍កសិកម្ម ទីផ្សារ ខ្សែច្រវាក់តម្លៃផលិតផលកសិកម្ម។ល។
- ត្រូវបញ្ចប់ការពង្រីកផ្ទៃដីកសិកម្មដែលគ្មានផែនការគ្រោងទុកច្បាស់លាស់
- ទប់ស្កាត់ការពង្រីកដីកសិកម្មចូលក្នុងប្រភេទដីព្រៃឈើនិងទប់ស្កាត់ការប្តូរប្រភេទដីកសិកម្មទៅជាដីសាងសង់
- ត្រូវរក្សាស្ថានភាពភូមិសាស្ត្រនិងទេសភាពធម្មជាតិតំបន់ខ្ពង់រាបក្នុងការធ្វើកសិកម្ម
- ចុះបញ្ជីនិងកំណត់ប្រភេទដីកសិកម្ម។

### ៥.១.៤- យុទ្ធសាស្ត្ររង : ការពារតំបន់ទេសភាពដែលជាផ្នែកមួយនៃអត្តសញ្ញាណបរិស្ថាន សង្គម និងវប្បធម៌របស់ខេត្តមណ្ឌលគិរី

- កំណត់តំបន់ការពារទេសភាពនិងបង្កើតក្របខ័ណ្ឌគតិយុត្តគ្រប់គ្រង ដើម្បីកំណត់ប្រភេទនៃការប្រើប្រាស់ដីសម្រាប់ការអភិវឌ្ឍនិងការអភិរក្សអត្តសញ្ញាណភូមិសាស្ត្រ ក្នុងតំបន់ទេសភាពទាំងនេះ៖
  - ក្រុងសែនមនោរម្យ មានសមុទ្រឈើ ភ្នំបាយឆៅ ភ្នំពូតាំង ភ្នំដោះក្រមុំ វាលស្មៅលឹងល្វើយ ព្រៃស្រល់ជាដើម
  - ស្រុកកោះញែក មានតំបន់ទេសភាពនៃបឹងលិចទឹកនិងជាជម្រកសត្វស្លាបតូចៗ
  - ស្រុកពេជ្រាដា មានតំបន់ទឹកជ្រោះប៊ូស្រា តំបន់ទឹកធ្លាក់អូរផ្លាយ
  - ស្រុកអូររាំង មានតំបន់តាមដងផ្លូវពីស្រុកអូររាំងមកកាន់ក្រុងសែនមនោរម្យជាតំបន់ដែលមានទេសភាពដ៏ត្រកាល ព្រមទាំងមានព្រៃស្រល់ធំទូលាយដែលជាប្រព័ន្ធព្រៃឈើតែមួយគត់នៅប្រទេសកម្ពុជានិងជាអត្តសញ្ញាណយ៉ាងសំខាន់សម្រាប់ខេត្តមណ្ឌលគិរី។
- កំណត់ទីតាំងប្រភពទឹក អាងស្តុកទឹកធម្មជាតិ និងតំបន់ធម្មជាតិជុំវិញ៖
  - ក្រុងសែនមនោរម្យ មានព្រែកទេរ ទំនប់ស្នាក់ទឹកដាក់ដៀរ ទំនប់ស្នាក់ទឹកជ្រោះក្បាលព្រះ អូរត្រកអូរម្លេង អូរកុស អូរឡឿ អូរក្រពើ អូររាំងជាដើម
  - ស្រុកកែវសីមា មានព្រែកឆ្នូង ទំនប់ស្នាក់ទឹកដាក់ដៀរជាដើម
  - ស្រុកអូររាំង មានអូរទេរ អូរផ្លាយ អូរជក អូរដាក់ដាង អូរត្លួស អូរហុច ទឹកធ្លាក់លេងអងលែងឃិន ទឹកធ្លាក់៧ជំណាក់ ទឹកធ្លាក់ជ្រៃធំ ទំនប់ស្នាក់ទឹកអូរត្លួស ត្រពាំងត្លួសជាដើម

- ស្រុកពេជ្រាដា មានព្រែកពោធិ៍ ព្រែកដាក់ច្រិត អូរនកាន អូរទា អូររវ៉ាត អូរណាំង អូរនជ្រល់ អូរផ្លាយ ជាដើម
- ស្រុកកោះញែក មានទន្លេស្រែពក ព្រែកព្រះ ព្រែករវ៉ាក់ ព្រែកច្បារ ព្រែកត្រាវ ព្រែកត្រមេត ព្រែករវៃ ព្រែកណាមលៀរ ព្រែកយាឡៅផ្ទះ ព្រែករោយ ព្រែកទៀន អូរកោះញែក អូរធំ អូរកាម អូរជ័រ អូរដងពក អូរសាយជាដើម(ដូចមានបញ្ជីក្នុងឧបសម្ព័ន្ធ៧)។

- កំណត់ទីតាំងភ្នំសំខាន់ៗ៖
  - ក្រុងសែនមនោរម្យ មានភ្នំដោះក្រមុំ ភ្នំបាយឆៅជាដើម
  - ស្រុកកែវសីមា មានភ្នំកែវសីមា ភ្នំគូសជាដើម
  - ស្រុកអូររាំង មានភ្នំអណ្ដូងស្នេហ៍ ភ្នំយោគយ៉ៅ(ភ្នំខ្លា) ភ្នំណល់ទឹត ភ្នំចុតម្លុង ភ្នំរតាប់ ភ្នំឡាវរីក ភ្នំកុងក្លៃ ភ្នំអូមត្រូន ភ្នំគង់ក្ងាច់ ភ្នំដាញ ភ្នំគង់ក្លេល ភ្នំស្រែះចត ភ្នំរលូវផៃ ភ្នំព្រីក(តំបន់ទេសចរណ៍សត្វទោច) ភ្នំបារាំងស៊ុំ ភ្នំគង់រញ្ជូងជាដើម
  - ស្រុកពេជ្រាដា មានភ្នំណាមលៀរ ភ្នំលុប្រាណ ភ្នំមុសរលួង ភ្នំអូរទេរជាដើម
  - ស្រុកកោះញែក មានភ្នំណាមរ៉ាម ភ្នំក្អូន ភ្នំក្រោលជាដើម។
- កំណត់ទីតាំង កសាងបញ្ជី និងចុះបញ្ជីសារពើភណ្ឌតំបន់ការពារទេសភាពដែលជាអត្តសញ្ញាណបរិស្ថាន សង្គម និងវប្បធម៌របស់ខេត្តមណ្ឌលគិរី(ដូចមានបញ្ជីក្នុងឧបសម្ព័ន្ធ៨) និងតំបន់ដែលមានទេសភាពពិសេសផ្សេងទៀតដែលត្រូវការពារ។

## ៥.២- យុទ្ធសាស្ត្រកម្រិតផលប៉ះពាល់អវិជ្ជមានលើសេដ្ឋកិច្ច បរិស្ថាន និងសង្គមនៃគម្រោងអភិវឌ្ឍខ្នាតធំ

គម្រោងរ៉ែនិងទំនប់វារីអគ្គិសនីមានផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងទៅលើធនធានធម្មជាតិដែលស្ថិតនៅក្នុងដែនជម្រកសត្វព្រៃនិងរបៀងអភិរក្សជីវៈចម្រុះ ក៏ដូចជាជីវភាពរស់នៅរបស់ប្រជាជនក្នុងខេត្តមណ្ឌលគិរី។ ការកំណត់បាននូវអត្តសញ្ញាណនៃផលប៉ះពាល់ច្បាស់លាស់និងការត្រួតពិនិត្យយ៉ាងតឹងរឹងគឺចាំបាច់ណាស់ ដើម្បីកាត់បន្ថយផលប៉ះពាល់ទាំងនេះ ស្របពេលដែលអាចរក្សាបាននូវសក្ដានុពលសម្រាប់ការអភិវឌ្ឍបៃតងនៅក្នុងខេត្តមណ្ឌលគិរី។ ដោយសារប្រតិបត្តិការទាញយករ៉ែ(ការស្វែងរុករកឬការធ្វើអាជីវកម្ម) នៅក្នុងខេត្តមណ្ឌលគិរីមានទំហំដ៏ធំ ការផ្ដោតសំខាន់ជាយុទ្ធសាស្ត្រលើការត្រួតពិនិត្យនិងការកាត់បន្ថយផលប៉ះពាល់លើវិស័យនេះតម្រូវឱ្យមានជាចាំបាច់។

### ៥.២.១- យុទ្ធសាស្ត្ររង : កម្រិតផលប៉ះពាល់អវិជ្ជមាននៃប្រតិបត្តិការទាញយករ៉ែ

- ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដោយនីតិបុគ្គលសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដែលមានជំនាញវិជ្ជាជីវៈច្បាស់លាស់និងទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ចក្នុងភាពជាដៃគូជិតស្និទ្ធនិងការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន។ ផលប៉ះពាល់អាចប្រែប្រួលទៅតាមទីតាំងនិងការប្រើប្រាស់ដីជុំវិញ។ ការយកចិត្តទុកដាក់ជាពិសេសគួរត្រូវបានផ្ដោតលើការគ្រប់គ្រងតំបន់ស្នូល ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ប្រភពទឹក ជីកសិកម្ម ឬផ្នែកដាច់ពីគ្នានៃព្រៃឈើ

- រៀបចំក្របខ័ណ្ឌគតិយុត្ត ដើម្បីកាត់បន្ថយផលប៉ះពាល់លើជីវៈចម្រុះសម្រាប់ប្រតិបត្តិការទាញយករ៉ែ
- ត្រួតពិនិត្យប្រតិបត្តិការនិងការធ្វើអាជីវកម្មរ៉ែយ៉ាងទៀងទាត់ដោយអ្នកជំនាញដែលមានវិជ្ជាជីវៈនិងទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ច
- ស្វែងរកកិច្ចសហការរវាងក្រុមហ៊ុនវិនិយោគរ៉ែជាមួយនឹងសហគមន៍ក្នុងទម្រង់ជាសហគមន៍រ៉ែ ដើម្បីជំរុញយន្តការចែករំលែកផលប្រយោជន៍រួមគ្នា
- បង្កើតនិងអនុវត្តវិធានការស្តារឡើងវិញក្រោយការធ្វើអាជីវកម្មឱ្យបានច្បាស់លាស់ រួមបញ្ចូលផែនការសកម្មភាពលើជីវៈចម្រុះ ដើម្បីស្តារតំបន់នោះឡើងវិញសម្រាប់ប្រជាជនមូលដ្ឋានបន្ទាប់ពីប្រតិបត្តិការទាញយករ៉ែរួច
- កាត់បន្ថយចំនួនអាជ្ញាបណ្ណស្វែងរុករករ៉ែឬអាជីវកម្មរ៉ែបុកស៊ីតនៅប៉ែកអាគ្នេយ៍នៃខេត្តមណ្ឌលគិរី។ សុពលភាពនៃអាជ្ញាបណ្ណដែលបានផ្តល់ដល់ក្រុមហ៊ុននៅស្រុកអូររាំងនិងក្រុងសែនមនោរម្យគួរត្រូវបានធ្វើការពិចារណាឡើងវិញ ប្រសិនបើប្រតិបត្តិការស្វែងរុករករ៉ែឬធ្វើអាជីវកម្មរ៉ែបុកស៊ីតមានផលប៉ះពាល់ដល់បរិស្ថាន ធនធានធម្មជាតិ ធនធានទឹក និងព្រៃឈើ ក៏ដូចជាលើជីវភាពរស់នៅរបស់ប្រជាជន សត្វ និងសក្តានុពលសម្រាប់ការអភិវឌ្ឍអេកូទេសចរណ៍ក្នុងតំបន់។

### ៥.២.២- យុទ្ធសាស្ត្ររង : កម្រិតផលប៉ះពាល់អវិជ្ជមាននៃគម្រោងអភិវឌ្ឍទំនប់វារីអគ្គិសនី

- ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដោយនីតិបុគ្គលសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដែលមានជំនាញវិជ្ជាជីវៈច្បាស់លាស់និងទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ច ក្នុងភាពជាដៃគូជិតស្និទ្ធនិងការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋានសម្រាប់ស្នើសុំសាងសង់ទំនប់វារីអគ្គិសនី
- ត្រួតពិនិត្យប្រតិបត្តិការនិងការធ្វើអាជីវកម្មយ៉ាងទៀងទាត់នៃគម្រោងទំនប់វារីអគ្គិសនីដែលកំពុងដំណើរស្រាប់
- កំណត់និងសាកល្បងប្រភពថាមពលកកើតឡើងវិញដែលមាននិរន្តរភាពផ្សេងទៀត ដូចជាថាមពលពន្លឺព្រះអាទិត្យ ថាមពលខ្យល់ជាដើម។

## ៥.៣- យុទ្ធសាស្ត្រគាំទ្រការបង្កើតមជ្ឈមណ្ឌលអប់រំអំពីការអភិរក្សធនធានធម្មជាតិនិងលើកកម្ពស់ការសិក្សាស្រាវជ្រាវអំពីជីវៈចម្រុះនិងការអភិរក្សប្រកបដោយនិរន្តរភាព

ខេត្តមណ្ឌលគិរីគឺជាទីតាំងសមស្របមួយ ដើម្បីស្នើសុំបង្កើតឱ្យមានមជ្ឈមណ្ឌលអប់រំចម្រុះនិងសម្បូរបែបទាក់ទងនឹងការគ្រប់គ្រងជីវៈចម្រុះនិងធនធានធម្មជាតិដែលអាចរួមបញ្ចូលទាំងគ្រឿងបរិក្ខារសម្រាប់ការបោះជុំរំវិស្សមកាល អគារសម្រាប់មន្ទីរពិសោធន៍ស្រាវជ្រាវ រៀបចំសិក្ខាសាលា និងកន្លែងចុះអនុវត្តនិងសិក្សាស្រាវជ្រាវនៅទីវាលជាក់ស្តែង។

### ៥.៣.១- យុទ្ធសាស្ត្ររង : លើកកម្ពស់ការសិក្សានៅទីវាលជាក់ស្តែងអំពីជីវៈចម្រុះ

- កំណត់តំបន់សម្រាប់ធ្វើការសាងសង់មជ្ឈមណ្ឌលធនធានសម្រាប់ការបណ្តុះបណ្តាលនិងតំបន់សិក្សាស្រាវជ្រាវនៅទីវាល

- កំណត់ទីតាំងសមស្របសម្រាប់បង្កើតជាសួនបូតានិចឬសួនរុក្ខជាតិ(Botanical Garden)
- សហការជាមួយភ្នាក់ងារជាតិនិងអន្តរជាតិ ដើម្បីអភិវឌ្ឍមូលធនមនុស្ស លើកកម្ពស់ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍលើជំនាញអភិរក្សជីវៈចម្រុះនិងធនធានធម្មជាតិ។

## ៥.៤- យុទ្ធសាស្ត្រពង្រីកការអភិវឌ្ឍអេកូទេសចរណ៍ដោយផ្សារភ្ជាប់នឹងការគ្រប់គ្រងធនធានធម្មជាតិ និងការអភិរក្សវប្បធម៌ប្រកបដោយនិរន្តរភាព

វិស័យទេសចរណ៍ទូទៅ អេកូទេសចរណ៍ និងទេសចរណ៍វប្បធម៌គឺជាវិស័យគន្លឹះមួយសម្រាប់ការអភិវឌ្ឍខេត្តមណ្ឌលគិរីនាពេលអនាគត។ ការអភិវឌ្ឍវិស័យទេសចរណ៍មានអត្ថប្រយោជន៍ដល់វិស័យនិងសេវាកម្មផ្សេងៗយ៉ាងច្រើន។ ការអភិវឌ្ឍវិស័យនេះក៏នាំមកនូវហានិភ័យច្រើនដល់ធនធានធម្មជាតិនិងការការពារអត្តសញ្ញាណរបស់ជនជាតិដើមភាគតិចនៅក្នុងខេត្តមណ្ឌលគិរីផងដែរ។ ហានិភ័យទាំងនេះចាំបាច់ត្រូវកំណត់និងកាត់បន្ថយតាមរយៈវិធានការសមស្របនានា។ វិធានជាយុទ្ធសាស្ត្រសំខាន់មួយគឺជំរុញការអនុវត្តផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ ការចុះបញ្ជីតំបន់ទេសចរណ៍ដែលមានស្រាប់និងតំបន់មានសក្តានុពលទេសចរណ៍ រៀបចំផែនការប្រើប្រាស់ដីក្នុងតំបន់ទេសចរណ៍ឱ្យបានច្បាស់លាស់ និងរៀបចំផែនការគ្រប់គ្រងបច្ចេកទេសសម្រាប់តំបន់នីមួយៗ ព្រមទាំងរៀបចំបណ្តាញផ្លូវសម្រាប់ភ្ញៀវទេសចរ ដើម្បីតភ្ជាប់ពីតំបន់ទេសចរណ៍មួយទៅតំបន់ទេសចរណ៍មួយទៀតស្របតាមស្ថានភាពតំបន់ឬទីកន្លែង។ ឧទាហរណ៍ការជិះកង់លើភ្នំឬដើរឡើងភ្នំជាទម្រង់វិលជុំរយៈពេល២ថ្ងៃ ដោយចេញពីឬក៏ត្រឡប់មកវិញក្រុងសែនមនោរម្យឆ្លោះទៅទីតាំងផ្ទះស្នាក់(Homestay) ក្នុងភូមិជនជាតិដើមភាគតិចនិងទៅកន្លែងផ្សេងៗទៀតជាដើម។

### ៥.៤.១- យុទ្ធសាស្ត្ររង : លើកកម្ពស់ការអភិវឌ្ឍវិស័យអេកូទេសចរណ៍

- បញ្ជ្រាបការយល់ដឹងនិងការប្រតិបត្តិអេកូទេសចរណ៍ជាទេសចរណ៍ដែលស្រឡាញ់ធម្មជាតិ មានគោលដៅសិក្សា សង្កេត ស្រាវជ្រាវ ពិសោធន៍។ល។ លើធម្មជាតិ ភូមិសាស្ត្រ និងជីវៈចម្រុះ ដោយមិនប៉ះពាល់ដល់ការអភិរក្សនិងការរីកចម្រើននៃធម្មជាតិប្រកបដោយចីរភាព
- កំណត់និងចុះបញ្ជីតំបន់អេកូទេសចរណ៍មានស្រាប់ទាំងអស់និងតំបន់មានសក្តានុពលអេកូទេសចរណ៍ផ្សេងទៀត ដើម្បីរៀបចំបង្កើតផែនការគ្រប់គ្រង រួមទាំងការដាក់វិធានបរិស្ថាន កម្រិតផលប៉ះពាល់នានាដែលបណ្តាលមកពីសកម្មភាពទេសចរណ៍
- ជំរុញអភិវឌ្ឍផ្លូវរបៀងទេសចរណ៍តភ្ជាប់ពីក្រុងសែនមនោរម្យទៅទឹកជ្រោះប៊ូស្រា ភ្នំណាមលៀរ ភូមិវប្បធម៌ដាក់ដាំ និងត្រឡប់មកក្រុងសែនមនោរម្យវិញ។ ផ្លូវរបៀងទេសចរណ៍នេះ ស្របគ្នាទៅនឹងរបៀងទេសចរណ៍ប៊ូស្រា- ដាក់ដាំដែលបានកំណត់នៅក្នុងផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ ហើយផ្តល់នូវសក្តានុពលដ៏សំខាន់សម្រាប់ដំណើរទេសចរណ៍ ដោយសារផ្លូវរបៀងនេះបានតភ្ជាប់ទាំងរមណីយដ្ឋានមានបរិស្ថាន ទេសភាពល្អឯក និងមានវប្បធម៌ពិសេស
- ជំរុញរៀបចំនិងអនុវត្តផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី។

### ៥.៤.២- យុទ្ធសាស្ត្ររង : លើកកម្ពស់ការអភិវឌ្ឍវិស័យទេសចរណ៍វប្បធម៌ជនជាតិដើមភាគតិច

- បញ្ជ្រាបការយល់ដឹងនិងការប្រតិបត្តិទេសចរណ៍វប្បធម៌ជនជាតិដើមភាគតិចជាទេសចរណ៍ដែលលើកកម្ពស់ការថែរក្សាអត្តសញ្ញាណវប្បធម៌ជនជាតិដើមភាគតិច មានគោលដៅសិក្សា សង្កេត ស្រាវជ្រាវ ពិសោធន៍។ល។ លើអត្តសញ្ញាណវប្បធម៌និងសង្គមរស់នៅរបស់ជនជាតិដើមភាគតិច ដោយធានានិរន្តរភាពដល់អត្តសញ្ញាណវប្បធម៌ជនជាតិដើមភាគតិច
- កំណត់និងចុះបញ្ជីទីតាំងបេតិកភណ្ឌវប្បធម៌រូបីនិងអរូបីរបស់ជនជាតិដើមភាគតិចនៅក្នុងខេត្តមណ្ឌលគិរី ដូចជាទីតាំងប្រតិបត្តិជំនឿ សាសនា សិល្បៈ និងវប្បធម៌ ព្រមទាំងរៀបចំបង្កើតផែនការគ្រប់គ្រងទេសចរណ៍វប្បធម៌
- ពង្រឹងការការពារជំនឿ ទីសក្ការៈបូជា ព្រៃអារក្សរបស់ជនជាតិដើមភាគតិចជាតំបន់បេតិកភណ្ឌជាតិ
- សិក្សា ស្រាវជ្រាវ និងចងក្រងឯកសារពាក់ព័ន្ធនឹងប្រពៃណី ទំនៀមទម្លាប់ និងភាសារបស់ជនជាតិដើមភាគតិចនីមួយៗ
- ជំរុញរៀបចំនិងអនុវត្តផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី។

### ៥.៤.៣- យុទ្ធសាស្ត្ររង : លើកកម្ពស់ការអភិវឌ្ឍវិស័យសេវាកម្មនិងផលិតផលទេសចរណ៍

- រៀបចំកញ្ចប់ដំណើរកម្សាន្តនិងផែនទីណែនាំគោលដៅទេសចរណ៍សម្រាប់ភ្ញៀវទេសចរនិងរៀបចំបណ្តាញផ្លូវសម្រាប់ភ្ញៀវទេសចរ ដើម្បីតភ្ជាប់ពីតំបន់ទេសចរណ៍មួយទៅតំបន់ទេសចរណ៍មួយទៀត រួមជាមួយនឹងការផ្តល់សេវាកម្ម ម្ហូបអាហារ និងកន្លែងស្នាក់នៅសមរម្យ
- ផ្តល់សេវាកម្មអភិវឌ្ឍសមត្ថភាពលើប្រធានបទពាក់ព័ន្ធនឹងការគ្រប់គ្រងអេកូទេសចរណ៍និងទេសចរណ៍វប្បធម៌ដល់ប្រជាសហគមន៍ អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធដទៃទៀតក្នុងវិស័យទេសចរណ៍
- រៀបចំបណ្តុះបណ្តាលជាទម្រង់សិល្បៈសម្តែងអំពីទំនៀមទម្លាប់ប្រពៃណីរបស់ជនជាតិដើមភាគតិចនីមួយៗ
- ជំរុញរៀបចំនិងអនុវត្តផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី។

## ៥.៥- យុទ្ធសាស្ត្រគាំទ្រការអភិវឌ្ឍមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដែលលើកកម្ពស់ដល់សេវាកម្មនិងផលិតផលទេសចរណ៍ផ្អែកលើធនធានមូលដ្ឋាន

ការអភិវឌ្ឍវិស័យទេសចរណ៍ដែលផ្សារភ្ជាប់នឹងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយបរិយាបន្ន តម្រូវឱ្យមានការអភិវឌ្ឍជំនាញនិងចំណេះដឹងដល់សហគមន៍មូលដ្ឋាន។ នេះជាកត្តាដ៏ចម្បងក្នុងវិស័យដែលប្រជាសហគមន៍មានទំនាក់ទំនងផ្ទាល់ជាមួយភ្ញៀវទេសចរ ដូចជាការផ្តល់សេវាកម្មស្នាក់នៅ ម្ហូបអាហារ និងការរៀបចំកញ្ចប់ទេសចរណ៍ជាដើម ឬក្នុងវិស័យទាំងឡាយដែលពាក់ព័ន្ធនឹងការផលិត ការលក់ដូរផលិតផលឬវត្ថុអនុស្សាវរីយ៍ដែលជាតម្រូវការឬការចាប់អារម្មណ៍ពីភ្ញៀវទេសចរ។ ការផ្តល់សេវាកម្មប្រកបដោយគុណភាពក្នុងវិស័យនេះគឺជាកត្តាគន្លឹះ ដើម្បីធានានូវការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព។ ដូច្នេះ ការបណ្តុះបណ្តាលចាំបាច់នានាគួរឆ្លើយតបនឹងតម្រូវការរបស់ប្រជាសហគមន៍មូលដ្ឋាន ដើម្បីបំពេញតម្រូវការទាំងនេះ។

**៥.៥.១- យុទ្ធសាស្ត្ររង : កំណត់គម្រោង រៀបចំគម្រោង និងអនុវត្តការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីអភិវឌ្ឍជំនាញចាំបាច់ដល់ការគ្រប់គ្រងទេសចរណ៍សហគមន៍មូលដ្ឋាន**

- សិក្សាវាយតម្លៃពីតម្រូវការនៃការអភិវឌ្ឍជំនាញនិងចំណេះដឹងក្នុងវិស័យទេសចរណ៍
- រៀបចំកម្មវិធីនិងវគ្គបណ្តុះបណ្តាលអំពីជំនាញគ្រប់គ្រងក្នុងផ្នែកផ្តល់សេវាកម្មស្នាក់នៅនិងម្ហូបអាហារ ដូចជាការគ្រប់គ្រងអាជីវកម្ម មុខម្ហូប ការផ្សាយពាណិជ្ជកម្មនិងទំនាក់ទំនង បដិសណ្ឋារកិច្ចនិងកសាងទំនាក់ទំនងជាមួយភ្ញៀវទេសចរ ការថែទាំនិងអនាម័យ ភាសាបរទេស ការសាងសង់ផ្ទះសំណាក់ដែលមានផាសុកភាពបែបធម្មជាតិជាដើម
- ពង្រឹងកិច្ចការពារទីតាំងប្រតិបត្តិជំនឿ ទីសក្ការបូជា ព្រៃតំណម ព្រៃអារក្សរបស់ជនជាតិដើមភាគតិចដែលជាសម្បត្តិបេតិកភណ្ឌជាតិ
- រៀបចំកម្មវិធីនិងវគ្គបណ្តុះបណ្តាលអំពីជំនាញគ្រប់គ្រង ដើម្បីគាំទ្រដល់ការរៀបចំកញ្ចប់ទេសចរណ៍សម្រាប់ភ្ញៀវទេសចរ ដូចជាជំនាញភាសា ការនាំភ្ញៀវទេសចរ សេវាជួលនិងជួសជុល ឧទាហរណ៍ កង់ ម៉ូតូ និងសម្ភារៈបោះតង់ជាដើម និងការថតរូបទេសភាពជាដើម។

**៥.៥.២- យុទ្ធសាស្ត្ររង : កំណត់គម្រោង រៀបចំគម្រោង និងអនុវត្តការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីលើកកម្ពស់ផលិតផលរបស់ខេត្តមណ្ឌលគិរី**

- សិក្សាអំពីតម្រូវការទីផ្សារនិងតម្រូវការរបស់អតិថិជនពីប្រភេទផលិតផលដែលជាការចាប់អារម្មណ៍របស់ភ្ញៀវទេសចរ ដូចជាផលិតផលពីកសិកម្ម សិប្បកម្មជាដើម និងពីវិធីសាស្ត្រកែលម្អខ្សែច្រវាក់ផលិតកម្ម
- រៀបចំកម្មវិធីនិងវគ្គបណ្តុះបណ្តាលស្តីពីជំនាញ ដើម្បីលើកកម្ពស់ផលិតកម្ម ការវេចខ្ចប់ ការដឹកជញ្ជូន ការផ្សព្វផ្សាយ និងការលក់ដូរនូវផលិតផលទាំងនេះ។

## ៥.៦- យុទ្ធសាស្ត្រជំរុញការអភិវឌ្ឍកសិកម្មខ្នាតតូចប្រកបដោយនិរន្តរភាពសម្រាប់កសិករ

កត្តាគន្លឹះគឺការធានាថា ប្រជាជនប្រកបរបរកសិកម្មនៅខេត្តមណ្ឌលគិរីអាចចិញ្ចឹមជីវិតពីកសិកម្មនៅលើដីដែលស្ថិតនៅខាងក្រៅដែនជម្រកសត្វព្រៃ។ កត្តានេះអាចកាត់បន្ថយការដាក់សម្ពាធលើធនធានព្រៃឈើ។ វិធីសាស្ត្រគន្លឹះ ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្ររួមនេះគឺមានការរួមបញ្ចូលគ្នានូវយុទ្ធសាស្ត្ររួមជាច្រើន ដូចជា ១) ការលើកកម្ពស់ការធ្វើពិពិធកម្មកសិកម្មនិងប្រពលវប្បកម្ម ស្របតាមគោលការណ៍ពិពិធកម្មកសិកម្មតាមបែបធម្មជាតិ ២) ការការពារចម្ការវិលជុំ និង ៣) ការគាំទ្រដល់សហគមន៍ព្រៃឈើនិងស្ថាប័នជលផល។

**៥.៦.១- យុទ្ធសាស្ត្ររង : ធានាឱ្យបាននូវការអភិវឌ្ឍកសិកម្មលក្ខណៈគ្រួសារប្រកបដោយភាពរស់រវើក(មានប្រសិទ្ធភាពនៃសេដ្ឋកិច្ច យុត្តិធម៌សង្គម និងបរិស្ថានល្អ)**

- លើកកម្ពស់វិធានការប្រពលវប្បកម្មកសិកម្មបែបធម្មជាតិនៅក្នុងប្រព័ន្ធប្រើប្រាស់ដីកសិកម្មរបស់កសិករខ្នាតតូច រួមមានការមិនភ្ជួររាស់ដី ដាំដំណាំគម្របដីជាអចិន្ត្រៃយ៍ និងកាត់បន្ថយការប្រើប្រាស់ជីគីមីនិងថ្នាំពុលជាដើម

- កសាងអាងស្តុកទឹកនិងប្រព័ន្ធធារាសាស្ត្រដែលមានតម្លៃសមរម្យនៅតាមដងស្ទឹង ទន្លេ និងទីតាំងសមស្រប ដើម្បីស្តុកទឹកនិងដោះស្រាយពេលមានគ្រោះរាំងស្ងួត។ អាងស្តុកទឹកទាំងនេះក៏ជួយកាត់បន្ថយគ្រោះទឹកជំនន់ផងដែរ។ ការដោះស្រាយបញ្ហាប្រឈមទាំងពីរនេះជួយកាត់បន្ថយផលប៉ះពាល់និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- ជំរុញធ្វើពិពិធកម្មកសិកម្ម ដូចជាស្បៀងអាហារនិងដំណាំកសិឧស្សាហកម្មលាយឡំជាមួយការចិញ្ចឹមសត្វតូចៗ
- ផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីសម្រាប់ដីដាំដុះទាំងអស់របស់កសិករខ្នាតតូច
- ផ្តល់វគ្គបណ្តុះបណ្តាលទូលំទូលាយអំពីបច្ចេកទេសកសិកម្មប្រកបដោយនិរន្តរភាពដល់កសិករខ្នាតតូចលើការគ្រប់គ្រងដីនិងទឹក ការផលិតគ្រាប់ពូជ ការជ្រើសរើសគ្រាប់ពូជទៅតាមស្ថានភាពដី ផលិតកម្មបន្លែ ឧបករណ៍កសិកម្ម ទីផ្សារ។ល។
- បង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្មនិងកសិកដ្ឋានគំរូ ដើម្បីបង្ហាញការអនុវត្តនិងផ្តល់បច្ចេកទេសកសិកម្មនិងតម្រង់ទិសការដាំដំណាំធម្មជាតិឱ្យស្របតាមប្រភេទដីនិងតម្រូវការទីផ្សារ
- រៀបចំឱ្យមានមន្ត្រីបង្គោលកសិកម្មនិងវិស័យពាក់ព័ន្ធទទួលបន្ទុកតាមភូមិ/ឃុំ ដើម្បីគាំទ្របច្ចេកទេសអភិវឌ្ឍកសិកម្ម ផលិតផលកសិកម្ម និងទីផ្សារ
- ជំរុញអភិវឌ្ឍនិងធ្វើការប្រកួតប្រជែងចលនាភូមិមួយផលិតមួយ
- ជំរុញគំរូវិនិយោគកសិកម្មដែលទទួលខុសត្រូវលើសិទ្ធិដីធ្លីនិងសន្តិសុខសេដ្ឋកិច្ចរបស់គ្រួសារកសិករ និងមានបរិស្ថានល្អ។ សកម្មភាពនេះត្រូវតម្រង់ទិសទៅស្រុកកោះញែក នៅតាមទីតាំង ដូចជាទំនប់អូរប្រង់ ឃុំស្រែហ៊ុយ ទំនប់អូរយេះ ឃុំស្រែសង្គម ទំនប់អូរណៃ ឃុំសុខសាន្ត ទំនប់អូរបាក់ខាំ ឃុំណាងឃីលីក ទំនប់អូរដ៉ា ឃុំរយ៉ រ ទំនប់អូរព្យុត និងតំបន់កសិកម្មទាំងមូលរបស់ឃុំស្រែសង្គម
- ពង្រឹងនិងលើកកម្ពស់សហករកសិកម្មថ្មីនិងសមាគមដែលមានស្រាប់ ដើម្បីបង្កើនការលក់ចូលទីផ្សារសម្រាប់កសិករខ្នាតតូច
- ពង្រីកសេវាកម្មបង្កើនទិន្នផលកសិកម្មដោយឈរលើប្រធានបទប្រពលវប្បកម្មកសិកម្មតាមបែបធម្មជាតិ
- លើកកម្ពស់ការអភិវឌ្ឍកសិកម្មដោយផ្តែកលើការបង្កើតគម្រោងប្រព័ន្ធធារាសាស្ត្រថ្មីនិងស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ រួមមានទំនប់អូរប្រង់ ទំនប់អូរណៃ ទំនប់អូរបាក់ខាំ ទំនប់អូរយេះ ទំនប់ភ្នំក្រោល ទំនប់កងពល ទំនប់ស្រែជ្រៃ ទំនប់អូរព្យុត ទំនប់របី ទំនប់អូរដ៉ា និងទំនប់រវ៉ាក់ជាដើម។

### ៥.៦.២- យុទ្ធសាស្ត្ររង : ការពារកសិកម្មវិលជុំដែលមានស្រាប់និងគាំទ្រការផ្លាស់ប្តូរពីប្រព័ន្ធកសិកម្មចម្ការវិលជុំទៅជាកសិកម្មអចិន្ត្រៃយ៍

កសិកម្មវិលជុំនៅតែជារបៀបធ្វើកសិកម្មដ៏សំខាន់មួយនៅក្រុងសែនមនោរម្យ ស្រុកពេជ្រាដា ស្រុកអូររាំង និងស្រុកកែវសីមា។ នៅទូទាំងខេត្តមណ្ឌលគិរី ប្រព័ន្ធនេះជាប្រធានបទនៃបញ្ហាស្រដៀងគ្នានឹងការលក់ដីដែល

ធ្វើកសិកម្មចម្ការវិលជុំទៅឱ្យជនចំណូលស្រុកនិងការកើនឡើងចំនួនប្រជាសាស្ត្រដែលបញ្ហាទាំងពីរនេះ បណ្ដាលឱ្យមានកំណើននូវតម្រូវការដីកសិកម្មកាន់តែច្រើនឡើងៗ។ ដោយសារការពង្រីកនេះបានកើតឡើងជាចម្បងដោយវត្តមាននៃសម្បទានដីសេដ្ឋកិច្ច ការពង្រីកការកាន់កាប់ដីកសិកម្មច្រើនតែងកើតមាននៅក្នុងរបៀងអភិរក្សជីវៈចម្រុះឬក្នុងដែនជម្រកសត្វព្រៃ។ ដំណើរការនេះតែងធ្វើឱ្យជនជាតិដើមភាគតិចដែលមានសន្តិសុខនៃសិទ្ធិកាន់កាប់តិចតួចងាយប្រឈមនឹងហានិភ័យនៃការបណ្ដេញចេញ ដូចជានៅក្រុងសែនមនោរម្យ ក្នុងសង្កាត់រមនា ភូមិពូលូង ស្រុកពេជ្រាដា ក្នុងឃុំប្រ៊ូសា ឃុំស្រែអំពូម ឃុំពូជ្រៃ និងស្រុកអូររាំង ក្នុងភូមិពូរ៉ាំង ភូមិពូឆប ទូលស្វាយ។

ជាលទ្ធផលតំបន់កសិកម្មវិលជុំទាំងនេះបាននិងកំពុងផ្លាស់ប្ដូរផ្នែកខ្លះឬទាំងស្រុងទៅជាប្រព័ន្ធកសិកម្មអចិន្ត្រៃយ៍។ ទោះជាមានការអនុវត្តការធ្វើចម្ការវិលជុំនៅក្នុងសហគមន៍ រួមទាំងតំបន់ដែលបានកំណត់កម្មសិទ្ធិដីសមូហភាពក៏ដោយ ក៏នៅមិនទាន់មានការឯកភាពគ្នាច្បាស់លាស់អំពីអនាគតនៃការធ្វើចម្ការវិលជុំនៅឡើយ។ គ្រួសារខ្លះនៅតែពឹងផ្អែកលើការធ្វើចម្ការវិលជុំ ហើយនៅតែចង់បន្តការធ្វើកសិកម្មវិលជុំនេះ។ សកម្មភាពមួយចំនួនត្រូវបានស្នើឡើងដូចជា៖

- សិក្សាឱ្យបានច្បាស់អំពីការធ្វើចម្ការវិលជុំនាពេលអនាគត ពោលគឺតំបន់ដែលការធ្វើចម្ការវិលជុំកំពុងរងការគំរាមកំហែងនិងតំបន់សក្ដានុពលសម្រាប់ធ្វើចម្ការវិលជុំគួរតែថែរក្សាទុក
- លើកកម្ពស់ជីវភាពរស់នៅដោយផ្អែកលើអនុផលព្រៃឈើ ព្រៃស្រោង
- រៀបចំកសាងនិងអនុវត្តដំណើរការឱ្យបានច្បាស់លាស់ ដើម្បីគ្រប់គ្រងមិនឱ្យមានការលក់ដូរឬផ្ទេរកម្មសិទ្ធិដីនៅក្នុងតំបន់ដែលកំពុងអនុវត្តកសិកម្មវិលជុំ។

## ៥.៧- យុទ្ធសាស្ត្រលើកកម្ពស់ការអភិវឌ្ឍកសិឧស្សាហកម្មខ្នាតធំប្រកបដោយការទទួលខុសត្រូវ ដើម្បីផ្ដល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមកជាមួយកសិកម្មខ្នាតតូច

តំបន់កសិកម្មនៅខេត្តមណ្ឌលគិរី រួមមានដីដែលកាន់កាប់និងដាំដុះដោយកសិករខ្នាតតូចនិងមានដីកសិកម្មខ្នាតធំដែលដំណើរការក្រោមឈ្មោះសម្បទានដីសេដ្ឋកិច្ចសម្រាប់គោលបំណងកសិឧស្សាហកម្ម។ សម្បទានដីសេដ្ឋកិច្ចនាំមកនូវផលចំណេញសម្រាប់សេដ្ឋកិច្ច ប៉ុន្តែក៏អាចនាំមកជាមួយនូវផលប៉ះពាល់ដល់កសិកម្មខ្នាតតូចផងដែរប្រសិនបើការគ្រប់គ្រងមិនបានត្រឹមត្រូវ។ តំបន់កសិកម្មគួរតែមានការរៀបចំនិងការអនុវត្តប្រព័ន្ធគ្រប់គ្រងតឹងរ៉ឹងនិងមានតម្លាភាពចំពោះសម្បទានដីសេដ្ឋកិច្ចដែលមានការរំលោភចូលដីកសិកម្មខ្នាតតូចរបស់កសិករ ហើយក៏ត្រូវផ្ដល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមកជាមួយកសិករដែលនៅជុំវិញ។

### ៥.៧.១- យុទ្ធសាស្ត្ររង : ជំរុញការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ចដែលស្វែងរកផលប្រយោជន៍រួមគ្នាជាមួយកសិកម្មខ្នាតតូច

- ទាមទារឱ្យមានការត្រួតពិនិត្យប្រកបដោយគណនេយ្យភាពនិងគោរពតាមកិច្ចសន្យានិងកិច្ចព្រមព្រៀងផ្ដល់សម្បទានដីសេដ្ឋកិច្ចជាមួយរាជរដ្ឋាភិបាល
- ជំរុញចុះបញ្ជីដីរដ្ឋសម្រាប់សម្បទានដីសេដ្ឋកិច្ចទាំងអស់ដែលមិនទាន់បានបញ្ចប់ការចុះបញ្ជី
- កំណត់និងអនុវត្តយន្តការដោះស្រាយសម្រាប់តំបន់ដែលមានវិវាទមិនទាន់បានដោះស្រាយរវាងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចនិងប្រជាកសិករ

- លើកកម្ពស់ទម្រង់ផ្សេងៗនៃកិច្ចសហការ ដូចជាកសិកម្មតាមកិច្ចសន្យារវាងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចនិងប្រជាកសិករ ដើម្បីទទួលបានអត្ថប្រយោជន៍ឈ្នះ ឈ្នះសម្រាប់ភាគីទាំងពីរ។ ការលើកកម្ពស់នេះរួមបញ្ចូលទាំងការរៀបចំសម្រាប់ការបែងចែកដី ការជ្រើសរើសកម្លាំងពលកម្ម និង/ឬទាំងលទ្ធភាពទទួលបានបរិក្ខារកែច្នៃ។

## ៥.៨- យុទ្ធសាស្ត្រពង្រឹងការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍នៅក្រៅប្រព័ន្ធតំបន់ការពារធម្មជាតិ

នៅខាងក្រៅប្រព័ន្ធនៃតំបន់ការពារធម្មជាតិ ដូចជាដែនជម្រកសត្វព្រៃនិងរបៀងអភិរក្សជីវៈចម្រុះ មានគម្រោងសហគ្រប់គ្រងជាច្រើនក្នុងការគ្រប់គ្រងធនធានព្រៃឈើឬតំបន់ដីសើម។ ធនធានទាំងនេះមានសារៈសំខាន់ដែលត្រូវរក្សាទុកជាដីសាធារណៈដោយចៀសវាងការដោះដូរឬផ្ទេរមកឯកជន ដើម្បីគ្រួសារនីមួយៗមានលទ្ធភាពទទួលបានអនុផលព្រៃឈើនិងនេសាទ។ ធនធានទាំងនេះក៏បានផ្តល់ឱកាស ដើម្បីបង្កើតជាកន្លែងទេសចរណ៍ធម្មជាតិផងដែរ។

### ៥.៨.១- យុទ្ធសាស្ត្ររង : ពង្រឹងការគ្រប់គ្រងសហគមន៍ព្រៃឈើដែលមានស្រាប់

- បំពេញការចុះបញ្ជីនិងចុះកិច្ចព្រមព្រៀងសម្រាប់សហគមន៍ព្រៃឈើទាំងអស់នៅទូទាំងខេត្ត
- ដោះស្រាយជម្លោះដីធ្លីដែលមិនទាន់ចប់នៅជុំវិញការអភិវឌ្ឍសហគមន៍ព្រៃឈើនៅក្នុងស្រុកអូររាំងនិងក្រុងសែនមនោរម្យ។

### ៥.៨.២- យុទ្ធសាស្ត្ររង : ពង្រឹងគម្រោងសហគ្រប់គ្រងសហគមន៍នេសាទដែលមានស្រាប់

- បញ្ចប់ការចុះបញ្ជីនិងកិច្ចព្រមព្រៀងសម្រាប់សហគមន៍នេសាទទាំងអស់នៅទូទាំងខេត្ត
- ពង្រឹងការគ្រប់គ្រងសហគមន៍នេសាទតាមរយៈការបង្កើតនិងការអនុវត្តប្លង់គោលប្រើប្រាស់ដីនៅតំបន់ដីសើមនិងតំបន់តាមបណ្តោយទន្លេ រួមទាំងកន្លែងសម្រាប់អេកូទេសចរណ៍។

## ៥.៩- យុទ្ធសាស្ត្រលើកកម្ពស់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន និងការធ្វើដំណើរ ដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានសេវាសាធារណៈសម្រាប់ប្រជាជននិងគាំទ្រការអភិវឌ្ឍតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនគឺជាធាតុដ៏សំខាន់ ដើម្បីជំរុញខេត្តមណ្ឌលគិរីដើរតួនាទីគាំទ្រនៅក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា- ឡាវ- វៀតណាម និងធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានសេវាសាធារណៈ។ ការអភិវឌ្ឍនេះនឹងសម្រេចបានតាមរយៈយុទ្ធសាស្ត្របំពេញបន្ថែមចំនួន២។ ម្យ៉ាងវិញទៀតអាកាសយានដ្ឋានថ្មីនៅក្នុងភូមិសាស្ត្រស្រុកអូររាំងនឹងក្លាយជាមជ្ឈមណ្ឌលយុទ្ធសាស្ត្រមួយនៅក្នុងប្រព័ន្ធបណ្តាញដឹកជញ្ជូនថ្មីនេះ។ ការអភិវឌ្ឍផ្លូវខេត្តនឹងជួយតភ្ជាប់ខេត្តទៅនឹងច្រករបៀងអភិវឌ្ឍន៍សំខាន់ៗនិងខេត្តផ្សេងទៀត ក៏ដូចជាធ្វើឱ្យប្រសើរឡើងនូវការបម្លាស់ទីនិងលទ្ធភាពទទួលបានសេវាសាធារណៈនៅក្នុងខេត្តផងដែរ។ ទោះយ៉ាងណាក៏ដោយ ការអភិវឌ្ឍទាំងអស់នេះក៏នឹងផ្តល់ផលប៉ះពាល់ដល់ធនធានធម្មជាតិ ពិសេសបង្កើនការខណ្ឌចែកព្រៃឈើជាផ្នែកៗ។ ផលប៉ះពាល់ទាំងនេះចាំបាច់ត្រូវមានការទទួលស្គាល់ជាសាធារណៈ ជាមួយនឹងផែនការផ្សេងៗសម្រាប់កាត់បន្ថយផលប៉ះពាល់អវិជ្ជមាននានាទាក់ទងនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនេះ។

**៥.៩.១- យុទ្ធសាស្ត្ររង : អភិវឌ្ឍមជ្ឈមណ្ឌលដឹកជញ្ជូនកម្រិតតំបន់ដែលលើកកម្ពស់បរិស្ថានផ្សារភ្ជាប់ទៅនឹងអាកាសយានដ្ឋានថ្មីនិងក្រុងសែនមនោរម្យ**

- សិក្សានិងកាត់បន្ថយផលប៉ះពាល់បរិស្ថានពីការបង្កើតអាកាសយានដ្ឋានថ្មី ពិសេសដល់ដីកសិកម្មនិងធនធានព្រៃឈើដែលស្ថិតនៅក្នុងតំបន់គ្រប់គ្រងរួម
- សិក្សានិងកាត់បន្ថយផលប៉ះពាល់សង្គមពីការបង្កើតអាកាសយានដ្ឋានថ្មីដល់ដីនិងអត្តសញ្ញាណវប្បធម៌របស់ជនជាតិដើមភាគតិច។ វិធានការកាត់បន្ថយ រួមមានការផ្លាស់ទីលំនៅនិង/ឬសំណងសមស្របដល់គ្រួសាររងផលប៉ះពាល់ទាំងអស់ដែលនឹងត្រូវដកហូតដី
- រៀបចំច្រករបៀងអភិវឌ្ឍន៍មួយពីអាកាសយានដ្ឋានថ្មីទៅក្រុងសែនមនោរម្យ រួមមានផែនការកាត់បន្ថយផលប៉ះពាល់លើបរិស្ថានជុំវិញ(សំឡេង ពន្លឺភ្លើង និងលម្អ)។ ផែនការនេះចាំបាច់ត្រូវគិតទុកជាមុនអំពីផលប៉ះពាល់សេដ្ឋកិច្ច-សង្គមដែលបណ្តាលមកពីការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃតំបន់នេះ ដូចជាការជួញដូរដីធ្លី ការបណ្តេញចេញ ការប្រមូលទិញដីយ៉ាងឆាប់រហ័សជាដើម។ វិធានការការពារសម្រាប់គ្រួសារងាយរងគ្រោះចាំបាច់ត្រូវចាត់ទុកជាអាទិភាព។

**៥.៩.២- យុទ្ធសាស្ត្ររង : ធ្វើឱ្យប្រសើរឡើងនូវចល័តភាពក្នុងខេត្តមណ្ឌលគិរីនិងលទ្ធភាពទទួលបានសេវាសាធារណៈ**

- ធ្វើឱ្យប្រសើរឡើងនូវបណ្តាញផ្លូវខេត្តដោយកម្រិតផលប៉ះពាល់លើដែនជម្រកសត្វព្រៃតាមរយៈការកម្រិតការខណ្ឌចែកតំបន់ស្នូល តំបន់អភិរក្ស និងតំបន់អភិវឌ្ឍន៍ច្បាស់លាស់។ សំណើផ្លូវដូចមានផែនទីក្នុងឧបសម្ព័ន្ធ៥ ត្រូវយកចិត្តទុកដាក់ជាពិសេសដល់៖
  - ផ្លូវលេខ៧៥ ពីមជ្ឈមណ្ឌលស្រុកកោះញែកទៅខាងលិច។ ការធ្វើឱ្យប្រសើរឡើងនៃផ្លូវខេត្តគួរចៀសវាងការឆ្លងកាត់ផ្នែកខាងត្បូងនៃដែនជម្រកសត្វព្រៃលំផាត់
  - ការរៀបចំនិងស្ថាបនាផ្លូវពីទីប្រជុំជនស្រុកកោះញែកទៅខាងត្បូងឆ្ពោះទៅខេត្តក្រចេះគួរចៀសវាងការឆ្លងកាត់តំបន់ស្នូលនិងតំបន់អភិរក្សនៃដែនជម្រកសត្វព្រៃភ្នំព្រេច
  - ផ្លូវលេខ៩៥ឬលេខ៣៧៦៦ ពីទីប្រជុំជនស្រុកកោះញែកទៅខាងកើតឆ្ពោះទៅព្រំប្រទល់ប្រទេសវៀតណាមគួរអភិវឌ្ឍទៅជិតនឹងដងទន្លេ ចន្លោះទន្លេស្រែពកនិងអូរល្វេរ ដើម្បីចៀសវាងការឆ្លងកាត់ដែនជម្រកសត្វព្រៃស្រែពក និងទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន ជាអតិបរមាសម្រាប់ប្រជាជនរស់នៅក្នុងតំបន់និងតាមដងទន្លេ ព្រមទាំងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់ដែនជម្រកសត្វព្រៃស្រែពក
  - ផ្លូវក្រវាត់ក្រុងថ្មីដែលតភ្ជាប់តំបន់អាកាសយានដ្ឋានថ្មីនៅស្រុកអូររាំងទៅក្រុងសែនមនោរម្យស្ថិតនៅផ្នែកខាងកើតនៃទីប្រជុំជនក្រុងសែនមនោរម្យ។
- ជំរុញរៀបចំនិងអនុវត្តផែនការមេហេដ្ឋារចនាសម្ព័ន្ធផ្លូវខេត្ត ក្រុង ការដឹកជញ្ជូន និងការធ្វើដំណើរក្នុងក្រុងប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងសោភណភាព។

### ៥.១០- យុទ្ធសាស្ត្រលើកកម្ពស់កំណើនអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនិងការអភិវឌ្ឍតាមតំបន់ព្រំដែនតាមផែនការប្រោះលាស់ជាមជ្ឈមណ្ឌលអភិវឌ្ឍន៍ថ្មី ដើម្បីសម្រួលដល់ការផ្លាស់ប្តូរពាណិជ្ជកម្មជាមួយប្រទេសជិតខាង

ទីតាំងយុទ្ធសាស្ត្ររបស់ខេត្តមណ្ឌលគីរីតាមបណ្តោយព្រំដែនជាមួយប្រទេសវៀតណាមផ្តល់ឱកាសជាយុទ្ធសាស្ត្រ ដើម្បីជំរុញការកែច្នៃ ការស្តុកទុក និងការធ្វើពាណិជ្ជកម្មទំនិញ ពិសេសទំនិញកសិកម្មទៅកាន់ប្រទេសវៀតណាមនិងក្នុងតំបន់។ បន្ថែមលើនេះ ការអភិវឌ្ឍតាមបណ្តោយព្រំដែនក៏ផ្តល់ឱកាសគាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍ ដោយពឹងផ្អែកលើសក្តានុពលនៃធនធានធម្មជាតិ តាមភូមិសាស្ត្រនីមួយៗផងដែរ។ យុទ្ធសាស្ត្របំពេញបន្ថែមចំនួន២ ត្រូវបានកំណត់ ដើម្បីសម្រេចគោលបំណងនេះគឺអភិវឌ្ឍនិងកែលម្អបរិក្ខារព្រំដែន រួមជាមួយការបង្កើតឱ្យមានការអភិវឌ្ឍរោងចក្រកែច្នៃផលិតផលកសិឧស្សាហកម្មឬជាកន្លែងស្តុកទំនិញរបស់ខេត្តនិងតំបន់ជុំវិញ។

១- ដាក់ដាំ ស្រុកអូររាំង គឺជាច្រកទ្វារភាគីតូចមួយ។ ច្រកទ្វារភាគីនេះមិនដូចច្រកទ្វារភាគីណាមលៀរទេ ព្រោះផ្នែកក្នុងទឹកដីព្រះរាជាណាចក្រកម្ពុជាមានហេដ្ឋារចនាសម្ព័ន្ធនិងមានសក្តានុពលសម្រាប់ការអភិវឌ្ឍនិងកែច្នៃផលិតផលកសិឧស្សាហកម្ម។ រីឯនៅក្នុងទឹកដីប្រទេសវៀតណាមមិនទាន់មានហេដ្ឋារចនាសម្ព័ន្ធធំៗនៅឡើយ។

២- ណាមលៀរ ស្រុកពេជ្រាដា ផ្លូវឆ្លងកាត់ភ្នំណាមលៀរមានទទឹងតូច ហើយមានទីតាំងស្ថិតនៅក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច។ ស្ថានភាពផ្លូវទៅព្រំដែនបច្ចុប្បន្នមានការលំបាកខ្លាំងណាស់ ពិសេសនៅរដូវវស្សា។ រីឯនៅតាមព្រំដែនខាងប្រទេសវៀតណាម ការសាងសង់មានដង់ស៊ីតេខ្ពស់ជាទីប្រជុំជននិងតំបន់ឧស្សាហកម្ម។

៣- ឡាប៉ាខេ ស្រុកកែវសីមា ជាច្រកទ្វារភាគីតូចមួយដែលភាគច្រើនបម្រើដល់ការនាំចេញឬនាំចូលផលិតផលកសិកម្មពីខេត្តមណ្ឌលគីរីនិងខេត្តផ្សេងៗ ដូចជាខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តក្រចេះ ខេត្តស្ទឹងត្រែងផងដែរ។ បច្ចុប្បន្នមានការព្រមព្រៀងរវាងស្រុកកែវសីមានិងស្រុករបស់ភាគីប្រទេសវៀតណាមដោយផ្តល់អាទិភាពដល់ប្រជាជនដែលទៅមកទទួលសេវាសុខភាព។ ទោះជាយ៉ាងណាក៏ដោយមិនមានបរិក្ខារជាក់លាក់សម្រាប់ការកែច្នៃនិងការស្តុកផលិតផលកសិកម្មនៅឡើយ។ ប៉ុន្តែដោយសារទីតាំងយុទ្ធសាស្ត្ររបស់ច្រកទ្វារភាគីឡាប៉ាខេ មានបណ្តាញតភ្ជាប់ជាមួយច្រករបៀងអាស៊ានហើយច្រកនេះមានសក្តានុពលក្នុងការអភិវឌ្ឍនិងការធ្វើឱ្យប្រសើរឡើងនូវសេវាកម្មទាំងនេះក្នុងកម្រិតខ្ពស់ ពិសេសសម្រាប់ការបង្កើតតំបន់អភិវឌ្ឍន៍សេដ្ឋកិច្ចពិសេសនិងផែស្ងួត។

៤- ជីមៀតឬកោះមឿល ស្រុកកោះញែក តំបន់ឆ្លងកាត់ព្រំដែនជីមៀតឬកោះមឿលគឺជាតំបន់ឆ្លងកាត់ព្រំដែនតូចមួយដែលការធ្វើពាណិជ្ជកម្មនៅមានកម្រិតទាប។ តំបន់ព្រំដែននេះស្ថិតនៅក្នុងដែនជម្រកសត្វព្រៃស្រែពក ហើយការអភិវឌ្ឍតំបន់ព្រំដែននេះនឹងជះឥទ្ធិពលដល់ការគ្រប់គ្រងតំបន់ដែនជម្រកសត្វព្រៃ។

## ៥.១០.១- យុទ្ធសាស្ត្ររង: គាំទ្រការអភិវឌ្ឍ បរិក្ខារ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មតាមព្រំដែននិងកាត់បន្ថយផលប៉ះពាល់បរិស្ថានពីការអភិវឌ្ឍ

### ក- ច្រកព្រំដែនដីមៀតឬកោះមឿល ស្រុកកោះញែក

- ទប់ស្កាត់ការពង្រីកទីតាំងតំបន់ព្រំដែនកោះមឿល ដើម្បីចៀសវាងផលប៉ះពាល់បរិស្ថានក្នុងដែនជម្រកសត្វព្រៃស្រែពក
- សិក្សាកំណត់ទីតាំងថ្មីនៃតំបន់ព្រំដែនដីមៀតឬកោះមឿល នៅជិតដងទន្លេចន្លោះទន្លេស្រែពកនិងអូរល្វេ
- រៀបចំផែនការប្រើប្រាស់ដីលម្អិតនិងផែនការអភិវឌ្ឍន៍បរិក្ខារ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មគាំទ្រ ដើម្បីជំរុញនិងលើកកម្ពស់ការអភិវឌ្ឍព្រំដែនដីមៀតឬកោះមឿលជាព្រំដែនកម្រិតខ្ពស់
- ពង្រឹងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ពិសេសសន្តិសុខ សេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយប្រទេសវៀតណាមនិងក្នុងតំបន់។

### ខ- ច្រកព្រំដែនណាមលៀរ ស្រុកពេជ្រាដា

- កំណត់ផ្ទៃដីតំបន់អភិវឌ្ឍន៍ច្រកព្រំដែន ដើម្បីស្នើសុំកាត់ចេញពីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចឬសិក្សាលទ្ធភាពកំណត់តំបន់អភិវឌ្ឍព្រំដែនណាមលៀរថ្មី មានភូមិសាស្ត្រសមស្រប ងាយស្រួលគ្រប់គ្រងនិងទំនាក់ទំនងជាមួយភាគីប្រទេសវៀតណាម
- រៀបចំផែនការប្រើប្រាស់ដីលម្អិតនិងផែនការអភិវឌ្ឍន៍បរិក្ខារ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មគាំទ្រ ដើម្បីជំរុញនិងលើកកម្ពស់ការអភិវឌ្ឍព្រំដែនណាមលៀរជាព្រំដែនកម្រិតអន្តរជាតិនិងរក្សាឱ្យបាននូវបរិស្ថាននិងធនធានធម្មជាតិ
- ជំរុញលើកទឹកចិត្តការវិនិយោគលើផ្នែកហេដ្ឋារចនាសម្ព័ន្ធនិងការសាងសង់តំបន់សេដ្ឋកិច្ចពិសេស រួមទាំងផែស្ងួត រោងចក្រកែច្នៃជាដើម
- ពង្រឹងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ពិសេសសន្តិសុខ សេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយប្រទេសវៀតណាមនិងក្នុងតំបន់។

### គ- ច្រកព្រំដែនឡាប៉ាខេ ស្រុកកែវសីមា

- រៀបចំផែនការប្រើប្រាស់ដីលម្អិតនិងផែនការអភិវឌ្ឍន៍បរិក្ខារ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មគាំទ្រ ដើម្បីជំរុញនិងលើកកម្ពស់ការអភិវឌ្ឍព្រំដែនឡាប៉ាខេជាព្រំដែនកម្រិតខ្ពស់ឬព្រំដែនអន្តរជាតិនិងរក្សាឱ្យបាននូវបរិស្ថាននិងធនធានធម្មជាតិ
- ជំរុញលើកទឹកចិត្តការវិនិយោគលើផ្នែកហេដ្ឋារចនាសម្ព័ន្ធនិងការសាងសង់តំបន់សេដ្ឋកិច្ចពិសេស រួមទាំងផែស្ងួត រោងចក្រកែច្នៃជាដើម
- ពង្រឹងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ពិសេសសន្តិសុខ សេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយប្រទេសវៀតណាមនិងក្នុងតំបន់។

### ឃ- ច្រកព្រំដែនដាក់ដាំ ស្រុកអូររាំង

- រៀបចំផែនការប្រើប្រាស់ដីលម្អិតនិងផែនការអភិវឌ្ឍន៍បរិក្ខារ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មគាំទ្រ ដើម្បីជំរុញនិងលើកកម្ពស់ការអភិវឌ្ឍព្រំដែនដាក់ដាំជាព្រំដែនកម្រិតខ្ពស់ឬព្រំដែនអន្តរជាតិនិងរក្សាឱ្យបាននូវបរិស្ថាននិងធនធានធម្មជាតិ

- ជំរុញលើកទឹកចិត្តការវិនិយោគលើផ្នែកហេដ្ឋារចនាសម្ព័ន្ធនិងការសាងសង់តំបន់សេដ្ឋកិច្ចពិសេស រួមទាំងផែស្ងួត រោងចក្រកែច្នៃជាដើម
- ពង្រឹងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ពិសេសសន្តិសុខ សេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយប្រទេសវៀតណាមនិងក្នុងតំបន់។

### ៥.១០.២- យុទ្ធសាស្ត្ររង : ពង្រឹងកិច្ចសហប្រតិបត្តិការតាមព្រំដែននិងគ្រប់គ្រងការអភិវឌ្ឍតំបន់ព្រំដែន

- ពង្រឹងកិច្ចសហប្រតិបត្តិការនិងទំនាក់ទំនងអន្តរជាតិ ដើម្បីលើកកម្ពស់ការអភិវឌ្ឍព្រំដែនជាមួយប្រទេសវៀតណាមនិងក្នុងតំបន់
- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយអាជ្ញាធរប្រទេសវៀតណាម ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទ មានជាអាទិ៍បទល្មើសព្រៃឈើ សត្វព្រៃ ជួញដូរគ្រឿងញៀន ជួញដូរមនុស្សជាដើម
- ផ្តល់ការណែនាំច្បាស់លាស់ ដើម្បីលើកកម្ពស់ការពង្រីកតំបន់សាងសង់និងការអភិវឌ្ឍនានានៅតំបន់ព្រំដែន ដោយចៀសវាងផលប៉ះពាល់លើដែនជម្រកសត្វព្រៃ។

## ៥.១១- យុទ្ធសាស្ត្រលើកកម្ពស់កំណើនអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនិងការអភិវឌ្ឍកសិឧស្សាហកម្មនិងប្រភេទឧស្សាហកម្មផ្សេងទៀតក្នុងតំបន់មានសក្តានុពល ហើយតភ្ជាប់បណ្តាញដឹកជញ្ជូននិងតំបន់ផែស្ងួតទៅនឹងទីផ្សារក្នុងស្រុកនិងទីផ្សារក្រៅស្រុក

មានភាពចាំបាច់ ដើម្បីជំរុញការអភិវឌ្ឍប្រកបដោយនិរន្តរភាពនិងតុល្យភាពដោយផ្អែកលើការកែច្នៃផលិតផលនានា ពិសេសផលិតផលកសិឧស្សាហកម្មនិងការបង្កើតនូវប្រភេទឧស្សាហកម្មផ្សេងទៀតនៅតាមតំបន់ដែលមានសក្តានុពលកំណើនថ្មីៗនិងតំបន់ចាំបាច់នានា។ តំបន់អភិវឌ្ឍន៍ទាំងនេះត្រូវមានផែនការច្បាស់លាស់និងត្រូវពិចារណាផ្សារភ្ជាប់នឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានា ដើម្បីដំណើរការដោយរលូនប្រកបដោយប្រសិទ្ធភាព ព្រមទាំងមានកិច្ចសហការជាមួយប្រទេសជិតខាងនិងក្នុងតំបន់។ ទន្ទឹមនឹងនេះ ការកសាងសមត្ថភាពទាំងការគ្រប់គ្រងនិងសមត្ថភាពការងារជំនាញនានាក៏មានភាពចាំបាច់និងត្រូវមានផែនការនិង អនុវត្តតាមទិសដៅច្បាស់លាស់។

### ៥.១១.១- យុទ្ធសាស្ត្ររង : ពង្រឹងសមត្ថភាពនៃការគ្រប់គ្រងរបស់ខេត្ត ដើម្បីបង្កើនតម្លៃផលិតផលកសិកម្មរបស់ខ្លួនតាមរយៈការគ្រប់គ្រង ការស្តុកទុក និងកែច្នៃឱ្យបានល្អ

- រៀបចំនិងកំណត់តំបន់អភិវឌ្ឍន៍កសិឧស្សាហកម្មសមស្របតាមបណ្តោយផ្លូវក្រវាត់ក្រុងក្នុងមជ្ឈមណ្ឌលឡូជីស្ទិកថ្នាក់តំបន់ដែលភ្ជាប់ទៅនឹងអាកាសយានដ្ឋានថ្មីនិងក្រុងសែនមនោរម្យឬនៅតាមតំបន់ច្រកព្រំដែន
- រៀបចំនិងកំណត់តំបន់ឡូជីស្ទិក តំបន់ផែស្ងួត កន្លែងស្តុកបរិក្ខារ និងតំបន់ផ្សេងទៀតសម្រាប់គាំទ្រដល់ដំណើរការនៃការអភិវឌ្ឍមជ្ឈមណ្ឌលនេះ
- កសាងសមត្ថភាពគ្រប់គ្រងនិងសមត្ថភាពជំនាញនានា ដើម្បីចូលរួមក្នុងខ្សែច្រវាក់ផលិតកម្មបន្ថែមតម្លៃផលិតផលកសិកម្មក្នុងការកែច្នៃនិងស្តុកទុកផលិតផល។

### ៥.១១.២- យុទ្ធសាស្ត្ររង : ជំរុញការអភិវឌ្ឍឧស្សាហកម្មផ្អែកលើចំណេះដឹង បច្ចេកវិទ្យា និងនវានុវត្តន៍ដោយមិនប៉ះពាល់ដល់បរិស្ថាន

- រៀបចំនិងកំណត់តំបន់សមស្របសម្រាប់ការបង្កើតឧស្សាហកម្មផ្អែកលើចំណេះដឹង បច្ចេកវិទ្យា និងនវានុវត្តន៍ដែលមានទីតាំងផ្សារភ្ជាប់ជាមួយតំបន់ឡូជីស្ទិកនិងអាកាសយានដ្ឋានថ្មី
- កសាងសមត្ថភាពជំនាញនានា ដើម្បីចូលរួមក្នុងខ្សែច្រវាក់ផលិតកម្មឧស្សាហកម្មផ្អែកលើចំណេះដឹង បច្ចេកវិទ្យា និងនវានុវត្តន៍
- ផ្តល់សេវាកម្មនិងហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានា ដើម្បីចីរភាពនៃដំណើរការខ្សែច្រវាក់ផលិតកម្មឧស្សាហកម្មផ្អែកលើចំណេះដឹង បច្ចេកវិទ្យា និងនវានុវត្តន៍។

## ៥.១២- យុទ្ធសាស្ត្រលើកកម្ពស់ការអភិវឌ្ឍទីក្រុង ទីប្រជុំជនដោយមានផែនការច្បាស់លាស់និងប្រកបដោយនិរន្តរភាព ដើម្បីឆ្លើយតបនឹងកំណើនតម្រូវការសេវាកម្មសាធារណៈនិងឯកជននិងកំណត់ផលប៉ះពាល់នៃកំណើននគរូបនីយកម្មលើបរិស្ថាន

ការគ្រប់គ្រងការអភិវឌ្ឍមជ្ឈមណ្ឌលទីក្រុង ទីប្រជុំជនក្នុងខេត្តមណ្ឌលគិរីប្រកបដោយប្រសិទ្ធភាព តុល្យភាព ចីរភាព និងបរិយាបន្នគឺជាការចាំបាច់ ដើម្បីចៀសវាងផលប៉ះពាល់ធនធានធម្មជាតិនិងសក្តានុពលសម្រាប់ការអភិវឌ្ឍគ្រប់វិស័យ។ ទន្ទឹមនឹងនេះ ដើម្បីឆ្លើយតបតម្រូវការសេវាកម្មសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានារបស់ប្រជាជននិងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងមជ្ឈមណ្ឌលទីក្រុង ទីប្រជុំជនត្រូវអនុវត្តនូវយុទ្ធសាស្ត្រដែលមានភាពប្រទាក់ក្រឡាគ្នា។

### ៥.១២.១- យុទ្ធសាស្ត្ររង : គ្រប់គ្រងការអភិវឌ្ឍនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាពនិងចីរភាព

#### ក- កំណត់តំបន់គោលនគរូបនីយកម្ម

បច្ចុប្បន្នកំណើននគរូបនីយកម្មមានលក្ខណៈគួរឱ្យកត់សម្គាល់ដែលតម្រូវឱ្យមានការគ្រប់គ្រងនិងកំណត់តំបន់គោលនគរូបនីយកម្មច្បាស់លាស់សម្រាប់អនាគត។ ឆ្នាំ២០២០ ផ្ទៃដីសរុបតំបន់គោលនគរូបនីយកម្មប្រមាណ៤ ២៣៤ហិកតាស្មើនឹង០,៣០ភាគរយនៃផ្ទៃដីសរុបខេត្តមណ្ឌលគិរី ហើយអាចនឹងកើនដល់ ០,៨៨ ភាគរយនៅឆ្នាំ២០៤០។ ដើម្បីចីរភាពនិងសោភណភាពនៃការអភិវឌ្ឍនគរូបនីយកម្មត្រូវមានការកំណត់ដង់ស៊ីតេនិងអាំងតង់ស៊ីតេនៃការអភិវឌ្ឍទៅនឹងមុខងារនៃការប្រើប្រាស់ដីតាមប្រភេទនិងឋានានុក្រមនៃទីក្រុងទីប្រជុំជននីមួយៗ។

- ក្រុងសែនមនោរម្យជាតំបន់គោលនគរូបនីយកម្មស្នូលនៃខេត្តមណ្ឌលគិរី។ បច្ចុប្បន្នផ្ទៃដីនគរូបនីយកម្មនៃក្រុងសែនមនោរម្យប្រមាណ៦៤៩ហិកតាស្មើនឹង០,៣០ភាគរយនៃផ្ទៃដីសរុបក្រុងសែនមនោរម្យ។ ផ្ទៃដីនគរូបនីយកម្មក្រុងសែនមនោរម្យនៅឆ្នាំ២០៤០នឹងត្រូវព្យាករនិងកំណត់ដោយប្លង់គោលប្រើប្រាស់ដីក្រុងសែនមនោរម្យ ចក្ខុវិស័យឆ្នាំ២០៤០ដែលកំពុងគាំទ្របច្ចេកទេសសិក្សារៀបចំបន្តដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ទីប្រជុំជនឃុំស្រែខ្ទុម ស្រុកកែវសីមា និងទីប្រជុំជនឃុំស្រែសង្គម ស្រុកកោះញែក ជាតំបន់គោលនគរូបនីយកម្មទី២នៃខេត្តមណ្ឌលគិរី។ បច្ចុប្បន្នផ្ទៃដីនគរូបនីយកម្មនៃទីប្រជុំជនឃុំស្រែខ្ទុមមានប្រមាណ ៩៤២ហិកតាស្មើនឹង០,៣២ភាគរយនៃផ្ទៃដីសរុបស្រុកកែវសីមា ខណៈផ្ទៃដីនគរូបនីយកម្មនៃទីប្រជុំជន

ឃុំស្រែសង្គមប្រមាណ១ ៥៨៦ហិកតាស្មើនឹង០,២៨ភាគរយនៃផ្ទៃដីសរុបស្រុកកោះញែក។ ផ្ទៃដីនគរូបនីយកម្មឃុំស្រែខ្ទុមនិងឃុំស្រែសង្គមនៅឆ្នាំ២០៤០នឹងត្រូវព្យាករនិងកំណត់ដោយប្លង់គោលប្រើប្រាស់ដីស្រុកកែវសីមានិងស្រុកកោះញែក ចក្ខុវិស័យឆ្នាំ២០៤០ដែលកំពុងគាំទ្របច្ចេកទេសសិក្សារៀបចំបន្តដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- ទីប្រជុំជនឃុំស្រែព្រះ ទីប្រជុំជនឃុំសែនមនោរម្យ ទីប្រជុំជនឃុំប៊ូស្រា និងទីប្រជុំជនឃុំពូជ្រៃ ជាតំបន់គោលនគរូបនីយកម្មទី៣នៃខេត្តមណ្ឌលគិរី
- ទីប្រជុំជនឃុំស្រែឈូក ស្រុកកែវសីមា ទីប្រជុំជនឃុំដាក់ដាំ ស្រុកអូររាំង ទីប្រជុំជនឃុំមេម៉ង់និងឃុំចុងផ្លាស់ ស្រុកកែវសីមា ទីប្រជុំជនឃុំណងឃីលិក ស្រុកកោះញែក ជាទីប្រជុំជនជនបទ
- ទីប្រជុំជនពិសេស មានទីប្រជុំជនច្រកទ្វារភាគីឡាប៉ាខេ ទីប្រជុំជនច្រកទ្វារភាគីដាក់ដាំ ទីប្រជុំជនច្រកព្រំដែនណាមលៀរ និងទីប្រជុំជនច្រកព្រំដែនជីមៀតឬកោះមៀល។

**ខ- គោលការណ៍សម្រាប់កសាងប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម**

- ត្រូវរៀបចំ កសាង និងអនុវត្តប្លង់គោលនិងផែនការប្រើប្រាស់ដីក្រុងសែនមនោរម្យ ទីប្រជុំជនស្រុកកែវសីមា ទីប្រជុំជនស្រុកកោះញែក ទីប្រជុំជនឃុំសែនមនោរម្យ ឃុំប៊ូស្រា ឃុំពូជ្រៃ ឃុំដាក់ដាំ ឃុំមេម៉ង់ ឃុំចុងផ្លាស់ ឃុំណងឃីលិក និងតំបន់ទីប្រជុំជនពិសេស ច្រកព្រំដែនឡាប៉ាខេ ដាក់ដាំ ណាមលៀរ និងជីមៀតឬកោះមៀល ស្របតាមចក្ខុវិស័យនៃផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី ដើម្បីតម្រង់ទិសការអភិវឌ្ឍនិងការអភិរក្សតាមទម្រង់ត្រឹមត្រូវប្រកបដោយចីរភាពនិងប្រសិទ្ធភាព
- ត្រូវកំណត់ឱ្យច្បាស់លាស់អំពីប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់ ព្រមទាំងការកំណត់តំបន់ប្រើប្រាស់ដី ដោយតម្រង់ទិសការអភិវឌ្ឍតាមទម្រង់ទីក្រុងល្អត្រឹមត្រូវនិងចៀសវាងការពង្រីកឬការសាងសង់តាមទម្រង់ជាខ្សែត្រង់មិនសមស្រប តាមបណ្តោយផ្លូវជាតិដែលខុសពីប្លង់គោល
- ត្រូវធានានូវសោភណភាព ចីរភាព និងអត្តសញ្ញាណភូមិសាស្ត្រ វប្បធម៌ និងទេសភាពធម្មជាតិតំបន់ខ្ពង់រាប ប្រជុំភ្នំ ជម្រាលភ្នំ ជ្រលងភ្នំ ទន្លេ ស្ទឹង ព្រែក អូរ។ល។ ដូចជាការសាងសង់ហេដ្ឋារចនាសម្ព័ន្ធការរៀបចំលម្អសាធារណៈ លម្ហបៃតង បណ្តាញបៃតង អ័ក្សអេកូឡូស៊ី របងជីឡូត៍អំពីធម្មជាតិស្ថាបត្យកម្មធម្មជាតិ និងសំណង់បៃតងជាដើម
- ត្រូវទប់ស្កាត់ការពង្រីកផ្ទៃដីនគរូបនីយកម្មចូលទៅក្នុងតំបន់កសិកម្ម តំបន់ព្រៃឈើដែលគ្មានផែនការគ្រោងទុកច្បាស់លាស់និងទប់ស្កាត់ការប្តូរប្រភេទដីទាំងនេះទៅជាប្រភេទដីសាងសង់
- វាយតម្លៃផលប៉ះពាល់ការរៀបចំដែនដីនិងនគរូបនីយកម្ម លើប្លង់គោលនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក និងតាមទីប្រជុំជន ឱ្យបានត្រឹមត្រូវនិងច្បាស់លាស់ មុននឹងសម្រេចដាក់ឱ្យប្រើប្រាស់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- កំណត់បទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព ភាពឆ្លាត និងបរិយាបន្ន។

### ៥.១២.២- យុទ្ធសាស្ត្ររង: ធានានូវការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មទីក្រុងចាំបាច់ឱ្យកាន់តែប្រសើរឡើង

- សិក្សាពីតម្រូវការ ការរៀបចំអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មទីក្រុងចាំបាច់ ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព ភាពឆ្លាត និងបរិយាបន្ន ដូចជាផ្លូវថ្នល់ ប្រព័ន្ធលូទឹកភ្លៀង លូទឹកកខ្វក់ ស្ថានីយចម្រោះទឹកកខ្វក់ ប្រព័ន្ធបណ្តាញទឹកស្អាត ប្រព័ន្ធបណ្តាញអគ្គិសនី ប្រព័ន្ធបណ្តាញទូរគមនាគមន៍ ប្រព័ន្ធដឹកជញ្ជូន ឡូជីស្ទិក ស្ថានីយចំណតរថយន្ត មណ្ឌលព័ត៌មានទេសចរណ៍ជាដើម
- សិក្សាតម្រូវការនិងផ្តល់សេវាអប់រំគ្រប់កម្រិតតាមមជ្ឈមណ្ឌលទីក្រុង ទីប្រជុំជននីមួយៗ ស្របតាមរបាយប្រជាជនតាមរយៈការផ្តល់បរិក្ខារ ដូចជាសំណង់សាលារៀន អគារបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ត្រីអប់រំតាមជាក់ស្តែង
- សិក្សាតម្រូវការនិងផ្តល់សេវាសុខាភិបាលគ្រប់កម្រិតតាមមជ្ឈមណ្ឌលទីក្រុង ទីប្រជុំជននីមួយៗ ស្របតាមរបាយប្រជាជនតាមរយៈការផ្តល់បរិក្ខារ ដូចជាមណ្ឌលសុខភាព ពេទ្យបង្អែក និងមន្ត្រីសុខាភិបាលតាមជាក់ស្តែង
- សិក្សាលទ្ធភាពផ្តល់សេវាអប់រំនិងសេវាសុខាភិបាលកម្រិតខ្ពស់ ដូចជាសាកលវិទ្យាល័យនិងមន្ទីរពេទ្យស្របតាមតម្រូវការនៃបណ្តុំទីប្រជុំជននិងទីតាំងភូមិសាស្ត្រប្រកបដោយតុល្យភាព។

## ៥.១៣- យុទ្ធសាស្ត្រលើកកម្ពស់ទេសភាពទីក្រុង ទីប្រជុំជនតាមរយៈការលើកកម្ពស់និងអភិរក្សប្រព័ន្ធបៃតងធម្មជាតិនិងកសិកម្មក្នុងក្រុង ទីប្រជុំជន និងតំបន់ជុំវិញ

ការអភិវឌ្ឍទីក្រុង ទីប្រជុំជននៅខេត្តមណ្ឌលគិរីស្ថិតនៅក្នុងដំណាក់កាលដំបូងនៅឡើយ ហើយមានសក្តានុពលសមស្របសម្រាប់ការរៀបចំផែនការប្រព័ន្ធទេសភាពបៃតង ធម្មជាតិ និងតំបន់ទេសភាពកសិកម្មក្នុងទីក្រុង ទីប្រជុំជន ដើម្បីលើកកម្ពស់ទេសភាពទីក្រុង ទីប្រជុំជន និងពង្រឹងគុណភាពផលិតផលកសិកម្មដែលឆ្លើយតបនឹងតម្រូវការរបស់អ្នកប្រើប្រាស់។ ការអភិវឌ្ឍទីក្រុងបៃតងនឹងផ្តល់នូវបរិស្ថានរស់នៅប្រកបដោយផាសុកភាពសម្រាប់ប្រជាជន ក៏ដូចជាភ្ញៀវទេសចរផងដែរ។

### ៥.១៣.១- យុទ្ធសាស្ត្ររង: រៀបចំ កសាង និងអនុវត្តផែនការប្រព័ន្ធទេសភាពបៃតងលម្អិតនិងបទប្បញ្ញត្តិចាំបាច់

- សិក្សាកំណត់តំបន់ទេសភាពបៃតងមានស្រាប់និងតំបន់មានសក្តានុពលទេសភាព ដើម្បីពង្រីកនិងភ្ជាប់ប្រព័ន្ធបៃតងបន្ថែមជាមួយនឹងការពង្រីកទីក្រុង ទីប្រជុំជន និងបង្កើតការតភ្ជាប់តំបន់បៃតងរវាងទីប្រជុំជននិងជនបទ
- កសាងនិងអនុវត្តផែនការនិងកម្មវិធីប្រព័ន្ធទេសភាពបៃតង ធម្មជាតិ ដើម្បីបង្កើតនិងលើកកម្ពស់ទេសភាពបៃតងក្នុងទីក្រុង ទីប្រជុំជន ដោយការតភ្ជាប់តំបន់បៃតងតាមដងផ្លូវនិងទន្លេ ដូចជាការគ្រប់គ្រងឧទ្យានសាធារណៈក្រុងសែនមនោរម្យដែលជាទីតាំងអតីតព្រលានយន្តហោះ តំបន់ឧទ្យានវប្បធម៌ភ្នំដោះក្រមុំ អាងស្តុកទឹកទំនប់លើ អាងស្តុកទឹកទំនប់ក្រោម ទឹកធ្លាក់ដំណាក់ស្តេច ទឹកធ្លាក់អូរតាំងឡាំង ទឹកធ្លាក់ក្បាលព្រះ អូរសែនមនោរម្យ(ខាងក្រោមមន្ទីរពេទ្យ) ទេសភាពតាមដងផ្លូវពីស្រុកអូររាំងមកក្រុងសែនមនោរម្យ សមុទ្រឈើឡៅកា សមុទ្រឈើភ្នំបាយឆៅ និងទេសភាពខ្ពង់រាបភ្នំ ទន្លេ ស្ទឹង ព្រៃក អូរជាដើម
- រៀបចំបទប្បញ្ញត្តិសម្រាប់កាអភិវឌ្ឍនិងការអភិរក្សទេសភាពប្រកបដោយចីរភាពនិងបរិយាបន្ន។

### ៥.១៣.២- យុទ្ធសាស្ត្ររង : រៀបចំ កសាង និងអនុវត្តតំបន់ទេសភាពកសិកម្មនៅក្នុងមជ្ឈមណ្ឌលទីក្រុង ទីប្រជុំជនសំខាន់ៗ

- កំណត់និងគ្រប់គ្រងការប្រើប្រាស់ដីដែលគួរថែរក្សាទុកសម្រាប់កសិកម្មនៅក្នុងក្រុងនិងតំបន់ជុំវិញ តំបន់ទីប្រជុំជនសំខាន់ៗ
- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស លទ្ធភាពអាចទទួលបានទឹកប្រើប្រាស់ និងការកសាងសមត្ថភាព សម្រាប់ផលិតកម្មកសិកម្មទ្រទ្រង់អាហារសុខភាព
- ពង្រឹងខ្សែច្រវាក់ផលិតកម្មរយៈពេលខ្លីដែលផ្សារភ្ជាប់រវាងអ្នកផលិតនិងអ្នកប្រើប្រាស់ផ្ទាល់។

## ៥.១៤- យុទ្ធសាស្ត្រគ្រប់គ្រងនិងផ្តល់សេវាកម្មបរិស្ថានទីក្រុងប្រកបដោយប្រសិទ្ធភាពនិងមានគុណភាពខ្ពស់ ឆ្លើយតបនឹងកំណើនទីក្រុងនិងការអភិវឌ្ឍសេដ្ឋកិច្ច

ការផ្តល់សេវាកម្មបរិស្ថានទីក្រុងមានគុណភាពខ្ពស់ ដូចជាទឹកស្អាត ការគ្រប់គ្រងសំណល់រឹងនិងរាវប្រកបដោយប្រសិទ្ធភាពគឺជាកត្តាចាំបាច់និងជាមូលដ្ឋានគ្រឹះនៃសុខុមាលភាពសង្គម គុណភាពនៃការរស់នៅ និងបរិស្ថានរស់នៅល្អសម្រាប់ប្រជាជនទាំងអស់ រួមទាំងភ្ញៀវទេសចរនិងអ្នកវិនិយោគ។ ខេត្តមណ្ឌលគិរីកំពុងស្ថិតក្នុងដំណាក់កាលនៃការអភិវឌ្ឍដំបូងនិងមានស្ថានភាពភូមិសាស្ត្រជាតំបន់ខ្ពង់រាបត្រូវគិតគូរហ្មត់ចត់អំពីការគ្រប់គ្រងនិងការផ្តល់សេវាកម្មទាំងនេះសម្រាប់អនាគត ដើម្បីឆ្លើយតបនឹងកំណើនទីក្រុងនិងការអភិវឌ្ឍសេដ្ឋកិច្ចដែលនឹងជំរុញលើកកម្ពស់ការអភិវឌ្ឍដែនដីខេត្តនិងទាក់ទាញភ្ញៀវទេសចរនិងអ្នកវិនិយោគចំទិសដៅឱ្យកាន់តែច្រើនឡើង។

### ៥.១៤.១- យុទ្ធសាស្ត្ររង : លើកកម្ពស់ការផ្តល់សេវាកម្មនិងបរិក្ខារគាំទ្រការផ្គត់ផ្គង់ទឹកស្អាតមានសុវត្ថិភាព និងគ្រប់គ្រាន់ក្នុងតំបន់ទីក្រុងនិងតំបន់ជុំវិញ

- ថែរក្សាតំបន់ប្រភពទឹក អាងទឹកធម្មជាតិ តំបន់ជម្រាល និងផ្ទៃរងទឹកភ្លៀងក្នុងទីក្រុង ទីប្រជុំជន និងតំបន់ពាក់ព័ន្ធជុំវិញ មានដូចជា៖
  - ក្រុងសែនមនោរម្យ មានព្រែកដាក់ដៀរ អាងស្តុកទឹកទំនប់លើ អាងស្តុកទឹកទំនប់ក្រោម អូរសែនមនោរម្យ អូរយ៉ាងងលៈ អូរបុងទូ អូរត្រេក អូរកុល អូរម្លេង អូរអន់ជ្រូង អូរឈើ អូរខ្លែរ ទឹកធ្លាក់ដំណាក់ស្តេច ទឹកធ្លាក់រមនា១ ទឹកធ្លាក់រមនា២ ទឹកធ្លាក់ជ្រៃយស ទឹកជ្រោះពោកព្រះឬក្បាលព្រះ ទឹកជ្រោះអូត្រា ទឹកជ្រោះអូរឆ្វេង ទឹកជ្រោះលែងទូវជាដើម
  - ស្រុកកែវសីមា មានព្រែកឆ្លូង ព្រែកដាក់ហ្វូត ព្រែកជេង ព្រែកម្ចោច ព្រែកពោធិ៍ ព្រែកព្រះ ព្រែកខ្លងព្រែកឈ្លូង ត្រពាំងភ្នំកែវសីមា ត្រពាំងវែង(លើកំពូលភ្នំគូស) អូរទេរ អូរហ៊ុច អូរកូនព្រះ អូរលូបាក់ អូរទឹកខ្ញប អូរតាឡាយ អូរបាម អូរទ្រី អូរឃ្មង អូរត្រូន អូរជិក អូរច្រា អូររាំង អូរផ្លះ អូរតរ អូរទ្រៀង អូរតាន់បៀង អូរខ្ទង់ អូរក្បាយ អូរសំរូច អូរអណ្តែត អូរកញ្ជរ អូរជៀល អូរបាក់និ អូររំលុក អូររីស៊ីវ អូរគតីរ អូរក្តុល អូរពូរហោ អូរប៊ុប៉ា អូរអណ្តូង អូរយោល អូររវេ អូរអខ្មែង អូរព្រាធ អូរត្រឡប់ អូរកាំពី ទឹកធ្លាក់អូរតាំងឡាំង ទឹកធ្លាក់វត្តស្រែត្រាវ ទឹកធ្លាក់លែងចាំងជាដើម
  - ស្រុកអូររាំង មានព្រែកដាក់ហ្វូត អូរធ្ងើ អូរប៊្លម អូរពត អូរអាម អូរជាង អូរយ៉ាងងលៈ អូរពាមធើងអូរពោធិ៍ អូរម្លេង អូរព័រ អូរនុយ អូរដាក់ងាង អូរខ្ទង់ អូរទូក្មេន អូរឃាំងយូ អូររថន អូរជីងត្រាវ អូរ

ពូឡេត អូររសែស អូរក្រពើ អូររាំង អូររនោង អូរអន់រូង អូរឌៀរ អូរអង្កាន អូរឃ្នង អូរខ្នង់ទឹកធ្លាក់លែងឃិនលែងអន ទឹកធ្លាក់លែងកាប៉ាវ ទឹកធ្លាក់លែងណុត ទឹកធ្លាក់លែងឆុល ទឹកធ្លាក់អូររណោល ទឹកធ្លាក់លែងហ្វូវ ទឹកធ្លាក់លែងពួម ទឹកធ្លាក់លែងពុរកនក្រង់ជាំងដាំដែក ទឹកធ្លាក់ជ្រៃធំ ទឹកធ្លាក់លែងកៃ ទឹកធ្លាក់អូរតាវ ទឹកធ្លាក់ត្រង ទឹកធ្លាក់លែងការ ទឹកធ្លាក់លែងក្រេង ទឹកធ្លាក់លែងប៉ាល់ទោក ទឹកធ្លាក់លែងម្រើវ ទឹកធ្លាក់លែងកក់ ទឹកធ្លាក់លែងតាំត្រុះ ទឹកធ្លាក់លែងឈឹបពីយ ទឹកធ្លាក់លែងចាស់លែងចាង ទឹកធ្លាក់លែងប្រាក់ឬទឹកធ្លាក់ក្អោក ទឹកធ្លាក់លែងរ៉ាពូព្រៃ ទឹកធ្លាក់លែងច្បាក់រ៉ាឆាន ទឹកធ្លាក់លែងគ្លី ទឹកធ្លាក់លែងអូរឈើង ទឹកធ្លាក់លែងត្រាង ទឹកធ្លាក់លែងត្រង ទឹកធ្លាក់លែងទ្រឹង ទឹកធ្លាក់លែងបូង ទឹកធ្លាក់លែងរទូង ទឹកធ្លាក់លែងប៉ែល ទឹកធ្លាក់លែងគុល ទឹកធ្លាក់លែងង៉ល់ ទឹកធ្លាក់លែងតុងនុំ ទឹកធ្លាក់លែងចូញ ទឹកធ្លាក់លែងតុង ទឹកធ្លាក់លែងង្កែក ទឹកធ្លាក់លែងប៉ង ទឹកជ្រោះ៧ជាន់ ទឹកជ្រោះលែងម្ពក់ជាដើម

- ○ ស្រុកពេជ្រាដា មានព្រែកច្បារ ព្រែកដាក់ចុម ព្រែកព្រីង ព្រែកពោធិ៍ ព្រែកដាក់កាណា ព្រែកដាក់រេត ព្រែករម៉ាញ់ ព្រែករវៃ ព្រែកញងជ្រេញ ព្រែកដាក់កូប្រាន ព្រែករនុយ ព្រែករបោះ ព្រែកត្រមេត ព្រែកដាក់រកាន ព្រែកដាក់ជូ ព្រែកដាក់កូនក្រុង ព្រែកដាក់ដាំដេត ព្រែកខ្លង ព្រែកកូនពុងត្រពាំងក្អែម អូរបៃល អូរ៧ជាន់ អូរពោតឬអូររ៉េត អូរប៉ុល អូររពៅ អូរដា អូរបុងទូ អូរឡាវកា អូរយូនី អូរជំរ អូររ៉ាក់ អូរជើងព្រៃ អូរជា អូរណុំភូមិ អូរពីយ៉ាត អូរពៅ អូរយល អូរវេក អូរឡុងប្លា អូររេត អូរយោង អូរផ្លាយ អូររវេះ អូរយោមី អូរនទ្រូ អូរប្រី ទឹកធ្លាក់ម៉ុមតាល់ ទឹកជ្រោះប៊ូស្រា ទឹកជ្រោះអូរតាំកន ទឹកជ្រោះ៧ជាន់ ទឹកជ្រោះលែងប៉ាឡុងជាដើម
- ○ ស្រុកកោះញែក មានទន្លេស្រែពក ព្រែកច្បារ ព្រែករវាក់ ព្រែកត្រាវ ព្រែកត្រមេត ព្រែករវៃ ព្រែកពោធិ៍ ព្រែកដាក់ច្រិត ព្រែកណាមលៀវ ព្រែកយាឡៅផ្ទះ ព្រែកលាយ ព្រែកទាន ទំនប់ណំ ទំនប់អូររយ៉ះ ទំនប់អូរប្រង់ ទំនប់បាក់ខាំ ទំនប់ម្ទូរង្ហា ទំនប់អូរខ្ទូរ អូរជីមៀត អូរល្វេ អូរកោះញែក អូរធំ អូរកាម អូរនកាន់ អូរទា អូរវាត អូររោត អូរណាំងអូរផ្លាយ អូរជំរ អូរជងពក អូរសាយជាដើម។

- កំណត់បទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រងតំបន់ប្រភពទឹកនិងការពារអាងទឹកធម្មជាតិក្នុងក្រុង ស្រុក ឃុំ សង្កាត់ ទីប្រជុំជន និងតំបន់ពាក់ព័ន្ធជុំវិញ ដើម្បីចីរភាពនៃការផ្គត់ផ្គង់ទឹកស្អាត
- ជំរុញបង្កើតរោងចក្រទឹកស្អាតសមស្រប ឆ្លើយតបនឹងតម្រូវការប្រើប្រាស់ក្នុងលំនៅឋាននិងការប្រកបអាជីវកម្មក្នុងទីក្រុង។

**៥.១៤.២- យុទ្ធសាស្ត្ររង: ធានាការគ្រប់គ្រងសំណល់រាវមានប្រព័ន្ធបង្ហូរទឹកកខ្វក់និងប្រព័ន្ធបង្ហូរទឹកភ្លៀងក្នុងទីក្រុង ទីប្រជុំជនប្រកបដោយប្រសិទ្ធភាព**

- ថែរក្សានិងការពារប្រព័ន្ធទឹកធម្មជាតិ ដូចជាទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ ជ្រលង និងអាងស្តុកទឹកធម្មជាតិជាដើម ដើម្បីផ្គត់ផ្គង់ការប្រើប្រាស់សម្រាប់កសិកម្មនិងទឹកស្អាត
- កំណត់បែងចែកប្រព័ន្ធលូបង្ហូរទឹកភ្លៀងនិងប្រព័ន្ធលូបង្ហូរទឹកកខ្វក់ ឱ្យដាច់ដោយឡែកពីគ្នា
- បង្កើតប្រព័ន្ធលូទឹកកខ្វក់ត្រូវភ្ជាប់នឹងប្រព័ន្ធស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ សមស្របតាមបទដ្ឋានបរិស្ថានមុននឹងបង្ហូរចូលទៅប្រព័ន្ធទឹកធម្មជាតិ

- ត្រូវមានប្រព័ន្ធនិងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ រាល់មូលដ្ឋានឧស្សាហកម្មនិងមន្ទីរពេទ្យស្របតាមបទដ្ឋានបរិស្ថាន ដើម្បីធ្វើប្រព្រឹត្តិកម្មទឹកកខ្វក់មុននឹងបង្ហូរចូលប្រព័ន្ធទឹកកខ្វក់សាធារណៈ
- សិក្សាលទ្ធភាពសាងសង់ប្រព័ន្ធនិងស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ ស្របតាមបទដ្ឋានបរិស្ថាន ដើម្បីលើកកម្ពស់សុខុមាលភាពសង្គមនិងចីរភាពបរិស្ថាន
- លើកកម្ពស់ការយល់ដឹងអំពីបញ្ហាទឹក អនាម័យ ការសម្អាតអនាម័យ និងផលប៉ះពាល់នានាដែលកើតឡើងពាក់ព័ន្ធនឹងទឹក។

### ៥.១៤.៣- យុទ្ធសាស្ត្ររង : ធានាការគ្រប់គ្រងសំណល់រឹងក្នុងទីក្រុង ទីប្រជុំជនប្រកបដោយប្រសិទ្ធភាព

- កំណត់ប្រព័ន្ធប្រមូលសំណល់រឹងបែបទំនើប ដោយធ្វើការបែងចែកសំណល់រឹងតាមប្រភេទ
- កំណត់ទីតាំងគ្រប់គ្រងសំណល់រឹងសម្រាប់ក្រុងសែនមនោរម្យដែលមានផ្ទៃដី១៣០ហិកតា ស្ថិតនៅភូមិពូលូង សង្កាត់រមនា
- បន្តកំណត់ទីតាំងគ្រប់គ្រងសំណល់រឹងសម្រាប់ទីប្រជុំជនស្រុកទាំងអស់នៅខេត្តមណ្ឌលគិរី
- សិក្សាលទ្ធភាពអភិវឌ្ឍទីលានទុកដាក់សំណល់រឹងនិងប្រព័ន្ធកែច្នៃសំណល់រឹង
- បែងចែកប្រភេទសំណល់រឹង ដូចជាសំណល់រឹងទូទៅពីលំនៅឋាន សំណល់ឧស្សាហកម្ម និងសំណល់វេជ្ជសាស្ត្រពីមន្ទីរពេទ្យ ហើយរៀបចំគម្រោងផែនការគ្រប់គ្រងតាមប្រភេទនីមួយៗ
- លើកកម្ពស់ការផ្តល់សេវាកម្មប្រមូលសំណល់រឹង រួមទាំងដេប៉ូផ្ទុកសំរាមនិងប្រព័ន្ធដឹកជញ្ជូនសំណល់រឹងក្នុងទីក្រុង
- លើកកម្ពស់ភាពជាដៃគូរវាងរដ្ឋនិងឯកជននិងភាពជាដៃគូរវាងរដ្ឋនិងរដ្ឋក្នុងប្រព័ន្ធគ្រប់គ្រងសំណល់រឹង
- លើកកម្ពស់ការយល់ដឹងអំពីការគ្រប់គ្រងសំណល់រឹងនៅនឹងកន្លែង រួមទាំងអំពីគោលការណ៍ប្រើប្រាស់ឡើងវិញ ជួសជុល កាត់បន្ថយ និងកែច្នៃ និងអំពីផលប៉ះពាល់នៃការគ្រប់គ្រងសំណល់រឹងទីក្រុងដល់សាធារណៈនិងអ្នកពាក់ព័ន្ធទូទៅ។

## ៥.១៥- យុទ្ធសាស្ត្រប្រើប្រាស់ដី

ខេត្តមណ្ឌលគិរីមានផ្ទៃដីសរុប១ ៤២៨ ៨០០ហិកតា។ ផ្អែកតាមការសង្កេតជាក់ស្តែងការប្រើប្រាស់ដីនៅខេត្តមណ្ឌលគិរីត្រូវបានបែងចែកជាតំបន់គោលប្រើប្រាស់ដីនិងបទប្បញ្ញត្តិប្រើប្រាស់ដី ស្របតាមភូមិសាស្ត្រដូចខាងក្រោម៖

### ៥.១៥.១- ការកំណត់តំបន់គោលប្រើប្រាស់ដីក្នុងខេត្តមណ្ឌលគិរី

**ក-តំបន់គោលនគរូបនីយកម្ម** តំបន់គោលនគរូបនីយកម្មនីមួយៗត្រូវបានបែងចែកប្រភេទដីជា២ គឺប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់ដែលត្រូវកំណត់លម្អិតបន្តនៅក្នុងប្លង់គោលនិងផែនការប្រើប្រាស់ដីក្រុង ស្រុក និងទីប្រជុំជន។ ប្រភេទដីអាចសាងសង់បានត្រូវបានបែងចែកជាតំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់ចម្រុះ តំបន់ដឹកជញ្ជូន តំបន់សេវាកម្មទេសចរណ៍ តំបន់រដ្ឋបាលនិងសេវាសាធារណៈ តំបន់លម្ហសាធារណៈនិងផ្ទៃបៃតង តំបន់វប្បធម៌និងសាសនា និងតំបន់ផ្សេងៗមួយចំនួនទៀត ស្របតាមភូមិសាស្ត្រជាក់ស្តែង។ ប្រភេទដីកម្រិត

ការសាងសង់ត្រូវបានបែងចែកជាតំបន់កសិកម្ម តំបន់ព្រៃឈើ តំបន់ធនធានទឹក តំបន់ការពារ និងតំបន់ផ្សេងៗទៀត ស្របតាមភូមិសាស្ត្រជាក់ស្តែង។ តំបន់គោលនគរូបនីយកម្មនឹងត្រូវកំណត់ដោយប្លង់គោលប្រើប្រាស់ដីក្រុង ទីប្រជុំជននូវប្រភេទដីសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់។ តំបន់គោលនគរូបនីយកម្ម មានជាអាទិ៍៖

- ក្រុងសែនមនោរម្យ
- ទីប្រជុំជនស្រុកកែវសីមា
- ទីប្រជុំជនស្រុកកោះញែក
- ទីប្រជុំជនស្រុកអូររាំង
- ទីប្រជុំជនស្រុកពេជ្រាដា។

**ខ- តំបន់គោលកសិកម្ម** តំបន់គោលកសិកម្មត្រូវបានបែងចែកជា៣ រួមមានតំបន់កសិឧស្សាហកម្មខ្នាតធំ តំបន់កសិកម្មខ្នាតតូចនិងមធ្យម(កម្រិតខ្ពស់) និងតំបន់កសិកម្មខ្នាតតូចនិងមធ្យម(កម្រិតទាប)។ តំបន់គោលកសិកម្ម មានជាអាទិ៍៖

- តំបន់កសិកម្មខ្នាតធំដែលជាទីតាំងសម្បទានដីសេដ្ឋកិច្ច
- តំបន់កសិកម្មខ្នាតតូចនិងមធ្យម នៅក្រុងសែនមនោរម្យនិងតំបន់ជុំវិញ
- តំបន់កសិកម្មខ្នាតតូចនិងមធ្យម នៅជុំវិញនិងក្បែរសម្បទានដីសេដ្ឋកិច្ច
- តំបន់កសិកម្មដំណាំស្រូវដ៏មានសក្តានុពល នៅភូមិសាស្ត្រស្រុកកោះញែក។

**គ- តំបន់គោលធនធានទឹក** តំបន់គោលធនធានទឹក រួមមានទន្លេ ស្ទឹង ព្រែក អូរ បឹង ត្រពាំង ទំនប់ជាដើម។ តំបន់គោលធនធានទឹក មានជាអាទិ៍៖

- ទន្លេ មានទន្លេស្រែពក
- ព្រែក មានព្រែកច្បារ ព្រែកព្រះ ព្រែកឆ្លូង ព្រែករវាក់ ព្រែកដាក់ហ្មត ព្រែកដាក់រេតជាដើម
- អូរ មានអូរផ្លាយ អូរខ្ទង់ អូរជីមៀត អូរកោះញែក អូរឈ្លូល អូរហ៊ុចជាដើម
- ទំនប់ មានទំនប់ក្រោម ទំនប់លើ ទំនប់ស្រែជ្រៃ ទំនប់អូរប្រង់ ទំនប់បាក់ខាំជាដើម
- ទឹកធ្លាក់និងទឹកជ្រោះ មានទឹកធ្លាក់លែងឃិនលែងអង ទឹកជ្រោះប៊ូស្រាជាដើម(ដូចមានបញ្ជីក្នុងឧបសម្ព័ន្ធ៧)។

**ឃ- តំបន់គោលព្រៃឈើ** តំបន់គោលព្រៃឈើ រួមមានតំបន់ព្រៃឈើនិងចម្ការព្រៃឈើទូទៅ ស្ថិតនៅក្រៅតំបន់ការពារធម្មជាតិ។

**ង- តំបន់គោលការពារធម្មជាតិ** តំបន់គោលការពារធម្មជាតិត្រូវបានបែងចែកជារបៀងអភិរក្សជីវៈចម្រុះភាគពាយ័ព្យ ឧទ្យានជាតិអូរយ៉ាដាវ និងដែនជម្រកសត្វព្រៃកែវសីមា ភ្នំព្រេច លំផាត់ ណាមលៀរ និងអូរយ៉ាដាវ។ តំបន់ការពារធម្មជាតិត្រូវបានបែងចែកជា៤ គឺតំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍មូលដ្ឋាន។ តំបន់គោលការពារធម្មជាតិ មានជាអាទិ៍៖

- ដែនជម្រកសត្វព្រៃ មានដែនជម្រកសត្វព្រៃកែវសីមា ភ្នំព្រេច លំផាត់ ណាមលៀរ និងស្រែពក
- របៀងអភិរក្សជីវៈចម្រុះ មានរបៀងអភិរក្សជីវៈចម្រុះភាគពាយ័ព្យ។

**ច-តំបន់គោលផ្សេងៗ** តំបន់គោលផ្សេងៗត្រូវបានបែងចែកជាតំបន់រមណីយដ្ឋានទេសចរណ៍ តំបន់ទេសចរណ៍និងសាសនា និងតំបន់ធនធានរ៉ែមាស។ តំបន់គោលផ្សេងៗ មានជាអាទិ៍៖

- តំបន់ភ្នំណាមលៀវ
- តំបន់ដាក់ដាំ
- តំបន់ទេសភាពតាមដងទន្លេស្រែពក
- តំបន់ភ្នំដោះក្រមុំ
- តំបន់ភ្នំកែវសីមា
- ភូមិវប្បធម៌ជនជាតិដើមភាគតិច ពូតាំង មជ្ឈមណ្ឌលអភិរក្សនិងអភិវឌ្ឍន៍វប្បធម៌ សិល្បៈជនជាតិដើមភាគតិចទាំង១០ជនជាតិ រួមមានព្នង ក្រោល គ្រឹង ស្ទៀង ទំពួន ចារាយ ថ្មូន គួយ រដែរ រអូង។

## ៥.១៥.២- ការកំណត់បទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម

បទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្មសម្រាប់ការអភិវឌ្ឍនិងការអភិរក្សប្រកបដោយចីរភាពនៅខេត្តមណ្ឌលគិរី ត្រូវបានកំណត់ដូចខាងក្រោម៖

ក-រាល់ការប្ដូរដីពីតំបន់គោលមួយទៅតំបន់គោលមួយផ្សេងទៀតនៃការរៀបចំដែនដី ការប្ដូរប្រភេទដីឬការប្ដូរតំបន់ប្រើប្រាស់ដីត្រូវមានលិខិតអនុញ្ញាតអភិវឌ្ឍន៍ដីជាមុនពីអាជ្ញាធរមានសមត្ថកិច្ច។ អាជ្ញាធរមានសមត្ថកិច្ចត្រូវកត់ត្រានិងចុះបញ្ជីនូវរាល់ទិន្នន័យនៃការផ្លាស់ប្ដូរ ដើម្បីធ្វើបច្ចុប្បន្នកម្មផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីតាមកាលកំណត់។

ខ-រាល់ការអភិវឌ្ឍនិងការសាងសង់ត្រូវកំណត់អនុវត្តតាមគោលការណ៍ប្រភេទដីអាចសាងសង់បាន ប្រភេទដីកម្រិតការសាងសង់ និងតំបន់ប្រើប្រាស់ដី ដើម្បីតម្រង់ទិសការអភិវឌ្ឍជាលក្ខណៈប្រមូលផ្ដុំ ដោយចៀសវាងការពង្រីកឬការសាងសង់មិនត្រឹមត្រូវតាមបណ្ដោយដងផ្លូវជាតិនិងត្រូវធ្វើការវាយតម្លៃផលប៉ះពាល់ការរៀបចំដែនដីនិងនគរូបនីយកម្ម ព្រមទាំងត្រូវធានាបាននូវសោភណភាព ចីរភាព និងអត្តសញ្ញាណភូមិសាស្ត្រ វប្បធម៌ និងទេសភាពធម្មជាតិតំបន់ខ្ពង់រាប ប្រជុំភ្នំ ជម្រាលភ្នំ ជ្រលងភ្នំ ទន្លេ ស្ទឹង ព្រែក អូរជាដើម ដូចជាការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការរៀបចំលម្ហសាធារណៈ លម្ហបៃតង បណ្ដាញបៃតង អ័ក្សអេកូឡូស៊ី របងដីឡូត៍អំពីធម្មជាតិ ស្ថាបត្យកម្មធម្មជាតិ និងសំណង់បៃតងជាដើម។

គ-រាល់ការអភិវឌ្ឍដីក្នុងតំបន់គោលកសិកម្មត្រូវរក្សាស្ថានភាពភូមិសាស្ត្រ ទេសភាពធម្មជាតិតំបន់ខ្ពង់រាប ប្រជុំភ្នំ ជម្រាលភ្នំ ជ្រលងភ្នំ ទន្លេ ស្ទឹង ព្រែក អូរជាដើម។

ឃ-រាល់ការពង្រីកផ្ទៃដីតំបន់គោលនគរូបនីយកម្មចូលទៅក្នុងតំបន់គោលកសិកម្ម តំបន់គោលព្រៃឈើ និងតំបន់គោលធនធានទឹកដែលគ្មានផែនការគ្រោងទុកច្បាស់លាស់ និងការប្ដូរប្រភេទដីទាំងនេះទៅជាប្រភេទដីអាចសាងសង់បានត្រូវទប់ស្កាត់និងបញ្ឈប់។

ង-រាល់ការពង្រីកផ្ទៃដីតំបន់គោលកសិកម្ម ចូលក្នុងតំបន់គោលការពារធម្មជាតិ តំបន់គោលធនធានទឹក និងតំបន់គោលព្រៃឈើ និងការប្ដូរប្រភេទដីពីតំបន់គោលកសិកម្ម ទៅទៅជាតំបន់គោលនគរូបនីយកម្មដែលគ្មានផែនការត្រឹមត្រូវគ្រោងទុកច្បាស់លាស់ ត្រូវទប់ស្កាត់និងបញ្ឈប់។

ច- ត្រូវហាមឃាត់រាល់ការអភិវឌ្ឍដីដែលមានផលប៉ះពាល់នូវទីតាំងដូចខាងក្រោម លើកលែងតែការអភិវឌ្ឍដីនោះបម្រើដល់ផលប្រយោជន៍ជាតិនិងផលប្រយោជន៍សាធារណៈដែលត្រូវបានសម្រេចដោយរាជរដ្ឋាភិបាលៈ

- ទីស្ថានបុរាណវិទ្យា សម្បត្តិបេតិកភណ្ឌ ស្ថាបត្យកម្មឬសំណង់ដែលមានអត្ថប្រយោជន៍និងតម្លៃពិសេសផ្នែកស្ថាបត្យកម្ម ប្រវត្តិសាស្ត្រ សិល្បៈ វប្បធម៌ប្រពៃណី សាសនា និងសោភណភាព
- ទីតាំងភូមិសាស្ត្រ ទេសភាព និងរមណីយដ្ឋានធម្មជាតិ ភ្នំ ព្រៃឈើ ឧទ្យានជាតិ ទន្លេ ព្រែក ស្ទឹង អូរ បឹង អាងស្តុកទឹក និងប្រព័ន្ធបណ្តាញផ្លូវទឹកដែលមានអត្ថប្រយោជន៍និងតម្លៃប្រព័ន្ធអេកូឡូស៊ីនិងជីវៈចម្រុះ
- ដីកសិកម្មដែលមានជីជាតិនិងផលិតភាពកសិកម្មខ្ពស់
- ទីតាំងងាយទទួលរងគ្រោះថ្នាក់បណ្តាលមកពីការបាក់ដី ការរអិលដី ការស្រុតដី ទឹកជំនន់ ឬគ្រោះមហន្តរាយធ្ងន់ធ្ងរដែលធ្វើឱ្យមានការលំបាកក្នុងការផ្តល់សេវាកម្មសាធារណៈនិង/ឬរចនាសម្ព័ន្ធដីធម្មជាតិធ្ងន់ធ្ងរដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពសាធាណៈឬវិខានដល់ការរស់នៅអចិន្ត្រៃយ៍របស់ប្រជាជន។

ឆ- ដីសាធារណៈរបស់រដ្ឋដែលត្រូវការពារនិងអភិរក្ស មានជាអាទិ៍ៈ

- ដែនជម្រកសត្វព្រៃនិងរបៀងអភិរក្សជីវៈចម្រុះដែលត្រូវបានកំណត់ជាតំបន់គោលការពារធម្មជាតិ
- ទីបម្រុងទុកទឹក ទំនប់ទឹក អាងស្តុកទឹកធម្មជាតិ ផ្លូវទឹកនិងប្រភពទឹកនានា ទន្លេ ព្រែក ស្ទឹង បឹង អូរ និងប្រឡាយ ព្រមទាំងច្រាំង ដីចំណី ត្រូវបានកំណត់នៅក្នុងតំបន់គោលធនធានទឹក
- ទីតាំងបេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រដែលត្រូវបានចុះបញ្ជីដោយអាជ្ញាធរមានសមត្ថកិច្ច
- សួនច្បារសាធារណៈ លម្ហសាធារណៈ ភ្នំ ព្រៃឈើស្ថិតក្រៅតំបន់ការពារធម្មជាតិ
- ដីបម្រុងទុកសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ មានជាអាទិ៍ផ្លូវថ្នល់ អាកាសយានដ្ឋាន
- ដីឬទីតាំងដែលត្រូវបានការពារដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ជ- ដីរដ្ឋអាចត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញស្របតាមតម្រូវការចាំបាច់នៃការរៀបចំដែនដីនិងនគរូបនីយកម្ម ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម បរិស្ថាន និងវប្បធម៌។ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តមណ្ឌលគីរីនិងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិត្រូវវាយតម្លៃលើរាល់សំណើគម្រោងស្នើសុំធ្វើការអភិវឌ្ឍដីរដ្ឋស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ រាល់ការសម្រេចអនុញ្ញាតឱ្យប្រើប្រាស់ដីរដ្ឋត្រូវគោរពតាមគោលការណ៍សំខាន់ៗ ដូចខាងក្រោមៈ

- ត្រូវធ្វើការសិក្សាវាយតម្លៃហេតុផលប៉ះពាល់នៃការរៀបចំដែនដីនិងនគរូបនីយកម្ម
- ត្រូវរៀបចំផែនការរូបវន្តសម្រាប់អភិវឌ្ឍន៍ក្នុងទីតាំងគម្រោងស្របតាមបទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម។

ឈ- រាល់ការរៀបចំប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្មត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជន និងលម្ហសាធារណៈនិងផ្ទៃបៃតងសមស្របសម្រាប់ក្រុង ទីប្រជុំជននីមួយៗនិងត្រូវរៀបចំសម្រាប់មនុស្សទូទៅ រួមទាំងជនមាន

ពិការភាពនិងជនងាយរងគ្រោះ។ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជន និងលម្ហសាធារណៈនិងផ្ទៃបៃតងត្រូវរៀបចំសមាហរណកម្មជាមួយប្រព័ន្ធដឹកជញ្ជូន និងមានភាពសមស្របនឹងកម្រិតដង់ស៊ីតេនៃតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច សង្គម វប្បធម៌ កិច្ចការពារបរិស្ថាន និងមុខងារនៃការរៀបចំដែនដីនិងនគរូបនីយកម្ម។

៣- រាល់ការរៀបចំផែនការអភិវឌ្ឍន៍លំនៅឋានឬសហគមន៍ត្រូវគិតគូរដល់ការលើកកម្ពស់ការអភិវឌ្ឍតាមតំបន់ដាច់ស្រយាល តំបន់តាមបណ្តោយព្រំដែន តំបន់សម្បទានដីសេដ្ឋកិច្ច និងតំបន់សម្បទានដីសង្គមកិច្ច ដើម្បីរួមចំណែកដល់ការការពារបូរណភាពទឹកដីនិងតុល្យភាពនៃការអភិវឌ្ឍ។ ក្នុងករណីទីតាំងងាយទទួលរងគ្រោះថ្នាក់បណ្តាលមកពីការបាក់ដី ការរអិលដី ការស្រុតដី ទឹកជំនន់ ឬគ្រោះមហន្តរាយធ្ងន់ធ្ងរឬហានិភ័យផ្សេងៗដែលធ្វើឱ្យមានការលំបាកក្នុងការផ្តល់សេវាកម្មសាធារណៈឬប៉ះពាល់ដល់សុខភាពសាធាណៈឬរំខានដល់ការរស់នៅអចិន្ត្រៃយ៍របស់ប្រជាជនជាដើមមិនត្រូវរៀបចំឱ្យមានការតាំងទីលំនៅថ្មីទេ។

## ៦- ផែនការសកម្មភាព

ផែនការសកម្មភាពនិងគម្រោងអាទិភាពដែលបានកំណត់នៅក្នុងផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីត្រូវបានរៀបចំឡើងដោយការទទួលខុសត្រូវរបស់រដ្ឋបាលខេត្តមណ្ឌលគិរីនិងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តមណ្ឌលគិរី ដោយមានការគាំទ្របច្ចេកទេសពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រនិងសម្រេចគោលបំណងនិងចក្ខុវិស័យនៃផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី ចក្ខុវិស័យឆ្នាំ២០៤០សម្រាប់ការអភិវឌ្ឍនិងការអភិរក្សខេត្តមណ្ឌលគិរីប្រកបដោយចីរភាព ភាពឆ្លាត និងបរិយាបន្ន។

ផែនការសកម្មភាពនិងគម្រោងអាទិភាព មានវិសាលភាពគ្របដណ្តប់លើគម្រោងតាមវិស័យសម្រាប់អនុវត្តរយៈពេលខ្លី(២០២២-២០២៦) រយៈពេលមធ្យម(២០២៦-២០៣០) និងរយៈពេលវែង(២០៣០-២០៤០) ព្រមទាំងការធ្វើជាប្រចាំ ក្នុងក្របខ័ណ្ឌកម្រិតខុសៗគ្នា មានទាំងថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ក្រុង ស្រុក និងថ្នាក់ឃុំ សង្កាត់ ដើម្បីជាមូលដ្ឋានឆ្លើយតបនឹងតម្រូវការនៃការអភិវឌ្ឍនិងភាពចាំបាច់នៃការធ្វើអន្តរាគមន៍របស់រាជរដ្ឋាភិបាល ដែលមានក្នុងតារាងផែនការសកម្មភាពនិងវិធានការអនុវត្ត ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ១។

ផែនការសកម្មភាពនិងគម្រោងអាទិភាពនីមួយៗត្រូវធ្វើសមាហរណកម្មដាក់បញ្ចូលទៅជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍខេត្ត៥ឆ្នាំនិង/ឬកម្មវិធីវិនិយោគ៣ឆ្នាំរំកិលឬផែនការនិងកម្មវិធីផ្សេងៗទៀត។ តាមមធ្យោបាយនេះ ចំណែកខ្លះនៃថវិកាខេត្តអាចគ្រោងទុក ដើម្បីអនុវត្តបាន។ គម្រោងអាទិភាព ត្រូវជំរុញអនុវត្ត ទោះបីមិនបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍខេត្ត៥ឆ្នាំក៏ដោយ ក្នុងករណីមានថវិកាតាមរយៈប្រភពផ្សេងទៀត ដូចជាថវិកាអន្តរាគមន៍ថ្នាក់ជាតិឬភ្នាក់ងារដៃគូអភិវឌ្ឍជាដើម។

## ៧- ធនធានហិរញ្ញវត្ថុ

ប្រភពធនធាននិងហិរញ្ញវត្ថុសម្រាប់ការអនុវត្តផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី មានជាអាទិ៍៖

- ថវិកាជាតិ
- ថវិកាខេត្ត
- ថវិកាឯកជននិងវិស័យឯកជន

- ថវិកាភាពជាដៃគូរវាងរដ្ឋនិងឯកជន
- ថវិកាហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ថវិកាពីការចូលរួមរបស់ប្រជាពលរដ្ឋ សហគមន៍ និងសប្បុរសជន។

## ៨- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ

### ៨.១- យន្តការ

#### ៨.១.១- យន្តការថ្នាក់ជាតិ

យន្តការថ្នាក់ជាតិ ដើម្បីដឹកនាំ សម្របសម្រួល តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី ចក្ខុវិស័យឆ្នាំ២០៤០ មានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។ ក្រសួង ស្ថាប័នតាមវិស័យពាក់ព័ន្ធមានភារកិច្ចដឹកនាំ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃតាមវិស័យរៀងៗខ្លួន។

#### ៨.១.២- យន្តការថ្នាក់ក្រោមជាតិ

យន្តការថ្នាក់ក្រោមជាតិសម្រាប់ការអនុវត្តផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី ចក្ខុវិស័យឆ្នាំ២០៤០ មានរដ្ឋបាលខេត្តមណ្ឌលគិរីនិងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តមណ្ឌលគិរី រដ្ឋបាលក្រុង ស្រុក និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក មន្ទីរ និងអង្គភាពពាក់ព័ន្ធ។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តមណ្ឌលគិរីដឹកនាំដោយអភិបាលនៃគណៈអភិបាលខេត្តនិងមានមន្ទីរ អង្គភាពជុំវិញខេត្តជាសមាជិកមានតួនាទីសំខាន់ក្នុងការរៀបចំគម្រោងលម្អិតតាមសកម្មភាពអាទិភាពដែលបានស្នើឡើងខាងលើ ដើម្បីធានាការអនុវត្តផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីឱ្យសម្រេចបានជោគជ័យនិងត្រឹមត្រូវ។ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តមណ្ឌលគិរី ដោយមានការគាំទ្របច្ចេកទេសពីគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិនិងក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តការងារដោយផ្អែកលើគោលការណ៍ចូលរួមពីភាគីពាក់ព័ន្ធដទៃទៀត ដូចជាផ្នែករដ្ឋ ឯកជន អង្គការសង្គមស៊ីវិល វិជ្ជាជីវៈ និងប្រជាជនក្នុងមូលដ្ឋាន ទៅតាមប្រភេទនៃគម្រោងឬសកម្មភាពអាទិភាព។ គម្រោងលម្អិតខាងលើនេះត្រូវបញ្ជាក់ច្បាស់អំពីគោលបំណង សកម្មភាព ពេលវេលា ប្រភពហិរញ្ញវត្ថុ ការទទួលខុសត្រូវ និងសូចនាករសំខាន់ៗសម្រាប់តាមដាននិងវាយតម្លៃ។ ពិសេស គួរមានបញ្ចូលនូវសូចនាករពាក់ព័ន្ធនឹងហេតុប៉ះពាល់បរិស្ថាននិងសង្គមដែលអាចឱ្យធ្វើការតាមដាននិងការវាយតម្លៃបាន។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តមណ្ឌលគិរីត្រួតពិនិត្យការកសាងសំណើគម្រោងដែលត្រូវបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍ៥ឆ្នាំ ដោយត្រូវសម្របសម្រួលជាមួយមន្ទីរ អង្គភាពពាក់ព័ន្ធនានានិងយន្តការថ្នាក់ខេត្តផ្សេងទៀត ដូចជាគណៈកម្មការគ្រប់គ្រងដីរដ្ឋ គណៈកម្មការសុរិយោដីជាដើមដែលសុទ្ធតែមានសារៈសំខាន់ចាំបាច់ក្នុងការអនុវត្តផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី ដោយសារផែនការនេះមានលក្ខណៈអន្តរវិស័យ។ លេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តមណ្ឌលគិរីមានតួនាទីជាសេនាធិការឱ្យគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តមណ្ឌលគិរី ដើម្បីសម្រេចការងារនេះ។ តម្រូវការនៃទីតាំង ដើម្បីឆ្លើយតបនឹងការអភិវឌ្ឍថ្មីៗនិងកំណើនប្រជាជនគឺមិនអាចបញ្ឈប់បានដែលមានការពាក់ព័ន្ធជាមួយវិស័យជាច្រើននិងទាមទារឱ្យមានការចូលរួមដោះស្រាយរួមគ្នា។

ផែនការរៀបចំដែនដីនិងនគរូបនីយកម្មលម្អិតបន្តដែលត្រូវជំរុញរៀបចំនិងអនុវត្ត រួមមានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីក្រុង ស្រុក ទីប្រជុំជន និងប្លង់លម្អិតនគរូបនីយកម្ម ដោយផ្អែកលើមូលដ្ឋានផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី និងពិចារណានូវគ្រប់ទិដ្ឋភាពនៃតម្រូវការនៃការអភិវឌ្ឍនិងកំណើនប្រជាជន។ ពាក់ព័ន្ធករណីនេះ សមត្ថភាពនៃអាជ្ញាធរមូលដ្ឋានដើរតួសំខាន់ណាស់ក្នុងការកសាងផែនការឱ្យឆ្លើយតបនឹងតម្រូវការរបស់ខ្លួន។ ការកសាងផែនការតាមវិស័យលម្អិតជាច្រើនទៀតក៏ត្រូវរួមបញ្ចូលជាមួយផែនការរបស់ស្ថាប័នអង្គភាពរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍផ្សេងៗទៀត។ ផែនការតាមវិស័យទាំងនេះ គួរពិចារណាទំនាក់ទំនងជាមួយផែនការតាមវិស័យដទៃទៀតដែលរៀបចំដោយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ។

### ៨.១.៣- នីតិវិធីសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តមណ្ឌលគិរីត្រូវត្រួតពិនិត្យរាល់គម្រោងវិនិយោគដែលពាក់ព័ន្ធនឹងទិដ្ឋភាពនៃផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី។ ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីត្រូវយកចិត្តទុកដាក់អំពីភាពប្រទាក់ក្រឡាគ្នានៃគម្រោងវិនិយោគដែលបានស្នើឡើងជាមួយការអភិវឌ្ឍដែនដីឬរូបវន្តទាំងលើទិដ្ឋភាពផ្នែកបច្ចេកទេសនិងផ្នែកសង្គមនៃគម្រោងសម្រាប់សហគមន៍មូលដ្ឋាន។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមគឺជាផ្នែកមួយដ៏សំខាន់នៃការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ។

ដើម្បីរក្សាបាននូវភាពស៊ីចង្វាក់គ្នារវាងផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីនិងការអភិវឌ្ឍជាក់ស្តែងនៅខេត្តមណ្ឌលគិរី គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តមណ្ឌលគិរីត្រូវធ្វើការវាយតម្លៃផែនការរៀបចំដែនដីក្នុងរយៈពេល៥ឆ្នាំម្តង។ ការវាយតម្លៃនេះត្រូវអនុវត្តតាមការណែនាំរបស់ថ្នាក់ជាតិ ក្នុងករណីចាំបាច់។ ដំណើរការកែសម្រួលនិងវិសោធនកម្មត្រូវធ្វើឱ្យបានមុនការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍៥ឆ្នាំរបស់ខេត្តមណ្ឌលគិរី។ ភារកិច្ចសម្របសម្រួលរបស់រដ្ឋបាលខេត្តមណ្ឌលគិរី(ក្រុមប្រឹក្សាខេត្តនិងគណៈអភិបាលខេត្ត)គឺជាកត្តាគន្លឹះ។ ដូច្នេះ ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីគឺជាឯកសារគោលសម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍និងការវិនិយោគក្នុងប្រព័ន្ធផែនការមួយដែលស៊ីចង្វាក់គ្នាក្នុងកម្រិតខេត្ត។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តមណ្ឌលគិរីត្រូវអនុវត្តការតាមដាននិងការវាយតម្លៃការអនុវត្តផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី ដោយផ្អែកលើក្របខ័ណ្ឌសូចនាករដែលបានកំណត់ក្នុងគម្រោងនីមួយៗ។ ការវាយតម្លៃនេះនាំឱ្យទទួលបាននូវការកែសម្រួលដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តមណ្ឌលគិរីនិងឈានទៅទទួលបានការឯកភាពយល់ព្រមពីគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងតាមរយៈគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិនឹងឈានទៅទទួលបានការសម្រេចពីរាជរដ្ឋាភិបាល។

ការតាមដាននិងការវាយតម្លៃការអនុវត្តផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីត្រូវអនុវត្តដោយផ្អែកលើរបាយការណ៍បច្ចេកទេសនៃផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីដែលបានសម្រេចដោយរាជរដ្ឋាភិបាល ក្របខ័ណ្ឌច្បាប់ដែលមានច្បាប់និងគោលនយោបាយនៃវិស័យនីមួយៗ។ ភារកិច្ចរបស់គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មទាំងថ្នាក់ខេត្តនិងទាំងថ្នាក់ជាតិត្រូវសម្របសម្រួលវិស័យទាំងអស់ ដើម្បីឆ្ពោះទៅរកការអនុវត្តដែលប្រទាក់ក្រឡាគ្នានិងសមាហរណកម្មជាមួយគ្នា។

## ៨.២- គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តការងាររៀបចំដែនដីនិងនគរូបនីយកម្មក្នុងខេត្តមណ្ឌលគិរី ត្រូវអនុវត្តដោយផ្អែកលើផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី ចក្ខុវិស័យឆ្នាំ២០៤០ដែលបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយរាជរដ្ឋាភិបាល ព្រមទាំងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន មានជាអាទិ៍គោលនយោបាយជាតិស្ដីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់សំណង់ ច្បាប់ភូមិបាល ច្បាប់ស្ដីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្ដីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្ដីពីទេសចរណ៍ ច្បាប់ស្ដីពីព្រៃឈើ ច្បាប់ស្ដីពីជលផល ច្បាប់ស្ដីពីផ្លូវថ្នល់ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្ដីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ព្រមទាំងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

## ៨.៣- ការអភិវឌ្ឍស្ថាប័ន

ដូចបានបញ្ជាក់ក្នុងផ្នែកមុនៗរួចមកហើយ ការកសាងសមត្ថភាពនិងស្ថាប័ន រួមជាមួយអភិបាលកិច្ចល្អគឺជាមូលដ្ឋានគ្រឹះស្នូលនៃការអនុវត្តផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី។ ដូច្នេះ ការកសាងសមត្ថភាពនិងស្ថាប័នគឺជាកត្តាចាំបាច់។ សមាជិកគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តមណ្ឌលគិរី លេខាធិការដ្ឋានរួមទាំងក្រុមការងារស្នូលគឺជាតួអង្គសំខាន់ក្នុងចំណោមតួអង្គជាច្រើនទៀតដែលត្រូវទទួលការបណ្ដុះបណ្ដាលដើម្បីបានយល់ដឹងកាន់តែច្បាស់និងមានសមត្ថភាពអាចរៀបចំផែនការនិងកម្មវិធីតាមវិស័យរបស់ខ្លួនចាំបាច់នានាតាមសំណើគម្រោងសម្រាប់អនុវត្តប្រកបដោយប្រសិទ្ធភាព ដើម្បីឈានទៅសម្រេចគោលបំណងរបស់ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី។ ការកសាងសមត្ថភាពគឺជាឆ្អឹងខ្នងដ៏សំខាន់សម្រាប់ស្ថាប័នរឹងមាំ។ ទោះជាយ៉ាងណាក៏ដោយ វិធាននានាជាច្រើនក្នុងការពង្រឹងនិងកសាងស្ថាប័នគឺត្រូវការរៀបចំបន្ថែមជាចាំបាច់ ដើម្បីការអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាព។

## ៩- សេចក្ដីសន្និដ្ឋាន

ការរៀបចំនិងការដាក់ចេញនូវផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីមានភាពចាំបាច់និងឆ្លើយតបនឹងតម្រូវការជាក់ស្ដែងក្នុងមូលដ្ឋាន ពិសេសការកើនឡើងនូវចំនួនប្រជាជន តម្រូវការនៃការអភិវឌ្ឍ និងការប្រែប្រួលសេដ្ឋកិច្ច សង្គម វប្បធម៌ និងធនធានធម្មជាតិនៅខេត្តមណ្ឌលគិរី។ ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីក៏ជាការឆ្លុះបញ្ចាំងនូវឆន្ទៈដ៏មោះមុតរបស់រាជរដ្ឋាភិបាលក្នុងការដឹកនាំនិងបន្តជំរុញការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីបានពិចារណាយ៉ាងហ្មត់ចត់រួមគ្នា ដើម្បីធ្វើការអភិវឌ្ឍដែនដីខេត្តមណ្ឌលគិរីឱ្យទទួលបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅអភិវឌ្ឍន៍ដែលបានកំណត់ មិនឱ្យមានផលប៉ះពាល់អវិជ្ជមានដល់ចីរភាពបរិស្ថាន ធនធានធម្មជាតិ និងសមធម៌សង្គម។ ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីក៏តម្រង់ទិសការអភិវឌ្ឍពាក់ព័ន្ធនឹងកត្តារូបសាស្ត្រនិងរក្សាបាននូវសោភណភាពតាមតំបន់ ព្រមទាំងមានការបែងចែកផលប្រយោជន៍នៃកំណើនសេដ្ឋកិច្ចប្រកបដោយតុល្យភាពនិងសមធម៌ ហើយក៏ជាមូលដ្ឋានសម្រាប់ការ

កសាងផែនការតាមវិស័យនានានិងផែនការរូបវន្តកម្រិតក្រោមនានាផងដែរសម្រាប់ការអភិវឌ្ឍប្រកបដោយភាពសុខដុមរមនារវាងវិស័យពាក់ព័ន្ធទាំងអស់ ដើម្បីទទួលបាននូវបំណងប្រាថ្នារួមរបស់ខេត្តមណ្ឌលគិរី។ ដើម្បីសម្រេចបាននូវកិច្ចការដ៏សំខាន់និងចាំបាច់ដែលបានដាក់ចេញ ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីបានដាក់ស្នើនូវវិធាន និងមធ្យោបាយជាច្រើន ដើម្បីជាត្រីវិស័យសម្រាប់តម្រង់ទិសដំណើរការអភិវឌ្ឍគ្រប់វិស័យប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវ។

ជារួម ផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីនឹងក្លាយជាផែនទីបង្ហាញផ្លូវដ៏មានសារៈសំខាន់សម្រាប់ការគ្រប់គ្រង ការប្រើប្រាស់ ការបែងចែកដី និងធនធានធម្មជាតិ ដើម្បីគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សេដ្ឋកិច្ច សង្គម កិច្ចការពារបរិស្ថាន និងការលើកកម្ពស់ការថែរក្សាអត្តសញ្ញាណវប្បធម៌ជាតិប្រកបដោយវិចារណញ្ញាណនិងការទទួលខុសត្រូវច្បាស់លាស់ ដើម្បីធានាបានការអភិវឌ្ឍនិងការអភិរក្សប្រកបដោយចីរភាពស្របតាមតម្រូវការជាក់ស្ដែងរបស់ជាតិ ខេត្តមណ្ឌលគិរី និងប្រជាជនមូលដ្ឋាន ដោយឈរលើគោលការណ៍ច្បាប់ ការចូលរួម និងកិច្ចសហការអនុវត្តជិតស្និទ្ធរវាងគ្រប់ស្ថាប័ននិងអ្នកពាក់ព័ន្ធ។

ដូច្នេះ ការអនុវត្តផែនការរៀបចំដែនដីខេត្តមណ្ឌលគិរីប្រកបដោយប្រសិទ្ធភាពនិងការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់ ដោយមានការតាមដាននិងការវាយតម្លៃដំណើរការនៃការអនុវត្តផែនការហ្មត់ចត់គឺជាការចាំបាច់បំផុត ដើម្បីឈានទៅរួមចំណែកសម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍប្រកបដោយចីរភាព និងកំណើនសេដ្ឋកិច្ចក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

**សទ្ទានុក្រម**

**កេរ្សត្របរិស្ថានវិទ្យាឬកសិបរិស្ថានវិទ្យាឬកសិកម្មតាមបែបធម្មជាតិ** សំដៅដល់វិទ្យាសាស្ត្រអនុវត្តនៃប្រព័ន្ធអេកូឡូស៊ីសម្រាប់ការសិក្សា រៀបចំគម្រោង និងការគ្រប់គ្រងកសិកម្ម(Altieri, 1995) ដោយកំណត់សមាសធាតុសំខាន់របស់វាគឺប្រព័ន្ធនៃការប្រើប្រាស់ដីដែលធានានូវភាពសម្បូរបែបនៃពពួកសត្វនិងរុក្ខជាតិគ្រប់ប្រភេទ ជីវៈចម្រុះកេរ្សត្រសាស្ត្រ ការធ្វើឱ្យប្រសើរឡើងនូវដំណើរការប្រព័ន្ធអេកូឡូស៊ីនិងការផ្តល់នូវសេវាកម្មប្រព័ន្ធអេកូឡូស៊ី ការពង្រឹងសហគមន៍មូលដ្ឋាន និងការទទួលស្គាល់តួនាទីនិងតម្លៃនៃជនជាតិដើមភាគតិចនិងចំណេះដឹងមូលដ្ឋាន(IPCC, 2019)។

**ការកាន់កាប់ដីធ្លី** សំដៅដល់ប្រព័ន្ធផ្តល់សិទ្ធិលើដីធ្លី រួមមានគ្រប់ទម្រង់នៃកម្មសិទ្ធិ ភោគៈ និងសិទ្ធិប្រើប្រាស់ផ្សេងៗ។

**ការគ្រប់គ្រងរួមគ្នា** សំដៅដល់ដំណើរការរៀបចំការគ្រប់គ្រងរួមគ្នា តំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ ត្រូវកំណត់ លក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ក្នុងនោះមានការរៀបចំផែនការប្រើប្រាស់ដីតាមតំបន់និងការកំណត់តំបន់គ្រប់គ្រងរួមគ្នា លក្ខខណ្ឌតម្រូវនៃភាពស្របច្បាប់របស់សហគមន៍មូលដ្ឋានក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នានិងលក្ខខណ្ឌតម្រូវដទៃទៀតស្តីពីការគ្រប់គ្រងរួមគ្នា។

**ការប្តូរប្រភេទនៃការប្រើប្រាស់ដី** សំដៅដល់ការផ្លាស់ប្តូរការប្រើប្រាស់ដីពីប្រភេទមួយទៅប្រភេទផ្សេងទៀត ស្របតាមបទប្បញ្ញត្តិជាធរមាន។

**ការប្រែប្រួលអាកាសធាតុ** សំដៅដល់ការប្រែប្រួលស្ថានភាពអាកាសធាតុដែលអាចកំណត់អត្តសញ្ញាណបាន (តាមរយៈការវិភាគស្ថិតិ)តាមរយៈការប្រែប្រួលតួលេខមធ្យមនិងតួលេខអថេរនៃអាកាសធាតុ ហើយការប្រែប្រួលនោះបន្តកើតឡើងក្នុងរយៈពេលវែងជាច្រើនទសវត្សរ៍ឬយូរជាងនេះ។

**ការប្រើប្រាស់ដី** សំដៅដល់ការកំណត់អត្តសញ្ញាណប្រើប្រាស់ដី តំបន់គោលប្រើប្រាស់ដី ប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី និងបទប្បញ្ញត្តិនៃការប្រើប្រាស់ដី ស្របតាមទីតាំងភូមិសាស្ត្រនីមួយៗ ដូចជាតំបន់គោលនគរូបនីយកម្ម តំបន់គោលកសិកម្ម តំបន់គោលធនធានទឹក តំបន់គោលការពារធម្មជាតិ តំបន់គោលព្រៃឈើ តំបន់គោលផ្សេងៗ។ តំបន់គោលប្រើប្រាស់ដីនីមួយៗត្រូវបានបែងចែកជាប្រភេទប្រើប្រាស់ដី ហើយប្រភេទប្រើប្រាស់ដីនីមួយៗត្រូវបានបែងចែកជាតំបន់ប្រើប្រាស់ដី។

**គម្របព្រៃឈើ** សំដៅដល់ព្រៃឈើច្រើនប្រភេទផ្សេងទៀត ដូចជាព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃល្បោះ រួមបញ្ចូលទាំងប្រភេទព្រៃឈើដែលដុះឡើងវិញ ព្រៃរេចរឹល ព្រៃកោងកាង ព្រៃលិចទឹក ចម្ការព្រៃឈើ និងឫស្សី។ ចម្ការឈើដាំ ដូចជាកៅស៊ូ ដូងប្រេង អាកាស្យា ម៉ៃសាក់ ប្រេងខ្យល់ និងរុក្ខជាតិផ្តល់ឈើដទៃទៀតដែលមានលក្ខណៈដូចបានរៀបរាប់ខាងលើក៏ត្រូវបានចាត់ចូលជាគម្របព្រៃឈើផងដែរ។ ការកសាងផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី ប្រភេទព្រៃឈើបែងចែកជាព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង ព្រៃល្បោះ ព្រៃឈើដទៃទៀត(ចម្ការព្រៃឈើនិងឫស្សី) និងព្រៃកៅស៊ូ។

**គម្របដី** សំដៅដល់វត្ថុធាតុរូបវន្តនៅស្រទាប់ខាងលើនៃផ្ទៃដី ដូចជាព្រៃឈើ វាលស្មៅ ផ្ទៃទឹក ហេដ្ឋារចនាសម្ព័ន្ធ នគរូបនីយកម្ម ដីកសិកម្ម ដីទំនេរជាដើម។

**ចម្ការ** សំដៅដល់ដីប្រកបការងារកសិកម្មសារពើដំណាំ ស្របតាមទីតាំងភូមិសាស្ត្រតំបន់ភ្នំនិងខ្ពង់រាប។

**ជម្រាលទឹកភ្លៀង** សំដៅដល់តំបន់ដីប្រមូលទឹកឬទឹកភ្លៀងដែលទទួលបាននិងបង្ហូរចេញទៅកន្លែងណាមួយ ដូចជាទៅក្នុងទន្លេ ឆកសមុទ្រ ឬផ្ទៃទឹកផ្សេងទៀត។

**ជវភាព** សំដៅដល់សន្ទុះរីកចម្រើនប្រកបដោយថាមពលនិងគំនិតច្នៃប្រឌិត។

**ជីវៈចម្រុះ** សំដៅដល់បណ្ដាសារពាង្គកាយខុសគ្នានៅក្នុងប្រភេទតែមួយឬប្រភេទផ្សេងគ្នានិងបណ្ដាសារពាង្គកាយរស់នៃគ្រប់លំដាប់ថ្នាក់និងប្រភពទាំងអស់ រួមទាំងប្រព័ន្ធអេកូឡូស៊ីដែនដីគោក ដែនសមុទ្រ ដែនទឹកសាប និងបណ្ដាទំនាក់ទំនងអេកូឡូស៊ីដែលនៅក្នុងនោះមានប្រព័ន្ធអេកូឡូស៊ីទាំងនោះ។

**ដង់ស៊ីតេប្រជាជន** សំដៅដល់ចំនួនប្រជាជនធៀបនឹងផ្ទៃក្រឡាដី។

**ដែនជម្រកសត្វព្រៃ** សំដៅដល់តំបន់ក្នុងដែនដីគោកឬដែនទឹកដែលត្រូវឱ្យមានការធ្វើអន្តរាគមន៍យ៉ាងសកម្មសម្រាប់បំពេញគោលបំណងគ្រប់គ្រង ដើម្បីធានាឱ្យមានការថែទាំទីជម្រកនិង/ ឬដើម្បីបំពេញលក្ខខណ្ឌចាំបាច់សម្រាប់ប្រភេទណាមួយនៃសត្វឬរុក្ខជាតិ។

**តំបន់ការពារធម្មជាតិ** សំដៅដល់តំបន់នៃដែនដីសម្បត្តិសាធារណៈរបស់រដ្ឋ រួមមានដែនដីគោកឬដែនទឹក រួមទាំងឆ្នេរសមុទ្រស្ថិតនៅក្នុងតំបន់ដែលទទួលស្គាល់ដោយបញ្ញត្តិនៃច្បាប់ឬតំបន់ដែលបង្កើតថ្មីក្នុងដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។ តំបន់ទាំងនោះមានសារៈសំខាន់ទាំងផ្នែករូបសាស្ត្រនិងផ្នែកជីវសាស្ត្រដែលតម្រូវឱ្យមានការគ្រប់គ្រងតាមច្បាប់ក្នុងបំណងការពារនិងថែទាំជីវៈចម្រុះ ធនធានធម្មជាតិ និងធនធានវប្បធម៌ ហើយត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តភាពគ្រប់ជំនាន់ ដើម្បីផលប្រយោជន៍បរិស្ថាន សង្គម និងសេដ្ឋកិច្ច។

**តំបន់គោលកសិកម្ម** សំដៅដល់តំបន់ដីកសិកម្មជាទូទៅដែលនឹងត្រូវធ្វើចំណាត់ថ្នាក់កសិកម្មតាមប្រភេទនិងទំហំខ្នាតធំ ខ្នាតមធ្យម និងខ្នាតតូច ដូចជាស្រែ ចម្ការ សួនបន្លែ កសិដ្ឋានចិញ្ចឹមសត្វ ថ្នាលបណ្ដុះកូនឈើ កន្លែងចិញ្ចឹមត្រី បង្គារ ក្ដាម សិប្បកម្មបម្រើដល់កសិកម្មជាដើមតាមរយៈបទប្បញ្ញត្តិ។

